**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

UNIVERSITE ROYALE DE DROIT ET DES SCIENCES ECONOMIQUES

ROYAL UNIVERSITY OF LAW AND ECONOMICS

## សារណាបញ្ចប់ការសិក្សា

# ជនដែលត្រូវបានកម្រិតសមត្ថភាព នៅក្នុងការធ្វើសកម្មភាព

ស្រាវជ្រាវពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ កញ្ញា **សោម សុធារី**

ណែនាំដោយ

លោក **ពេជ្រ ពិសុទ្ធ**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២៣

ឆ្នាំចូលសិក្សា ២០១៩

ឆ្នាំសរសេរសារណា ២០២៣

# សេចក្ដីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **សោម សុធារី** ជានិស្សិតបញ្ចប់ថ្នាក់បរិញ្ញាបត្រ ជំនាញនីតិសាស្ត្រ ជំនាន់ទី២៣ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំសិក្សា ២០២២-២០២៣។

នាងខ្ញុំពិតជាមានក្ដីសោមនស្សរីករាយជាខ្លាំងដែលបានចងក្រងសារណានេះឡើង។ នាងខ្ញុំសូមធ្វើការអនុញ្ញាតដើម្បីថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះអ្នកមានគុណទាំងពីររបស់នាងខ្ញុំ គឺលោកឪពុក **សោម សារ៉ាត់** និងអ្នកម្ដាយ **ហ៊ុំ ថាវី** ដែលបានផ្ដល់កំណើតដល់កូន និងចិញ្ចឹមបីបាច់ថែរក្សាដោយព្រហ្មវិហារធម៌ទាំង៤ ដោយក្ដីមេត្តា ករុណា មុទិតា និងឧបេក្ខា ហើយបានបញ្ជូនកូនឱ្យទៅសាលាដើម្បីសិក្សារៀនសូត្រ ក្រេបជញ្ជក់នូវចំណេះដឹងតាំងពីថ្នាក់ទី១ រហូតមកដល់មហាវិទ្យាល័យនេះ លោកទាំងពីរតែងតែជួយជំរុញលើកទឹកចិត្តកូនជានិច្ច ដើម្បីឱ្យកូនដើរផ្លូវល្អ លើគន្លងធម៌ មានចំណេះជំនាញសម្រាប់ប្រើប្រាស់ គុណលោកទាំងពីរធំក្រៃលែងមិនអាចកាត់ថ្លៃបាន និងគ្មានថ្ងៃណាអាចបំភ្លេចបានឡើយសម្រាប់នាងខ្ញុំ។

នាងខ្ញុំសូមថ្លែងអំណរគុណផងដែរចំពោះគណៈគ្រប់គ្រងសាកលវិទ្យាល័យ មន្ត្រីរាជការ សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ ព្រមទាំងបុគ្គលិកទាំងអស់ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជាពិសេស **ឯកឧត្តម លុយ ចណ្ណា** សកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំប្រឹងប្រែងអស់ពីសមត្ថភាព លទ្ធភាពក្នុងការដឹកនាំគ្រប់គ្រងស្ថាប័នបណ្ដុះបណ្ដាលមូលធនខាងបញ្ញាឱ្យដំណើរការប្រកបដោយនិរន្តភាព និងប្រសិទ្ធភាពការងារខ្ពស់ ក្នុងស្មារតីពង្រឹងជាប្រចាំនូវថ្នាលបណ្ដុះបណ្ដាលធនធានមនុស្សឱ្យមានចំណេះដឹង បទពិសោធន៍ និងសមត្ថភាពខ្ពស់ គួបផ្សំនឹងសីលធម៌រស់នៅល្អ ដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍជាតិមាតុភូមិប្រកបដោយចីរភាព ។

នាងខ្ញុំសូមថ្លែងអំណរគុណដល់លោក **ពេជ្រ ពិសុទ្ធ** ដែលបានចំណាយពេលវេលាដ៏មានតម្លៃ បង្ហាញផ្លូវ និងបានផ្ដល់ដំបូន្មានក៏ដូចជាអនុសាសន៍ល្អៗជាច្រើន ក្នុងការតាក់តែងសារណាបញ្ចប់ការសិក្សានេះឡើង។

នាងខ្ញុំសូមថ្លែងអំណរគុណផងដែរ ចំពោះសិស្សនិស្សិតទាំងអស់ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជាពិសេសអរគុណដល់មិត្តៗរួមថ្នាក់ ដែលបានជួយលើកទឹកចិត្ត និងត្រួតពិនិត្យព្រមទាំងជួយកែលម្អសារណាបញ្ចប់ការសិក្សាមួយនេះឱ្យកាន់តែល្អប្រសើរឡើងផងដែរ។

ជាចុងក្រោយនាងខ្ញុំ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាថ្មី និងសូមប្រសិទ្ធពរជ័យដល់អ្នកមានគុណទាំងពីរ លោកឯកឧត្តមសកលវិទ្យាធិការ សកលវិទ្យាធិការរង លោក លោកស្រី សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និងប្រិយមិត្តនិស្សិតមិត្តអ្នកអានទាំងអស់ ទទួលយកដោយសេចក្ដីអនុគ្រោះ និងសូមឱ្យជួបប្រទះតែសេចក្ដីសុខ សុភមង្គលជានិច្ចនិរន្តរ៍។

# អារម្ភកថា

ប្រភេទ នៃជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពនៅកម្ពុជាមានតាំងពីយូរលង់ណាស់មកហើយ។ ច្បាប់បានកម្រិតសកម្មភាពរបស់ពួកគេ ដោយសកម្មភាពដែលពួកគេបានធ្វើឡើងក្រៅពីសកម្មភាពដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃហើយមិនមានជំនួយពីអ្នកមើលថែរក្សាតាមផ្លូវច្បាប់ទេ សកម្មភាពទាំងនោះត្រូវលុបចោល។ ប៉ុន្តែនៅមិនទាន់មានភាពច្បាស់លាស់នៅឡើយ ថាតើសកម្មភាពបែបណាដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ ហើយសកម្មភាពណាដែលច្បាប់អាចពិចារណាមិនអាចលុបចោលសកម្មភាពទាំងនោះបាន។ ដោយមានចម្ងល់ នឹងចង់ធ្វើការស្រាវជ្រាវបន្ថែម នាងខ្ញុំក៏បានសម្រេចចិត្តលើកយកប្រធានបទ « ជនដែលត្រូវបានកម្រិតសមត្ថភាពនៅក្នុងការធ្វើសកម្មភាព » មកធ្វើការសិក្សាស្វែងយល់បន្ថែម។

សារណានេះបានលើកឡើងអំពី « ជនដែលត្រូវបានកម្រិតសមត្ថភាពនៅក្នុងការធ្វើសកម្មភាព » នាងខ្ញុំនឹងធ្វើការបកស្រាយវែកញែកឱ្យស៊ីជម្រៅអំពីប្រភេទ នៃជនដែលត្រូវបានកម្រិតសមត្ថភាពនៅក្នុងការធ្វើសកម្មភាព លើសពីនេះ យើងនឹងធ្វើការសិក្សាបន្ថែមពីសកម្មភាពដែលពួកគេអាច ឬមិនអាចធ្វើបានដូចគ្នា។

នាងខ្ញុំសង្ឃឹមយ៉ាងមុតមាំថាសារណានេះនឹងអាចជាសៀវភៅមួយដែលជួយសម្រួលដល់ការសិក្សាស្រាវជ្រាវរបស់សិស្សនិស្សិត ក៏ដូចជាអ្នកដែលស្រេកឃ្លានចំណេះឱ្យយល់កាន់តែច្បាស់អំពីប្រភេទនៃជនដែលត្រូវបានកម្រិតសមត្ថភាពនៅក្នុងការធ្វើសកម្មភាព។

ជាចុងក្រោយនាងខ្ញុំពិតជាមានសេចក្តីសោមនស្សរីករាយក្រៃពេក ដែលបានបង្កើតស្នាដៃនេះឡើង ដើម្បីទុកជាឯកសារស្រាវជ្រាវបន្ថែមដល់មិត្តៗអ្នកអាន ជាពិសេសនិស្សិតជំនាន់ក្រោយ។ ទន្ទឹមនឹងនេះ នាងខ្ញុំរង់ចាំទទួលរាល់មតិរិះគន់ពីប្រិយមិត្តអ្នកអាន លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ និងនិស្សិតជំនាន់ក្រោយទាំងអស់នូវរាល់កំហុសខុសឆ្គងដែលកើតមានដោយអចេតនា នូវរាល់ពាក្យពេចន៍ អក្ខរាវិរុទ្ធ ដើម្បីជួយកែលម្អ ដល់សារណានេះកាន់តែប្រសើរឡើងសម្រាប់អ្នកអាន ព្រោះថាមនុស្សយើងម្នាក់ៗ មិនអាចមើលឃើញនូវភាពខ្វះខាតរបស់ខ្លួនបានគ្រប់ជ្រុងជ្រោយនោះឡើយ។ ជាទីបញ្ចប់នាងខ្ញុំ សូមគោរពជូនពរ ដល់និស្សិតមិត្តអ្នកអាន លោក លោកស្រី ព្រមទាំងលោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យទាំងអស់ ដែលចំណាយពេលដល់មានតម្លៃ យកចិត្តទុកដាក់ទៅលើប្រធានបទមួយនេះ និងសូមជូនពរនូវពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ថ្ងៃអង្គារ ១៤រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៣

# មាតិកា


ទំព័រ

**សេចក្តីផ្តើម ................................................................................................ ១**

**ជំពូកទី ១**

**ប្រភេទជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព**

**ផ្នែកទី១៖ អត្ថន័យ និងប្រភេទ ............................................................................ ៤**

១. និយមន័យ ........................................................................................................ ៤

២. ប្រភេទ នៃជនដែលត្រូវបានកម្រិតសមត្ថភាពនៅក្នុងការធ្វើសកម្មភាព............................ ៥

**ផ្នែកទី២៖ មូលហេតុដែលច្បាប់កំណត់ជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព ............................................................................................ ៦**

**ផ្នែកទី៣៖ គោលគំនិតក្នុងការការពារជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព ................................................................................................ ៧**

**ជំពូកទី ២**

**អនីតិជន**

**ផ្នែកទី១៖ សកម្មភាពរបស់អនីតិជន...................................................................... ៩**

១. សកម្មភាពដែលអនីតិជនបានធ្វើហើយមិនអាចលុបចោលបាន.................................... ១០

១.១ សកម្មភាពទទួលសិទ្ធិ.............................................................................. ១០

១.២ សកម្មភាពឱ្យរួចផុតពីកាតព្វកិច្ច ................................................................. ១១

១.៣ សកម្មភាពដែលទាក់ទងនឹងជីវភាពប្រចាំថ្ងៃ ................................................... ១២

១.៤ ការចាត់ចែងទ្រព្យសម្បត្តិដែលទទួលបានការអនុញ្ញាតឱ្យចាត់ចែង ........................ ១៣

១.៥ សកម្មភាពទាក់ទងនឹងអាជីវកម្មដែលទទួលបានការអនុញ្ញាតឱ្យធ្វើ ........................ ១៤

២. សកម្មភាពដែលអនីតិជនបានធ្វើហើយអាចលុបចោលបាន........................................ ១៥

២.១ សកម្មភាពទាក់ទងនឹងការបង្កើតកិច្ចសន្យា ..................................................... ១៥

២.២ សកម្មភាពបណ្តឹង .................................................................................... ១៦

២.៣ សកម្មភាពទាក់ទងនឹងការធ្វើមតកសាសន៍.................................................... ១៧

**ផ្នែកទី២៖ នីតិវិធីនៃការលុបចោលសកម្មភាព.......................................................... ១៧**

១. លក្ខខណ្ឌ ........................................................ ១៨

១.១ សកម្មភាពដែលអាចលុបចោលបាន ........................................................ ១៨

១.២ បុគ្គលដែលមានសិទ្ធិលុបចោល ........................................................ ១៨

១.៣ រយៈពេលដែលអាចលុបចោល ........................................................ ១៨

២. នីតិវិធីនៃការបង្ហាញឆន្ទៈលុបចោល ........................................................ ១៩

៣. អានុភាព ........................................................ ១៩

**ផ្នែកទី៣៖ យន្តការ និងការការពារភាគីម្ខាងទៀត ........................................................ ២០**

១. ការដាស់តឿន ........................................................ ២១

២. ការឆបោក ........................................................ ២២

២.១ លក្ខខណ្ឌ ........................................................ ២២

២.២ អានុភាព ........................................................ ២៣

៣. អត្តាធីនភាព ........................................................ ២៣

៣.១ លក្ខខណ្ឌទទួលបានអត្តាធីនភាព ........................................................ ២៤

៣.១.១ អត្តាធីនភាពតាមរយៈតុលាការ ........................................................ ២៤

៣.១.២ អត្តាធីនភាពតាមរយៈអាពាហ៍ពិពាហ៍ ........................................................ ២៥

៣.២ អានុភាពនៃអត្តាធីនភាព ........................................................ ២៦

**ជំពូកទី ៣**

**ជននៅក្រោមអាណាព្យាបាលទូទៅ**

**ផ្នែកទី១៖ របបអាណាព្យាបាលទូទៅ ........................................................ ២៨**

១. និយមន័យ ........................................................ ២៨

២. ការប្រកាសចាប់ផ្ដើមអាណាព្យាបាលទូទៅ ........................................................ ២៩

២.១ លក្ខខណ្ឌដែលអាចក្លាយជាជននៅក្រោមអាណាព្យាបាលទូទៅ ........................................................ ២៩

២.១.១ អាយុ ........................................................ ២៩

២.១.២ សមត្ថភាព ........................................................ ២៩

២.២ នីតិវិធីដើម្បីទទួលបានរបបអាណាព្យាបាលទូទៅ ........................................................ ២៩

២.២.១ ការស្នើសុំ ........................................................ ២៩

២.២.២ ការវិនិច្ឆ័យ និងការប្រកាសរបស់តុលាការ ........................................................ ៣០

២.២.៣ ការជ្រើសតាំងអ្នកអាណាព្យាបាលទូទៅ ..... ៣១
២.២.៣.១ បុគ្គលដែលអាចត្រូវបានជ្រើសតាំង ..... ៣១
២.២.៣.២ បុគ្គលដែលមិនអាចក្លាយជាអ្នកអាណាព្យាបាលទូទៅ ..... ៣១
២.២.៤ ការផ្លាស់ប្ដូរអ្នកអាណាព្យាបាលទូទៅ ..... ៣២
ក. ការលាឈប់របស់អ្នកអាណាព្យាបាលទូទៅ ..... ៣២
ខ. ការបញ្ឈប់អ្នកអាណាព្យាបាលទូទៅ ..... ៣២
៣. ការលុបចោលការប្រកាសចាប់ផ្ដើមអាណាព្យាបាលទូទៅ ..... ៣៣
៣.១ លក្ខខណ្ឌ ..... ៣៣
៣.២ នីតិវិធីនៃការលុបចោល ..... ៣៣
៣.២.១ ការដាក់ពាក្យសុំ ..... ៣៤
៣.២.២ ការវិនិច្ឆ័យ និងការប្រកាសរបស់តុលាការ ..... ៣៤
**ផ្នែកទី២៖ សកម្មភាពរបស់ជននៅក្រោមអាណាព្យាបាលទូទៅ ..... ៣៤**
១. សកម្មភាពដែលជននៅក្រោមអាណាព្យាបាលទូទៅបានធ្វើហើយមិនអាចលុបចោលបាន ..... ៣៤
១.១ សកម្មភាពដែលទាក់ទងនឹងជីវភាពប្រចាំថ្ងៃ ..... ៣៤
១.២ សកម្មភាពទាក់ទងនឹងការធ្វើមតកសាសន៍ ..... ៣៥
២. សកម្មភាពដែលជននៅក្រោមអាណាព្យាបាលទូទៅបានធ្វើហើយអាចលុបចោលបាន ..... ៣៦
២.១ សកម្មភាពទាក់ទងនឹងការបង្កើតកិច្ចសន្យា ..... ៣៦
២.២ សកម្មភាពបណ្ដឹង ..... ៣៧
**ផ្នែកទី៣៖ នីតិវិធីនៃការលុបចោលសកម្មភាព ..... ៣៧**
១.លក្ខខណ្ឌ ..... ៣៧
១.១ សកម្មភាពដែលអាចលុបចោលបាន ..... ៣៧
១.២ បុគ្គលដែលមានសិទ្ធិលុបចោល ..... ៣៨
១.៣ រយៈពេលដែលអាចលុបចោល ..... ៣៨
២. នីតិវិធីនៃការបង្ហាញឆន្ទៈលុបចោល ..... ៣៨
៣. អានុភាព ..... ៣៨
**ផ្នែកទី៤៖ យន្តការ និងការការពារភាគីម្ខាងទៀត ..... ៣៨**
១. ការដាស់តឿន ..... ៣៨

២. ការឆបោក .......... ៣៩

២.១ លក្ខខណ្ឌ.......... ៣៩

២.១ អានុភាព.......... ៣៩


## ជំពូកទី ៤

## ជននៅក្រោមហិតូបត្ថម្ភ


**ផ្នែកទី១៖ របបហិតូបត្ថម្ភ.......... ៤០**

១. និយមន័យ .......... ៤០

២. ការប្រកាសចាប់ផ្តើមហិតូបត្ថម្ភ.......... ៤០

២.១ លក្ខខណ្ឌដែលអាចក្លាយជាជននៅក្រោមហិតូបត្ថម្ភ.......... ៤១

២.២ នីតិវិធីដើម្បីទទួលបានរបបហិតូបត្ថម្ភ.......... ៤១

២.២.១ ការស្នើសុំ .......... ៤១

២.២.២ ការវិនិច្ឆ័យ និងការប្រកាសរបស់តុលាការ.......... ៤១

២.២.៣ ការជ្រើសតាំងហិតូបត្ថម្ភកៈ.......... ៤២

២.២.៣.១ បុគ្គលដែលអាចត្រូវបានជ្រើសតាំង.......... ៤២

២.២.៣.២ បុគ្គលដែលមិនអាចក្លាយជាហិតូបត្ថម្ភកៈ.......... ៤៣

២.២.៤ ការផ្លាស់ប្តូរហិតូបត្ថម្ភកៈ.......... ៤៣

២.២.៤.១ ការលាឈប់របស់ហិតូបត្ថម្ភកៈ.......... ៤៤

២.២.៤.២ ការបញ្ឈប់ហិតូបត្ថម្ភកៈ .......... ៤៤

៣. ការលុបចោលការប្រកាសចាប់ផ្តើមហិតូបត្ថម្ភ.......... ៤៤

៣.១ លក្ខខណ្ឌ.......... ៤៤

៣.២ នីតិវិធីនៃការលុបចោល .......... ៤៤

៣.២.១ ការដាក់ពាក្យសុំ .......... ៤៤

៣.២.២ ការវិនិច្ឆ័យ និងការប្រកាសរបស់តុលាការ.......... ៤៥

**ផ្នែកទី ២ សកម្មភាពរបស់ជននៅក្រោមហិតូបត្ថម្ភ.......... ៤៥**

១. សកម្មភាពដែលជននៅក្រោមហិតូបត្ថម្ភបានធ្វើហើយមិនអាចលុបចោល.......... ៤៥

១.១ សកម្មភាពដែលទាក់ទងនឹងជីវភាពប្រចាំថ្ងៃ.......... ៤៥

១.២ សកម្មភាពទាក់ទងនឹងការធ្វើមតកសាសន៍.......... ៤៥

១.៣ សកម្មភាពដែលផ្ទុយនឹងបញ្ញត្តិនៅក្នុងមាត្រា៣០ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ............... ៤៦
២. សកម្មភាពដែលជននៅក្រោមហិតូបត្ថម្ភបានធ្វើហើយអាចលុបចោលបាន ............................... ៤៦
ក. ការទទួល ឬការប្រើប្រាស់ទុន ........................................................................................... ៤៦
ខ. ការខ្ចីទ្រព្យ ឬការធានា ................................................................................................. ៤៦
គ. សកម្មភាពដែលមានបំណងទទួលបាន ឬធ្វើឱ្យបាត់បង់សិទ្ធិទាក់ទងនឹងទ្រព្យសម្បត្តិ ......... ៤៧
ឃ. ការធ្វើសកម្មភាពបណ្តឹង ............................................................................................... ៤៧
ង. ការធ្វើប្រទានកម្ម ឬធ្វើកិច្ចសន្យាស្រុះស្រួល ឬកិច្ចសន្យាមជ្ឈត្តកម្ម .................................... ៤៧
ច. ការទទួលស្គាល់នូវសន្តតិកម្ម ឬការបោះបង់ចោលនូវសិទ្ធិសន្តតិកម្ម ឬការបែងចែកនូវមត៌ក ... ៤៨
ឆ. ការប្រកែកមិនទទួល ឬការយល់ព្រមទទួលនូវប្រទានកម្ម ឬអច្ច័យទាន ............................... ៤៨
ជ. ការសាងសង់សំណង់ថ្មី ការសង់ឡើងវិញ ការសង់បន្ថែម ឬការជួសជុលធំ ........................ ៤៩
ឈ. ការធ្វើភតិសន្យា ដែលមានអំឡុងពេល .......................................................................... ៤៩
៣. សកម្មភាពដែលតុលាការបានប្រកាសចាំបាច់ត្រូវតែមានការយល់ព្រមពីហិតូបត្ថម្ភកៈ .......... ៤៩
**ផ្នែកទី ៣ នីតិវិធីនៃការលុបចោលសកម្មភាពរបស់ជននៅក្រោមហិតូបត្ថម្ភ .... ៥០**
១.លក្ខខណ្ឌ ......................................................................................................................... ៥០
១.១ សកម្មភាពដែលអាចលុបចោលបាន ............................................................................... ៥០
១.២ បុគ្គលដែលមានសិទ្ធិលុបចោល .................................................................................... ៥០
១.៣ រយៈពេលដែលអាចលុបចោល ........................................................................................ ៥១
២. នីតិវិធីនៃការបង្ហាញឆន្ទៈលុបចោល ................................................................................. ៥១
៣. អានុភាព ........................................................................................................................ ៥១
**ផ្នែកទី ៤ យន្តការ និងការការពារភាគីម្ខាងទៀត ........................................... ៥១**
១. ការដាស់តឿន .................................................................................................................. ៥១
២. ការឆបោក ...................................................................................................................... ៥២
**សេចក្តីសន្និដ្ឋាន ........................................................................................ ៥៣**
**អនុសាសន៍ ................................................................................................ ៥៥**
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

នីតិរដ្ឋប្បវេណី ជានីតិមួយ នៃនីតិឯកជន ជានីតិរួម ដែលបទដ្ឋាននានាកំណត់អំពីការរស់នៅរបស់មនុស្ស និងបេតិកភណ្ឌរបស់មនុស្សម្នាក់ៗ ដែលគ្របដណ្តប់ទៅលើទំនាក់ទំនងទ្រព្យសម្បត្តិ និងទំនាក់ទំនងញាតិ នៅក្នុងនោះក៏មានទាក់ទងទៅនឹងរបបគតិយុត្តិនៃសមត្ថភាពតាមផ្លូវច្បាប់របស់រូបវន្តបុគ្គលផងដែរ។ ក្រមរដ្ឋប្បវេណី បង្កើតឱ្យមានរបបគតិយុត្តនៃសមត្ថភាពក្នុងការធ្វើសកម្មភាពរបស់រូបវន្តបុគ្គលដោយធ្វើការកំណត់ប្រភេទបុគ្គល ដែលចាត់ទុកថា មិនមានសមត្ថភាពក្នុងការធ្វើពាណិជ្ជកម្មដោយឱ្យបុគ្គលទាំងនោះមានអ្នកអាណាព្យាបាល សម្រាប់បំពេញសមត្ថភាពនោះ។ មនុស្សគ្រប់រូបមានលក្ខណៈសម្បត្តិគ្រប់គ្រាន់អាចក្លាយជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ចបាន។ គ្រប់បុគ្គលទាំងអស់អាចទទួលបានសិទ្ធិ ចាប់តាំងពីពេលចាប់កំណើតនៅក្នុងផ្ទៃ ម្តាយ ប្រសិនបើទារកនោះអាចមានកំណើតនៅពេលក្រោយ។ នៅពេលដែលទារកកើតចេញពីផ្ទៃម្តាយ មានកំណើតមក ហើយពួកគេតែងតែទទួលបាននូវសិទ្ធិយ៉ាងពេញលេញ នៅក្នុងការធ្វើសកម្មភាពគ្រប់បែបយ៉ាងតាមដែលពួកគេចង់ធ្វើដោយមិនមាននរណាមកអាចរឹតត្បិតសិទ្ធិរបស់ពួកគេបានឡើយ ប៉ុន្តែសកម្មភាពទាំងនោះត្រូវស្ថិតនៅក្រោមច្បាប់ដែលនៅមានជាធរមាន។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ជនអសមត្ថភាពក្នុងការធ្វើសកម្មភាព ឬអាចហៅម៉្យាងទៀតថាជាជនដែលត្រូវបានកម្រិតសមត្ថភាព គឺជាជនដែលមិនអាចបង្ហាញឆន្ទៈប្រកបដោយប្រសិទ្ធភាព និងដោយឯករាជ្យបាន ហើយក៏មិនអាចវិនិច្ឆ័យអំពីការដឹងខុសត្រូវបានផងដែរ។ មុននឹងធ្វើសកម្មភាពណាមួយ បុគ្គលទាំងនេះត្រូវទទួលការអនុញ្ញាតពីអ្នកមានអំណាចមេបា អ្នកអាណាព្យាបាល ឬហិតូបត្ថម្ភកៈរបស់ជននោះជាមុនសិន មុនពេលបង្ហាញឆន្ទៈរបស់ខ្លួន។ ក្នុងករណី ជនដែលត្រូវបានកម្រិតសមត្ថភាពនៅក្នុងការធ្វើសកម្មភាពនេះ ធ្វើសកម្មភាពដោយមិនទទួលបានការអនុញ្ញាតពីអ្នកមានអំណាចមេបា អ្នកអាណាព្យាបាល ឬហិតូបត្ថម្ភកៈនោះទេ សកម្មភាពរបស់ជននោះអាចលុបចោលបាន។ សកម្មភាពដែលជនទាំងនោះធ្វើ ខ្លះច្បាប់ទទួលស្គាល់ អាចយកទៅប្រើប្រាស់ និងអនុវត្តបាន តែមានសកម្មភាពខ្លះទៀតដែលច្បាប់មិនអនុញ្ញាត និងមិនទទួលស្គាល់ហើយមិនអាចយកទៅអនុវត្តន៍បានឡើយ។ មូលហេតុដែលសកម្មភាពមួយចំនួនបានធ្វើឡើងហើយមិនត្រូវបានទទួលស្គាល់ ឬមិនមានសុពលភាព ព្រោះជនដែលបានធ្វើសកម្មភាពទាំងនោះ ច្បាប់បានកំណត់ថាជាជនដែលខ្វះសមត្ថភាព ឬត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព។

តើបុគ្គលប្រភេទណា ដែលច្បាប់បានកំណត់ថាជាបុគ្គលដែលត្រូវបានកម្រិតសមត្ថភាពនៅក្នុងការធ្វើសកម្មភាព? ហេតុអ្វីត្រូវកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពរបស់ពួកគេ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

សារណានេះធ្វើឡើងក្នុងគោលបំណងចង់ឱ្យសិស្សនិស្សិត ក៏ដូចជាអ្នកដែលមានបំណងចង់ចេះ ចង់ដឹង និងចង់ឈ្វេងយល់បន្ថែមអំពីប្រភេទ នៃជនដែលត្រូវបានកម្រិតសមត្ថភាពនៅក្នុងការធ្វើសកម្មភាពនេះយល់ដឹងអំពីជននីមួយៗដែលត្រូវបានកម្រិតសមត្ថភាពនៅក្នុងការធ្វើសកម្មភាព សកម្មភាពដែលពួកគេអាចធ្វើ ឬធ្វើទៅហើយមិនមានអានុភាព ឬត្រូវបានលុបចោល ព្រមទាំងធ្វើការសន្និដ្ឋាន និងផ្តល់អនុសាសន៍ដើម្បីធ្វើការកែតម្រូវចំពោះបញ្ហា ជាពិសេសគឺចងក្រងស្នាដៃទុកជាឯកសារសម្រាប់ប្អូនៗជំនាន់ក្រោយ និងទុកជាចំណុចផ្តើមនៃការស្រាវជ្រាវបន្តសម្រាប់អ្នកចង់ឈ្វេងយល់ និងស្រេកឃ្លានចំណេះដឹងជាអាទិ៍។

## ៤. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

ប្រធានបទ « **ជនដែលត្រូវបានកម្រិតសមត្ថភាពនៅក្នុងការធ្វើសកម្មភាព**» យើងខ្ញុំផ្តោតសំខាន់ទៅលើជនទាំង ៣ ( អនីតិជន ជនដែលស្ថិតនៅក្រោមអាណាព្យាបាលទូទៅ ជននៅក្រោមហិតូបត្ថម្ភ ) ដែលត្រូវបានកម្រិតសមត្ថភាព និងសកម្មភាពដែលពួកគេអាចធ្វើបានដោយគ្មានមូលហេតុលុបចោល និងសកម្មភាពបែបណាដែលពួកគេធ្វើទៅហើយអាចនឹងត្រូវលុបចោល។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ប្រធានបទសារណានេះពិតជាមានសារៈសំខាន់ណាស់ សម្រាប់ការរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ព្រោះគ្រប់ការធ្វើសកម្មភាពផ្សេងៗរបស់ជនដែលត្រូវបានកម្រិតសមត្ថភាព មិនប្រាកដថាសកម្មភាពទាំងនោះពិតប្រាកដដោយឆន្ទៈ ឬបុគ្គលដែលធ្វើសកម្មភាពនោះធ្វើឡើងដោយមានសមត្ថភាពគ្រប់គ្រាន់តាមផ្លូវច្បាប់ ឬមានវិការៈអាចនឹងត្រូវលុបចោលទេ។ មូលហេតុដែលច្បាប់បានកំណត់នូវបទបញ្ញត្តិស្តីពីការអាចលុបចោលបាន ព្រោះជាមធ្យោបាយ ក្នុងការការពារជនដែលត្រូវបានកម្រិតសមត្ថភាព នូវសកម្មភាពគតិយុត្តរបស់ជនដែលត្រូវបានកម្រិតសមត្ថភាព។ ដូចនេះវាពិតជាមានការស្មុគស្មាញនៅក្នុងការបែងចែកអំពីសកម្មភាពដែលជនទាំងនោះអាចធ្វើបាន ហើយសម្រាប់ប្រជាពលរដ្ឋទូទៅទៀតសោត ដែលពុំសូវយល់ដឹងផ្នែកច្បាប់ មិនបានយល់ច្បាស់ ដែលនាំឱ្យមានការបង្កើតនៅសកម្មភាពផ្សេងៗ ឬកិច្ចសន្យាណាមួយ ឬមានការភ័ន្តច្រឡំជាមួយជនទាំងនោះពេលធ្វើសកម្មភាពជាមួយពួកគេជាដើម។ ការខិតខំប្រឹងប្រែងរបស់ខ្ញុំក្នុងការសិក្សាស្រាវជ្រាវ និងចងក្រងសារណានេះឡើងមក គឺដើម្បីឱ្យប្រជាពលរដ្ឋ ក៏ដូចជាសិស្សនិស្សិតគាត់យល់ដឹង និងអាចយល់កាន់តែប្រសើរជាងមុនអំពីការប្រព្រឹត្តិទៅនៃសកម្មភាពរបស់ជនដែលត្រូវបានកម្រិតសមត្ថភាពធ្វើឡើង ចំពោះសកម្មភាពអ្វីពួកគេអាចធ្វើបានហើយមិនអាចលុបចោល និងសកម្មភាពដែលពួកគេធ្វើទៅមានមូលហេតុនៃការលុបចោលជាដើម ម៉្យាងវិញទៀតការសិក្សាស្រាវជ្រាវ និងចងក្រងសារណានេះឡើងក្នុងគោលបំណងជំនួយ

ដល់សិស្សនិស្សិត ជាពិសេសចំពោះគ្រប់បុគ្គលទាំងអស់ដើម្បីទុកជាឯកសារ នៅក្នុងការស្រាវជ្រាវបន្តឱ្យមានភាពកាន់តែល្អប្រសើរឡើងជាងនេះថែមទៀត។

## ៦. វិធីសាស្ត្រក្នុងការស្រាវជ្រាវ

នៅក្នុងសារណានេះ នាងខ្ញុំបានដកស្រង់មួយផ្នែកពីក្រមរដ្ឋប្បវេណីកម្ពុជា ហើយក៏បានស្រាវជ្រាវប្រមូលនូវឯកសារទៅតាមសារណាដែលពាក់ព័ន្ធរបស់សិស្សច្បងនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចពីមុនមក នឹងបានស្វែងរកឯកសារបន្ថែមក៏ដូចជាសៀវភៅច្បាប់មួយចំនួន ដូចជា ក្រមរដ្ឋប្បវេណីជប៉ុនជាដើម ក្នុងនោះដែរខ្ញុំក៏បានស្រាវជ្រាវនៅតាមអ៊ីនធើណេតដែលមានប្រភពច្បាស់លាស់ ឬគេហទំព័រផ្លូវការដែលដកស្រង់ចេញពីប្រភពដើម រួមទាំងចំណេះដឹងដែលទទួលបានពីសំណាក់លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យដែលខ្ញុំបានសិក្សាជាមួយរយៈពេល ៤ឆ្នាំកន្លងមក ជាពិសេសលោកគ្រូដែលជាសាស្ត្រាណែនាំដែលបានផ្តល់ជាមតិយោបល់ និងចង្អុលបង្ហាញផ្លូវដើម្បីឱ្យសារណាមួយនេះលេចចេញជារូបរាងផងដែរ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីងាយស្រួលក្នុងការសិក្សាឈ្វេងយល់អំពីប្រធានបទសារណានេះ ខ្ញុំបានធ្វើការបែងចែកជាបួនជំពូកធំៗដូចខាងក្រោម៖

**ជំពូកទី១៖ ប្រភេទជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព**

**ជំពូកទី២៖ អនីតិជន**

**ជំពូកទី៣៖ ជននៅក្រោមអាណាព្យាបាលទូទៅ**

**ជំពូកទី៤៖ ជននៅក្រោមហិតូបត្ថម្ភ**

# ជំពូកទី ១

# ប្រភេទជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព

# ជំពូកទី ១

# ប្រភេទជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព

## ផ្នែកទី១៖ អត្ថន័យ និងប្រភេទ

### ១. និយមន័យ

របបសមត្ថភាពក្នុងការធ្វើសកម្មភាព គឺជារបបការពារកុំឱ្យមានការទទួលរងនូវការខូចខាត ដែលកើតមានឡើងដោយសារកិច្ចការជួញដូររបស់ជនដែលពុំមានសមត្ថភាពគ្រប់គ្រាន់ក្នុងការវិនិច្ឆ័យ ដោយការមិនឱ្យជននៅក្នុងប្រភេទមួយចំនួន បង្កើតកិច្ចសន្យាដែលមានសុពលភាពពេញលេញបានកាលណាខូចប្រយោជន៍។

សមត្ថភាព គឺសំដៅទៅដល់សមត្ថភាពនៅក្នុងការអនុវត្តសិទ្ធិ និងអនុវត្តតាមកាតព្វកិច្ចក្រោមច្បាប់។ ចំពោះសមត្ថភាពត្រូវបានកំណត់ដោយកត្តាមួយចំនួន ដែលពឹងផ្អែកលើក្រមរដ្ឋប្បវេណីនៃប្រទេសនីមួយៗ (ដូចជាអាយុតាមច្បាប់កំណត់ ) ឬដោយលក្ខខណ្ឌផ្ទាល់ខ្លួន ( មិនមានបញ្ញា ឬរាងកាយមិនអាចទទួលបាននូវសិទ្ធិ ឬគោរពតាមកាតព្វកិច្ច។

ជនដែលត្រូវបានកម្រិតសមត្ថភាព ជាជនដែលខ្វះនូវសមត្ថភាពខាងស្មារតីពុំគ្រប់គ្រាន់សម្រាប់ធ្វើសកម្មភាពគតិយុត្ត[1] ហើយជាជនដែលត្រូវបានតុលាការដែលមានសមត្ថកិច្ចលើរឿងក្តីគ្រួសារប្រកាសថាជាជនដែលត្រូវបានកម្រិតសមត្ថភាពទៅតាមពាក្យសុំរបស់បុគ្គលជាក់លាក់មួយចំនួនដែលច្បាប់អនុញ្ញាត។[2] ជនដែលត្រូវបានកម្រិតសមត្ថភាព គ្រាន់តែសំដៅទៅលើការកម្រិតចំពោះសមត្ថភាពក្នុងការធ្វើសកម្មភាពប៉ុណ្ណោះ មិនមែនការដាក់កម្រិតលើសមត្ថភាពទទួលសិទ្ធិនោះទេ ដោយហេតុថាការទទួលសិទ្ធិគឺជាការផ្តល់ភាពចំណេញឱ្យជននោះ។ សមត្ថភាពនៅក្នុងការធ្វើសកម្មភាព សំដៅលើសមត្ថភាពដែលបុគ្គលម្នាក់អាចបង្ហាញឆន្ទៈប្រកបដោយប្រសិទ្ធភាពជាស្ថាពរ និងដោយឯករាជ្យ។ បុគ្គលដែលមានសមត្ថភាពអាចធ្វើអ្វីបាន អាចធ្វើសកម្មភាពពេញលេញ អាចបង្ហាញឆន្ទៈប្រកបដោយសុពលភាព ដោយការសម្រេចចិត្តរបស់ខ្លួនផ្ទាល់ ដោយមិនចាំបាច់មានជំនួយពីបុគ្គលណាម្នាក់នោះទេ បុគ្គលនោះត្រូវបានចាត់ទុកថាមានសមត្ថភាពគ្រប់គ្រាន់នៅក្នុងការធ្វើសកម្មភាពហើយ។

ជនដែលត្រូវបានកម្រិតសមត្ថភាពនៅក្នុងការធ្វើសកម្មភាព សំដៅដល់រូបវន្តបុគ្គលទាំងឡាយណាដែលខ្វះសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីសកម្មភាពតាមផ្លូវច្បាប់របស់ខ្លួនបាន ដោយមូលហេតុអាយុ សតិ និងបញ្ញាស្មារតី របស់ជននោះជាដើម។ យើងក៏អាចឱ្យនិយមន័យម៉្យាងទៀតថា ជនដែលត្រូវបានកម្រិតសមត្ថ-

[1] ក្រមរដ្ឋប្បវេណីបានពន្យល់ថា « ជនដែលស្ថិតក្នុងស្ថានភាពបាត់បង់ស្មារតីជានិរន្តរ៍ »

[2] សៀវភៅសេចក្តីផ្តើមនីតិរដ្ឋប្បវេណី ដែលនិពន្ធដោយ**សាស្ត្រាចារ្យ ណូមូរ៉ា តូយ៉ូហ៊ីរ៉ូ**

ភាពក្នុងការធ្វើសកម្មភាព គឺជាជនដែលច្បាប់ចាត់ទុកថា ពុំមានសមត្ថភាពក្នុងការធ្វើសកម្មភាព[3]ទោះបីជាជននោះមានសមត្ថភាពខាងឆន្ទៈ ឬគ្មានសមត្ថភាពខាងឆន្ទៈក៏ដោយ[4]។

សមត្ថភាពនៅក្នុងការធ្វើសកម្មភាព សំដៅទៅលើលក្ខណៈសម្បត្តិ ដែលអាចធ្វើឱ្យសកម្មភាពរបស់ខ្លួនមានអានុភាពតាមផ្លូវច្បាប់[5]។ ជនអសមត្ថភាព[6]ក្នុងការធ្វើសកម្មភាព ឬអាចហៅម៉្យាងទៀតថាជាជនដែលត្រូវបានកម្រិតសមត្ថភាព គឺជាជនដែលមិនអាចបង្ហាញឆន្ទៈប្រកបដោយប្រសិទ្ធភាព និងដោយឯករាជ្យបាន ហើយក៏មិនអាចវិនិច្ឆ័យអំពីការដឹងខុសត្រូវបានផងដែរ។ មុននឹងធ្វើសកម្មភាពណាមួយ បុគ្គលទាំងនេះត្រូវទទួលការអនុញ្ញាតពីអ្នកមានអំណាចមេបា អ្នកអាណាព្យាបាល ឬហិតូបត្ថម្ភកៈរបស់ជននោះជាមុនសិន មុនពេលបង្ហាញឆន្ទៈរបស់ខ្លួន។ ក្នុងករណី ជនដែលត្រូវបានកម្រិតសមត្ថភាពនៅក្នុងការធ្វើសកម្មភាពនេះ ធ្វើសកម្មភាពដោយមិនទទួលបានការអនុញ្ញាតពីអ្នកមានអំណាចមេបា អ្នកអាណាព្យាបាល ឬហិតូបត្ថម្ភកៈនោះទេ សកម្មភាពរបស់ជននោះអាចលុបចោលបាន។

## ២. ប្រភេទ នៃជនដែលត្រូវបានកម្រិតសមត្ថភាពនៅក្នុងការធ្វើសកម្មភាព

យោងតាមមាត្រា ១៦ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ បានឱ្យអត្ថន័យនៃជនដែលត្រូវបានចាត់ទុកថាជាជនដែលត្រូវបានកម្រិតសមត្ថភាព គឺសំដៅទៅលើជន ៣ប្រភេទ រួមមានអនីតិជន ជននៅក្រោមអាណាព្យាបាលទូទៅ និងជននៅក្រោមហិតូបត្ថម្ភ។ មាត្រានេះហៅជនទាំងនោះថាជាជនដែលត្រូវបានកម្រិតនូវសមត្ថភាពក្នុងការធ្វើសកម្មភាព ក្នុងន័យថាជននោះត្រូវបានកម្រិតសមត្ថភាពធ្វើកិច្ចសន្យាសុពលរហូតដល់ពេលសកម្មភាពនោះត្រូវបានលុបចោល។

អនីតិជនជាជនដែលច្បាប់ចាត់ទុកថាជាមនុស្សដែលពុំមានសមត្ថភាពគ្រប់គ្រាន់ ក្នុងការធ្វើសកម្មភាពមួយចំនួន និងទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួន។ ច្បាប់បានចាត់ទុកអនីតិជន ជាជនទន់ខ្សោយ បើប្រៀបធៀបទៅនឹងនីតិជន។ ចំណែកឯនីតិជនដែលជាជនទទួលបានការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ ត្រូវហៅថាជននៅក្រោមអាណាព្យាបាលទូទៅ ហើយត្រូវស្ថិតនៅក្រោមអ្នកអាណាព្យាបាលទូទៅ[7]។ រីឯនីតិជនដែលបាន

---

[3] សកម្មភាព គឺសំដៅទៅលើការបង្ហាញ ឆន្ទៈ ជាឯកតោភាគី ឬតាមរយៈកិច្ចសន្យា។

[4] មេរៀនស្តីពីលក្ខខណ្ឌបង្កើតកិច្ចសន្យាក្នុងវគ្គបណ្តុះបណ្តាលជំនាន់ទី ៧ នៃវិភាគទានច្បាប់ដែលរៀបរៀងដោយ កញ្ញាមេធាវី ឈុំ មុនីសុជាតា

[5] សន្ទានុក្រមពាក្យច្បាប់ ខ្មែរ អង់គ្លេស បារាំង ផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី

[6] អសមត្ថជន គឺជាជនដែលមិនអាចធ្វើសកម្មភាពដោយខ្លួនឯងបានឡើយ ក្នុងករណីដែលមិនមានការយល់ព្រមពីអ្នកតំណាងដែលច្បាប់បានកំណត់។

[7] មាត្រា ២៥ ក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៧

ទទួលការប្រកាសចាប់ផ្តើមហិតូបត្ថម្ភ ត្រូវហៅថាជននៅក្រោមហិតូបត្ថម្ភ ហើយត្រូវស្ថិតនៅក្រោមការថែរក្សាដោយហិតូបត្ថម្ភកៈ[8]។

ជនដែលត្រូវបានកម្រិតសមត្ថភាព គ្រាន់តែសំដៅទៅលើការកម្រិតចំពោះសមត្ថភាពក្នុងការធ្វើសកម្មភាពប៉ុណ្ណោះ មិនមែនជាការដាក់កម្រិតលើសមត្ថភាពទទួលសិទ្ធិនោះទេ។ ចំពោះជនក្រៅពីជនដែលត្រូវបានកម្រិតសមត្ថភាពនៅក្នុងការធ្វើសកម្មភាព ជាជនដែលមានសមត្ថភាពក្នុងការធ្វើសកម្មភាពពេញលេញ។ កិច្ចសន្យាដែលបង្កើតឡើងដោយជនក្រៅពីជនដែលត្រូវបានកម្រិតនូវសមត្ថភាពក្នុងការធ្វើសកម្មភាពគឺមានសុពលភាពពេញលេញ ប្រសិនបើពុំមានមូលហេតុផ្សេងទៀតដែលនាំឱ្យមោឃៈ ឬលុបចោលកិច្ចសន្យានោះបាន។

## ផ្នែកទី២៖ មូលហេតុដែលច្បាប់កំណត់ជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព

មានរឿងរ៉ាវគួរឱ្យកត់សម្គាល់ជាច្រើន អំពីមូលហេតុដែលច្បាប់ចែងកម្រិតសមត្ថភាពចំពោះ អនីតិជន ជននៅក្រោមអាណាព្យាបាលទូទៅ និងជននៅក្រោមហិតូបត្ថម្ភនេះ។ ចំពោះអនីតិជន ជាជនដែលមានវ័យជាកុមារភាព សកម្មភាពដែលពួកគេធ្វើមិនប្រាកដទេថាពួកគេពិតជាមានស្មារតីគ្រប់គ្រាន់ដែលអាចគ្រប់គ្រងចាត់ចែង រក្សាការពារទ្រព្យសម្បត្តិរបស់ខ្លួនបាននោះ លុះត្រាតែពួកគេមានអាយុ ១៨ឆ្នាំ ដែលច្បាប់បានចាត់ទុកថាពួកគេបានដល់នីតិភាព។ ទន្ទឹមនឹងនេះ បុគ្គលដែលអាយុក្រោម១៨ ឆ្នាំ មានកម្រិតនៃការយល់ដឹង ការដឹងខុស ដឹងត្រូវ គឺផ្សេងៗគ្នា ខុសប្លែកពីគ្នា ទៅតាមសង្គមជាក់ស្តែងដែលពួកគេរស់នៅ[9] ហើយពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ទៀតមានកម្រិតនៃការយល់ដឹងខុសៗគ្នា ផ្សេងៗពីគ្នា ហេតុនេះហើយ ទើបច្បាប់កម្រិតសមត្ថភាពនៅក្នុងការធ្វើសកម្មភាពរបស់ពួកគេ។

ម៉្យាងវិញទៀត ក្នុងករណីខ្លះ បុគ្គលដែលអាយុលើសពី ១៨ឆ្នាំ អាចយល់ដឹង និងចុះកិច្ចសន្យាបានដោយខ្លួនឯងហើយ ប៉ុន្តែករណីខ្លះទៀតមិនអាចចុះកិច្ចសន្យាដោយខ្លួនឯងបានឡើយ ដោយមិនអាចយល់ដឹងអ្វីទាំងអស់។ ជនដែលមិនអាចយល់ដឹងអ្វីទាំងអស់នោះ អាចជាជនដែលមានស្ថានភាពជានិរន្តរ៍ដែលខ្វះសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យដោយសារតែវិបត្តិផ្នែកបញ្ញាស្មារតី ជនដែលមិនអាចធ្វើសកម្មភាពសម្រាប់ជីវភាពប្រចាំថ្ងៃ ជនដែលមិនដឹងថាមានរឿងអ្វីកើតឡើងជុំវិញខ្លួនឯង គ្រួសារ ឬសង្គម ជនដែលជួបគ្រោះថ្នាក់ហេតុឈានទៅដល់ជិតបាត់បង់ជីវិត ឬពិការជាដើម ដែលពួកគេនៅមានដង្ហើមដក គ្រាន់តែពួកគេមិនអាចធ្វើសកម្មភាពអ្វីបាន ដែលដេកនៅនឹងមួយកន្លែង ដែលគេហៅថាមនុស្សរុក្ខជាតិ។ មនុស្សប្រភេទនេះ ច្បាប់បាន

[8] មាត្រា ២៩ ក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៧

[9] ក្រមរដ្ឋប្បវេណីជប៉ុនបានកំណត់ថាអនីតិជនដែលដល់នីតិភាពលុះត្រាតែអាយុ ២០ឆ្នាំ

កម្រិតសមត្ថភាពនៅក្នុងការធ្វើសកម្មភាពរបស់ពួកគេផងដែរ។ របបគតិយុត្តនីតិជនប្រភេទនេះ ត្រូវបានច្បាប់កំណត់ឱ្យស្ថិតនៅក្រោមអាណាព្យាបាលទូទៅ និងស្ថិតនៅក្រោមហិតូបត្ថម្ភ។

សមត្ថភាពក្នុងការប្រព្រឹត្តសកម្មភាពនានាបង្កើតជាទំនាក់ទំនងតាមផ្លូវច្បាប់ជាមួយអ្នកដទៃ ដែលស្តែងឡើងតាមរយៈការបង្ហាញឆន្ទៈរបស់អ្នកនោះ។ សកម្មភាពនានា ដែលកើតឡើង មិនប្រាកដថាមានសុពលភាពពេញលេញតាមផ្លូវច្បាប់នោះទេ ដែលសកម្មភាពខ្លះអាចមានវិការៈ ឬមានភាពមិនប្រក្រតីជាដើម ដែលត្រូវធ្វើការពិចារណាបន្ទាប់ពីសកម្មភាពនោះត្រូវបានប្រព្រឹត្តិឡើង ក៏ប៉ុន្តែ ប្រសិនបើគេត្រូវតែលើកយកគ្រប់ករណីនីមួយៗមកពិចារណាដើម្បីបញ្ជាក់ថាបុគ្គលណាម្នាក់មាន ឬគ្មានសមត្ថភាពបង្ហាញឆន្ទៈនោះ គេនឹងត្រូវធ្វើកិច្ចការច្រើនឥតគណនា ហើយភាពមាន ឬគ្មានសមត្ថភាពខាងឆន្ទៈ ចាំបាច់ត្រូវវិនិច្ឆ័យដោយឡែកពីគ្នា ក៏ប៉ុន្តែសម្រាប់យើងគ្រប់គ្នា នៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ដោយសារតែយើងត្រូវធ្វើការជួញដូរជាប់ជារៀងរាល់ថ្ងៃយ៉ាងដូច្នេះ ការដែលត្រូវតែធ្វើការវិនិច្ឆ័យថាតើភាគីមាន ឬគ្មានសមត្ថភាពខាងឆន្ទៈគ្រប់គ្រាន់នៅក្នុងគ្រប់ករណីជួញដូរនីមួយៗបែបនោះ គឺពិតជាមានភាពស្មុគស្មាញ។ ក្នុងស្ថានភាពជាក់ស្តែង គឺយើងពិបាកសង្ឃឹមថានឹងមាននីតិវិធីយ៉ាងដូច្នេះណាស់ ហើយនឹងជួបប្រទះជាមួយករណីដែលធ្វើការវិនិច្ឆ័យសម្រេចមិនកើតផងក៏មានជាពុំខាន។

ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានកំណត់នូវបទបញ្ញត្តិស្តីពីបទដ្ឋានជាក់លាក់ សម្រាប់ធ្វើការបែងចែកជនដែលមាន និងជនដែលគ្មានសមត្ថភាពក្នុងការធ្វើសកម្មភាព ពោលគឺជាសមត្ថភាពសំរេចនូវសកម្មភាពគតិយុត្តរបស់ខ្លួនដោយខ្លួនឯង។ ជនដែលឆន្ទៈរបស់គាត់មិនអាចយល់ដឹងដូចជនដទៃ ឬជនដែលខ្វះសមត្ថភាពធ្វើការវិនិច្ឆ័យដោយខ្លួនឯង ត្រូវបានចាត់ទុកជាជនដែលត្រូវបានកម្រិតសមត្ថភាព។ ចំពោះជនដែលគ្មានសមត្ថភាពធ្វើការវិនិច្ឆ័យដោយខ្លួនឯង ច្បាប់បានបើកឱ្យមានវិធានការទំនុកបម្រុង ដោយអនុញ្ញាតឱ្យអ្នកដ៏ទៃផ្សេងទៀតជួយបំពេញបង្គ្រប់ការបង្ហាញឆន្ទៈ ក្នុងគោលបំណងដើម្បីការពារជនគ្មានសមត្ថភាពធ្វើការវិនិច្ឆ័យដោយខ្លួនឯងនោះ ដូចបញ្ជាក់នៅក្នុង **ផ្នែកទី ៣ គោលគំនិតក្នុងការការពារជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពខាងក្រោម។**

## ផ្នែកទី៣៖ គោលគំនិតក្នុងការការពារជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព

ជនខ្វះសមត្ថភាព សំដៅដល់បុគ្គលដែលធ្វើសកម្មភាពចុះកិច្ចសន្យា សកម្មភាពឯកតោភាគីជាអាទិ៍ ដែលបុគ្គលនោះមិនអាចយល់ដឹង និងវិនិច្ឆ័យនូវលទ្ធផលតាមផ្លូវច្បាប់នៃអំពើរបស់ខ្លួនបាន។ ដោយឈរលើគោលការណ៍ស្វ័យភាពបុគ្គលឯកជន បុគ្គលគ្រប់រូបមានសិទ្ធិសេរីភាពក្នុងការធ្វើកិច្ចសន្យា បុគ្គលគ្រប់រូបទទួលបាននូវសិទ្ធិ និងកាតព្វកិច្ចតាមឆន្ទៈរបស់ខ្លួនដោយសេរី។ បុគ្គលម្នាក់ៗមានសេរីភាពក្នុងការបង្ហាញឆន្ទៈ ក៏ប៉ុន្តែ

ដើម្បីឱ្យការបង្ហាញឆន្ទៈនោះប្រព្រឹត្តិទៅប្រកបដោយប្រសិទ្ធភាព វាមានភាពចាំបាច់ណាស់ដែលអ្នកបង្ហាញឆន្ទៈនោះត្រូវមានសមត្ថភាពអាចយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់របស់ខ្លួនបាន។

ជនដែលខ្វះសមត្ថភាពបង្ហាញឆន្ទៈ ឬជនដែលខ្វះសមត្ថភាពធ្វើការវិនិច្ឆ័យ ដោយខ្លួនឯងត្រូវបានចាត់ទុកថាជាជនដែលត្រូវបានកម្រិតសមត្ថភាព ក្នុងគោលបំណងការពារជនប្រភេទនេះ គេទទួលស្គាល់ឱ្យជនដែលត្រូវបានកម្រិតសមត្ថភាពទាំងនេះអនុវត្តនូវសកម្មភាពគតិយុត្ត ត្រឹមតែមួយចំណែកប៉ុណ្ណោះ ឬមិនឱ្យអនុវត្តបានទេប្រសិនបើគ្មានការយល់ព្រម ឬការជ្រោមជ្រែង ពីអ្នកណាម្នាក់ផ្សេងទៀតទេនោះ ប៉ុន្តែម្យ៉ាងទៀត ច្បាប់ក៏ចាំបាច់ត្រូវ តែចែងទុកជាបញ្ញត្តិផងដែរ សំដៅការពារអ្នកដែលបានធ្វើកិច្ចសន្យាជាមួយជនណាដែលខ្លួនពុំបានដឹងថាជាជនដែលត្រូវបានកម្រិតសមត្ថភាពទេនោះ។

គោលបំណងដែលធ្វើការការពារជនដែលត្រូវបានកម្រិតសមត្ថភាពនេះ គឺដើម្បីការពារកុំឱ្យមានការខូចខាតដែលកើតឡើងដោយសារកិច្ចការជំនួញ របស់អ្នកដែលពុំមានសមត្ថភាពគ្រប់គ្រាន់ក្នុងការធ្វើសកម្មភាព។ ម៉្យាងវិញទៀត ទោះបីជាបុគ្គលដែលមិនមានសមត្ថភាពក្នុងការធ្វើសកម្មភាពនាពេលធ្វើសកម្មភាពនោះក៏ដោយ វាមានការលំបាកក្នុងការបញ្ជាក់ពីសមត្ថភាពនេះនៅពេលក្រោយ។ ជាលទ្ធផល វាមានភាពចាំបាច់ណាស់ក្នុងការចាត់ចំណាត់ថ្នាក់បុគ្គលដែលមិនមានសមត្ថភាពខាងឆន្ទៈ និងកម្រិតនូវសមត្ថភាពរបស់ពួកគាត់នៅក្នុងការធ្វើសកម្មភាព ដើម្បីការពារសិទ្ធិរបស់ពួកគាត់ និង ដើម្បីរក្សានូវស្ថិរភាពប្រតិបត្តិការជំនួញ។ ជាងនេះទៅទៀត បុគ្គលដែលមានសមត្ថភាពខាងឆន្ទៈហើយតែខ្វះសមត្ថភាពក្នុងការប្រឈមមុខជាមួយនឹងប្រព័ន្ធច្បាប់ និងផលប្រយោជន៍ស្មុគស្មាញត្រូវទទួលបានការការពារផងដែរ។ ការការពារជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពមានអត្ថប្រយោជន៍ ដើម្បីជួយសង្គមពីការប្រព្រឹត្តិនូវសកម្មភាពគតិយុត្តដែលធ្វើឱ្យខាតបង់ផលប្រយោជន៍ដល់គូភាគី ដែលមានមូលហេតុនៃការលុបចោលកិច្ចសន្យា និងការរំលោភបំពានលើស្ថានភាពជាក់ស្តែងរបស់ភាគីនៃកិច្ចសន្យាជាដើម។ ក្រមរដ្ឋប្បវេណីបានចាត់ថ្នាក់ជនដែលត្រូវបានកម្រិតសមត្ថភាពជាបីប្រភេទ ដើម្បីរក្សាតុល្យភាពរវាងការការពារជនដែលត្រូវបានកម្រិតសមត្ថភាព និងថែរក្សានូវស្ថេរភាពនៅក្នុងការប្រកបការកិច្ចការ។ ជនដែលត្រូវបានកម្រិតសមត្ថភាព រួមមាន៖

១. អនីតិជន ( ដូចមានបង្ហាញនៅក្នុងជំពូកទី១ )

២. ជននៅក្រោមអាណាព្យាបាលទូទៅ ( ដូចមានបង្ហាញនៅក្នុងជំពូកទី២ )

៣. ជននៅក្រោមហិតូបត្ថម្ភ ( ដូចមានបង្ហាញនៅក្នុងជំពូកទី៣ )

# ជំពូកទី ២
# អនីតិជន

# ជំពូកទី ២
# អនីតិជន

យោងតាមច្បាប់កម្ពុជាអនីតិជនសំដៅទៅលើជនដែលមានអាយុក្រោម ១៨ឆ្នាំ[10]។ ទារកដែលកើតចេញពីផ្ទៃម្តាយរហូតដល់អាយុក្រោម១៨ ឆ្នាំ ច្បាប់បានចាត់ទុកជនទាំងនោះថាមិនអាចពិចារណា និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនបាន។ មូលហេតុដែលច្បាប់ចែងបែបនេះពីព្រោះថាពួកគេនៅក្មេងខ្ចីនៅឡើយ។ នៅពេលដែលជនទាំងនោះនៅជាកុមារ ប្រាកដណាស់ថាពួកគេពិតជាមិនសូវមានស្មារតីគ្រប់គ្រាន់ដែលអាចគ្រប់គ្រងចាត់ចែង រក្សាការពារទ្រព្យសម្បត្តិរបស់ខ្លួនបាននោះទេ លុះត្រាតែពួកគេមានអាយុ ១៨ ឆ្នាំ ដែលច្បាប់បានចាត់ទុកថាពួកគេបានដល់នីតិភាព។ ម៉្យាងវិញទៀត ក្នុងករណីខ្លះ បុគ្គលដែលមានអាយុក្រោម១៨ឆ្នាំ អាចយល់ដឹង និងអាចចុះកិច្ចសន្យាដោយខ្លួនឯងបាន តែករណីខ្លះទៀតចុះកិច្ចសន្យាបានហើយ ប៉ុន្តែកិច្ចសន្យានោះមានសុពលភាពចាប់ពីពេលចុះកិច្ចសន្យារហូតដល់ពេលដែលអ្នកមានសិទ្ធិលុបចោល បានលុបចោលសកម្មភាពនោះ។ ទន្ទឹមនឹងនេះ បុគ្គលដែលអាយុក្រោម១៨ ឆ្នាំ មានកម្រិតនៃការយល់ដឹង ការដឹងខុស ដឹងត្រូវ គឺផ្សេងៗគ្នា ខុសប្លែកគ្នា ទៅតាមសង្គមជាក់ស្តែងដែលពួកគេរស់នៅ ហើយពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ទៀតមានកម្រិតនៃការយល់ដឹង ខុសៗគ្នា ផ្សេងៗពីគ្នា ហេតុនេះហើយ ទើបច្បាប់កម្រិតសមត្ថភាពនៅក្នុងការធ្វើសកម្មភាពរបស់ពួកគេ។

## ផ្នែកទី១៖ សកម្មភាពរបស់អនីតិជន

អនីតិជន ជាជនដែលមិនទាន់គ្រប់អាយុតាមច្បាប់កំណត់ ឬជនដែលមានអាយុក្រោម ១៨ឆ្នាំ។[11] នៅក្នុងសង្គមនីមួយៗ ការកំណត់អាយុរបស់អនីតិជន មានលក្ខណៈខុសៗគ្នាទៅតាមបរិបទរបស់សង្គមនៅក្នុងប្រទេសនីមួយៗ។ រីឯការកំណត់អាយុរបស់អនីតិជននៅក្នុងប្រទេសកម្ពុជាវិញ គឺបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណីថ្មី នៃព្រះរាជាណាចក្រកម្ពុជា។ អនីតិជនមិនមានសមត្ថភាព និងគ្រប់គ្រងទ្រព្យរបស់ខ្លួន និងត្រួតត្រាខ្លួនឯងដោយសេរីបានទេ[12]។ ជាធម្មតា អនីតិជនត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់ឪពុកម្តាយ ប៉ុន្តែប្រសិនបើគ្មានឪពុកម្តាយទេ ត្រូវគ្រប់គ្រងដោយអាណាព្យាបាលសម្រាប់អនីតិជន។

ចំពោះអនីតិជនដែលទទួលបានអត្តាធីនភាពត្រូវចាត់ទុកថាបានដល់នីតិភាព[13]។ សកម្មភាពដែលអនីតិជនបានធ្វើដោយមិនបានទទួលការយល់ព្រមពីអ្នកមានសិទ្ធិអំណាចមេបា ឬអាណាព្យាបាល ឬអ្នកអាណា

[10] មាត្រា១៧ នៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧

[11] សន្ធានុក្រមលេខ១៨៧ នៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៧

[12] មាត្រា៣៦៣ នៃក្រមរដ្ឋប្បវេណីកម្ពុជាចាស់ ឆ្នាំ១៩៦៧

[13] មាត្រា២២ នៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧

ព្យាបាលទូទៅសម្រាប់អនីតិជន អាចលុបចោលបាន។ មូលហេតុដែលកំណត់បែបនេះ គឺដើម្បីការពារផលប្រយោជន៍របស់អនីតិជនដូចបានបញ្ជាក់នៅក្នុង**ជំពូកទី ១ ផ្នែកទី៣ គោលគំនិតក្នុងការការពារជនដែលត្រូវបានកម្រិតសមត្ថភាពនៅក្នុងការធ្វើសកម្មភាព** ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះសកម្មភាពទទួលសិទ្ធិ ឬឱ្យរួចផុតពីកាតព្វកិច្ច ឬសកម្មភាពដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ។[14] ដោយហេតុសកម្មភាពទាំងនេះ អនីតិជនពុំមានការបាត់បង់នូវផលប្រយោជន៍របស់ខ្លួនឡើយ។ ម៉្យាងវិញទៀត សម្រាប់សមត្ថភាពទទួលសិទ្ធិ គឺច្បាប់មិនបានដកហូតសិទ្ធិបុគ្គលណាម្នាក់ឱ្យថ្លោះសិទ្ធិនោះទេ។

សរុបជារួមមក សកម្មភាពណាដែលធ្វើឱ្យអនីតិជនខាតប្រយោជន៍ សកម្មភាពនោះអាចលុបចោលបាន ដើម្បីការពារអនីតិជន។ ដើម្បីយល់កាន់តែច្បាស់អំពីសកម្មភាពណាដែលអនីតិជនអាចធ្វើបាន ឬធ្វើហើយមានមូលហេតុនៃការលុបចោល នាងខ្ញុំបានធ្វើការសម្រាយបញ្ជាក់នៅក្នុង**ចំណុច ១ សកម្មភាពដែលអនីតិជនបានធ្វើហើយមិនអាចលុបចោលបាន** និង**ចំណុច ២ សកម្មភាពដែលអនីតិជនបានធ្វើហើយអាចលុបចោលបាន** ដូចខាងក្រោម៖

## ១ សកម្មភាពដែលអនីតិជនបានធ្វើហើយមិនអាចលុបចោលបាន

ជាគោលការណ៍ សកម្មភាពដែលអនីតិជនបានធ្វើដោយគ្មានការយល់ព្រមពីអ្នកមានអំណាចមេបា[15] ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនអាចលុបចោលបាន[16]។ ប៉ុន្តែមានករណីមួយចំនួនដែលអនីតិជនអាចធ្វើសកម្មភាពបានដោយមិនចាំបាច់មានការយល់ព្រមពីអ្នកអាណាព្យាបាល។ សកម្មភាពទាំងនោះមានដូចជាសកម្មភាពទទួលសិទ្ធិ សកម្មភាពឱ្យរួចផុតពីកាតព្វកិច្ច សកម្មភាពដែលទាក់ទងនឹងជីវភាពប្រចាំថ្ងៃ ការចាត់ចែងទ្រព្យសម្បត្តិដែលអ្នកមានសិទ្ធិអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនអនុញ្ញាតឱ្យចាត់ចែង និងសកម្មភាពទាក់ទងនឹងអាជីវកម្ម ដែលអនីតិជនត្រូវបានអនុញ្ញាតឱ្យធ្វើដោយអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលជាដើម។

### ១.១ សកម្មភាពទទួលសិទ្ធិ

សកម្មភាពទទួលសិទ្ធិ បានមកពីពាក្យសកម្មភាព + ទទួល + សិទ្ធិ។ យោងតាមសន្ទានុក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានឱ្យនិយមន័យ ពាក្យ «សកម្មភាព» មានន័យថាជាការបង្ហាញឆន្ទៈ តាមរយៈកិច្ចសន្យា ឬសកម្មភាពជាឯកតោភាគី។ រីឯ ពាក្យ «ទទួល» គឺជាការព្រមតាម ព្រមយក ព្រមស្គាល់ ព្រមព្រៀងទទួលយក

[14] មាត្រា១៨ នៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧

[15] អំណាចមេបា គឺសំដៅដល់អ្នកដែលមានសិទ្ធិ និងករណីយកិច្ច ត្រូវបីបាច់ក្សាររូបកាយរបស់កូនដែលជាអនីតិជន និងគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូននោះ។

[16] មាត្រា១៨ នៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧

ទៅយករបស់អ្វីៗដែលគេហុចមក ឬឱ្យ។[17] ចំណែក ពាក្យ «សិទ្ធិ» គឺជាបុព្វសិទ្ធិ ដែលច្បាប់ទទួលស្គាល់ចំពោះបុគ្គល ដើម្បីប្រើប្រាស់ ជាប្រយោជន៍ផ្ទាល់ខ្លួន ព្រមទាំងទទួលបានការការពារពីច្បាប់។[18]

ដូចនេះ យើងអាចឱ្យនិយមន័យសកម្មភាពទទួលសិទ្ធិ គឺជាការបង្ហាញឆន្ទៈទទួលយកអ្វីមួយយកមកធ្វើជាប្រយោជន៍របស់ខ្លួន។ សកម្មភាពដែលទទួលសិទ្ធិ គឺមិនអាចលុបចោលបានឡើយ មានន័យថា សកម្មភាពដែលទទួលសិទ្ធិ គឺមានសុពលភាពពេញលេញ។ សកម្មភាពទទួលសិទ្ធិមានដូចជា ការទទួលយកប្រទានកម្ម ( អំណោយ ) ការទទួលសន្តតិកម្ម ជាអាទិ៍។

សកម្មភាពទទួលសិទ្ធិនេះ ពុំបានធ្វើឱ្យអនីតិជនបាត់បង់នូវផលប្រយោជន៍របស់ខ្លួននោះទេ ដូចនេះ គឺមិនអាចលុបចោលបានឡើយ ទោះបីជាអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនមិនយល់ព្រមក៏ដោយ។ ម៉្យាងវិញទៀត ចំពោះការទទួលនូវសន្តតិកម្មពីមតកជនជាសកម្មភាពឯកតោភាគី[19] ដែលមតកជនបានធ្វើចំពោះបុគ្គលណាម្នាក់ ប្រសិនបើមតកជន ធ្វើមតកសាសន៍ហើយប្រគល់មត៌កដល់អនីតិជន នោះអនីតិជននោះអាចទទួលនូវសិទ្ធិទទួលបានសន្តតិកម្មនេះបាន ព្រោះនេះជាសកម្មភាពទទួលសិទ្ធិ ហើយអនីតិជនអាចទទួលយកដោយមិនចាំបាច់មានការយល់ព្រមពីអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលឡើយ។ តាមរយៈសកម្មភាពឯកតោភាគីនេះផងដែរ វាគឺមិនចាំបាច់មានការយល់ព្រមពីភាគីម្ខាងទៀតនោះទេ។

### ១.២ សកម្មភាពឱ្យរួចផុតពីកាតព្វកិច្ច

យោងតាមវចនានុក្រមសម្តេចសង្ឃរាជជួនណាតបានឱ្យនិយមន័យ កាតព្វកិច្ច ដូចទៅនឹង ករណីកិច្ចដែរ គឺជាកិច្ចដែលគួរធ្វើការងារដែលត្រូវតែធ្វើ។ ចំណែកក្រមរដ្ឋប្បវេណីកម្ពុជាវិញបានឱ្យនិយមន័យកាតព្វកិច្ចជាចំណងតាមផ្លូវច្បាប់ដែលចងបុគ្គលពីរនាក់ ឬច្រើននាក់ដោយឱ្យបុគ្គលម្នាក់ដែលកំណត់ហៅថា «កូនបំណុល» មានករណីយកិច្ចមួយចំនួនចំពោះបុគ្គលម្នាក់ទៀតដែលបានកំណត់ហៅថា « ម្ចាស់បំណុល » ។[20]

សកម្មភាពឱ្យរួចផុតពីកាតព្វកិច្ចនេះ មិនខុសពីសកម្មភាពទទួលសិទ្ធិនោះទេ គឺមានសុពលភាពពេញលេញដូចគ្នា ព្រោះអនីតិជនពុំបានបាត់បង់នូវផលប្រយោជន៍អ្វីឡើយ ហើយសកម្មភាពដែលនាំឱ្យរួចផុត

[17] វចនានុក្រម សម្តេចសង្ឃ ជួន ណាត

[18] សាស្ត្រាចារ្យ ប៊ុច សីលា «ប្រភព ដើម និងការអភិវឌ្ឍន៍សិទ្ធិមនុស្ស» ឆ្នាំ២០១៨- ២០១៩

[19] មាត្រា៣១០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានឱ្យនិយមន័យ សកម្មភាពឯកតោភាគី គឺជាសកម្មភាពដែលបង្កើត កែប្រែ ឬរំលត់នូវកាតព្វកិច្ច ដោយបង្ហាញឆន្ទៈនៃការចាត់ចែងទ្រព្យដោយភាគីម្ខាង ឬ ដោយអនុវត្តសិទ្ធិ ដែលបានទទួលតាមកិច្ចសន្យា ឬ តាមបញ្ញត្តិនៃច្បាប់ ។

[20] សន្ទានុក្រមលេខ៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

កាតព្វកិច្ចនេះទៀតសោត ទោះបីជាមានការយល់ព្រម ឬមិនមានការយល់ព្រមពីអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនក៏ដោយ ក៏មិនអាចលុបចោលបានដែរ។

**ឧទាហរណ៍៖** សកម្មភាពរំលាយកិច្ចសន្យាបញ្ញើដោយមិនយកតម្លៃថ្នូរ ក្នុងនាមជាអ្នកទទួលបញ្ញើ ការចុះកិច្ចសន្យាដោយរួចផុតពីកាតព្វកិច្ចជាដើម។

### ១.៣ សកម្មភាពដែលទាក់ទងនឹងជីវភាពប្រចាំថ្ងៃ

ជីវភាពប្រចាំថ្ងៃ គឺជាភាពនៃការរស់នៅចិញ្ចឹមជីវិតជាប្រចាំ ជារៀងរាល់ថ្ងៃ។ សកម្មភាពដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ គឺជាសកម្មភាពពាក់ព័ន្ធនឹងជីវភាពរស់នៅរាល់ថ្ងៃ ដូចជាការទិញរបស់ប្រើប្រាស់ប្រចាំថ្ងៃជាដើម។[21] មូលហេតុដែលអនីតិជនអាចធ្វើសកម្មភាពទាក់ទងនឹងសកម្មភាពប្រចាំថ្ងៃដោយមិនចាំបាច់មានការយល់ព្រមពីអ្នកអាណាព្យាបាល ឬអ្នកមានអំណាចមេបា គឺដោយសារគោរពទៅលើសិទ្ធិស្វ័យសម្រេចរបស់អនីតិជន និងស្ថិរភាពនៃប្រតិបត្តិការជំនួញ ជាពិសេសនៅក្នុងករណីដែលជាប្រតិបត្តិការសាមញ្ញ និងសំខាន់។

ការទិញនំចំណីអាហារ សំលៀកបំពាក់សម្រាប់ប្រើប្រាស់ប្រចាំថ្ងៃជាដើម អនីតិជនអាចធ្វើតែម្នាក់ឯងបាន ដោយមិនចាំបាច់មានការអនុញ្ញាតឡើយ។ មូលហេតុដែលសកម្មភាពដែលទាក់ទងនឹងជីវភាពប្រចាំថ្ងៃមិនអាចលុបចោលបាន ព្រោះថាសកម្មភាពដែលទាក់ទងនឹងជីវភាពប្រចាំថ្ងៃជាសកម្មភាពមួយដែលមានភាពងាយស្រួលក្នុងការវិនិច្ឆ័យ ជាទូទៅមានតម្លៃទឹកប្រាក់ទាប ដែលមិនមានការព្រួយបារម្ភអំពីការខូចខាតផលប្រយោជន៍របស់អនីតិជនឡើយ។ ការធ្វើបែបនេះ គឺអាចធ្វើឱ្យអនីតិជនមានភាពងាយស្រួលក្នុងការធ្វើសកម្មភាពម្នាក់ឯងបានដើម្បីបម្រើជីវភាពប្រចាំថ្ងៃ។ ម៉្យាងវិញទៀតប្រសិនបើយើងអនុញ្ញាតឱ្យលុបចោលនូវសកម្មភាពប្រភេទនេះ ទោះបីជាអ្នកនៅក្រោមអាណាព្យាបាលមានសមត្ថភាពខាងឆន្ទៈឡើងវិញ ហើយមានបំណងធ្វើសកម្មភាពពាក់ព័ន្ធនឹងជីវភាពរស់នៅរាល់ថ្ងៃក៏ដោយ ក៏ភាគីម្ខាងទៀត នៃសកម្មភាពនោះបារម្ភថាសកម្មភាពនោះនឹងត្រូវបានលុបចោលវិញ ហើយមិនធ្វើកិច្ចការជួញដូរជាមួយ ដែលធ្វើឱ្យមានការលំបាក។ ម្យ៉ាងទៀត មានភាពចាំបាច់ត្រូវគិតដល់សុវត្ថិភាពនៃកិច្ចការជួញដូររបស់ ភាគីម្ខាងទៀតនៃកិច្ចការជួញដូរពាក់ព័ន្ធនឹងជីវភាពរស់នៅប្រចាំថ្ងៃ។

**ឧទាហរណ៍៖** ការទិញម្ហូបអាហារ ឬសំលៀកបំពាក់ ការបង់ទឹកភ្លើងក៏ត្រូវបានចាត់ទុកថាជាសកម្មភាពដែលទាក់ទងនឹងជីវភាពប្រចាំថ្ងៃដែរព្រោះ វាមានលក្ខណៈសំខាន់ណាស់ក្នុងការសម្រេចថា តើសកម្មភាពណាគឺជាសកម្មភាពដែលទាក់ទងសកម្មភាពប្រចាំថ្ងៃ ដោយធ្វើការពិចារណាទៅលើលក្ខខណ្ឌជាច្រើនផ្សេងទៀត ដូចជា អាយុ របស់អនីតិជន តម្លៃ ឬប្រភេទនៃកិច្ចការនោះ ជាអាទិ៍ ។

[21] សេចក្តីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

## ១.៤ ការចាត់ចែងទ្រព្យសម្បត្តិដែលទទួលបានការអនុញ្ញាតឱ្យចាត់ចែង

យោងតាមវចនានុក្រម សម្តេចសង្ឃ ជួន ណាត បានឱ្យនិយមន័យ ចាត់ចែងថា ជាការរៀបចំធ្វើ ចាត់ការ ដាក់មុខឱ្យដោយឡែកៗ ចាត់ការតាមមុខតាមប៉ែក ដោយសេចក្តីខ្នះខ្នែងដូចជាការចាត់ចែងភាគហ៊ុន ការចាត់ចែងប្រាក់ចំណេញជាដើម។ ចំណែកទ្រព្យសម្បត្តិ ជាទ្រព្យគ្រប់ប្រភេទ ចលនទ្រព្យ ឬអចលនទ្រព្យ ទ្រព្យរូបិយ ឬទ្រព្យអរូបិយ និងឯកសារឧបករណ៍គតិយុត្ត ដែលជាភស្តុតាងនៃកម្មសិទ្ធិ ឬអត្ថប្រយោជន៍លើទ្រព្យទាំងនេះ[22] ឬអាចឱ្យនិយមន័យម៉្យាងទៀតថាជាសិទ្ធិ និងផលប្រយោជន៍ដែលមនុស្សណាម្នាក់មាននៅក្នុងអ្វីដែលស្ថិតនៅក្រោមកម្មសិទ្ធិនោះ។

អំណាចមេបា គឺជាចំណងគតិយុត្តរវាងឪពុកម្តាយ និងកូនជាអនីតិជន ដែលចងភ្ជាប់សិទ្ធិ និងកាតព្វកិច្ចរបស់ឪពុកម្តាយ ចំពោះកូនជាអនីតិជន ក្នុងការអប់រំ ចិញ្ចឹមបីបាច់ថែរក្សា និងគ្រប់គ្រងកូន។ ប៉ុន្តែក្នុងករណីមួយចំនួនដែលឪពុកម្តាយបានប្រើប្រាស់សិទ្ធិអំណាចមេបានោះហួសហេតុ ឬករណីដើម្បីការពារផលប្រយោជន៍របស់កូន សិទ្ធិអំណាចមេបានេះអាចត្រូវព្យួរ ឬដកហូតបាន។[23] អ្នកអាណាព្យាបាលសម្រាប់អនីតិជន គឺជារបបមួយការពារអនីតិជន (អាយុក្រោម១៨ឆ្នាំ) ក្នុងករណីដែលអនីតិជននោះ គ្មានអ្នកអនុវត្តអំណាចមេបា។

អនីតិជនអាចចាត់ចែងទ្រព្យសម្បត្តិដែលអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនបានអនុញ្ញាតឱ្យចាត់ចែងដោយកំណត់គោលបំណង ក្នុងទំហំនៃគោលបំណងនោះបាន។ ម៉្យាងវិញទៀតអនីតិ-ជន ក៏អាចចាត់ចែងទ្រព្យសម្បត្តិដែលអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនបានអនុ-ញ្ញាត។ ដូចគ្នានេះដែលអ្នកមានអំណាចមេបា និងអ្នកអាណាព្យាបាលសម្រាប់អនីតិជន ក៏អាចអនុញ្ញាតឱ្យអនីតិជនចាត់ចែងទ្រព្យសម្បត្តិដែលមិនបានកំណត់គោលបំណងបានដូចគ្នា។ ក្នុងករណីដែលអ្នកមានសិទ្ធិអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន បានផ្តល់ទ្រព្យសម្បត្តិ ដូចជាប្រាក់ ជាដើម ដល់អនីតិជនដោយបានកំណត់គោលដៅប្រើប្រាស់ ឬសម្រាប់ចាយវាយ កំប៉ិកកំប៉ុក ដោយមិនបានកំណត់គោលដៅប្រើប្រាស់ ទោះជាអនីតិជនក៏ដោយ ក៏អាចធ្វើកិច្ចសន្យាសុពលពេញលេញបានដែរ ប្រសិនបើកិច្ចសន្យានោះស្ថិតនៅក្នុងទំហំដែលអាចបង់តម្លៃបានដោយប្រាក់ ជាដើម ដែលបានផ្តល់នោះ។[24]

ទោះបីជាមានការទទួលស្គាល់ឱ្យអនីតិជនចាត់ចែងម្នាក់ឯងក៏ដោយ ក៏នៅតែមានការព្រួយបារម្ភអំពីការបាត់បង់ផលប្រយោជន៍ចំពោះអនីតិជនដដែល ប៉ុន្តែប្រសិនបើអនីតិជនមិនអាចចាត់ចែងត្រឹមកម្រិតប៉ុណ្ណឹងបាននោះទេ វានឹងធ្វើឱ្យមានផលលំបាកដល់អនីតិជននោះ។ ដូចនេះហើយទើបច្បាប់ បានអនុញ្ញាតឱ្យអនីតិជនអាច

[22] ច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម

[23] https://freshnewsasia.com/index.php/en/localnews/178933-2020-12-06-05-53-09.html

[24] [24] សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី

ចាត់ចែងបានមួយកម្រិត ដើម្បីធ្វើឱ្យអនីតិជនមានភាពងាយស្រួលក្នុងការចាត់ចែង ហើយនឹងអាចឱ្យអនីតិជនមានភាពស៊ាំជាមុន មុននឹងពេលឈានទៅដល់នីតិភាព នោះនីតិជននោះអាចចាត់ចែងបានខ្លួនឯងតែម្តង។

## ១.៥ សកម្មភាពទាក់ទងនឹងអាជីវកម្ម ដែលទទួលបានការអនុញ្ញាតឱ្យធ្វើ

អ្នកអាណាព្យាបាល គឺជាអ្នកគ្រប់គ្រងបីបាច់ថែរក្សាទ្រព្យសម្បត្តិ រូបកាយរបស់អនីតិជនដែលគ្មានអ្នកអនុវត្តអំណាចមេបា ឬរបស់អសមត្ថជន។ អ្នកអាណាព្យាបាល ស្ថិតនៅក្នុងន័យពីរគឺអាណាព្យាបាលសម្រាប់អនីតិជន និងអាណាព្យាបាលទូទៅ។ ចំណែក អាជីវកម្ម សំដៅទៅដល់សកម្មភាពសេដ្ឋកិច្ចរបស់បុគ្គលក្នុងគោលដៅ ផលិត និងលក់ទំនិញ ផ្គត់ផ្គង់សេវា ភតិសន្យាជួល ឬលក់ទ្រព្យសម្បត្តិ ឬសកម្មភាពផ្សេងទៀត រួមទាំងសកម្មភាពរបស់ស្ថាប័ន ឬអង្គការនានា។[25]

អនីតិជនដែលទទួលបានការអនុញ្ញាតឱ្យប្រកបអាជីវកម្មមួយប្រភេទ ឬច្រើនប្រភេទ ពីអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន ត្រូវមានសមត្ថភាពដូចនីតិជន ចំពោះមុខជំនួញនោះបាន[26]។ បញ្ញត្តិនេះ បានអនុញ្ញាតឱ្យអនីតិជនអាចធ្វើអាជីវកម្មបាន ប្រសិនបើមានការទទួលស្គាល់ពីអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន ក្រោយពីទទួលបានការយល់ព្រមហើយ អនីតិជននឹងមានភាពឯករាជ្យចំពោះប្រតិបត្តិការក្នុងការប្រកបអាជីវកម្មដូចនីតិជនដែរ។ ដូចជា ក្នុងករណីដែលអនីតិជនបានប្រកបនូវអាជីវកម្មណាមួយដូចជា ការលក់បន្លែ នោះការនាំចូលបន្លែ ក៏ត្រូវចាំបាច់មានការយល់ព្រមពីឪពុកម្តាយជាមុនសិន ចំណែកការលក់បន្លែដល់អតិថិជនវិញ ក៏ត្រូវចាំបាច់ឱ្យឪពុកម្តាយផ្តល់ការយល់ព្រមនូវអាជីវកម្មនោះផងដែរ។ ដូច្នេះ យើងមើលឃើញថាអាជីវកម្មនោះពុំអាចប្រព្រឹត្តទៅបានយ៉ាងរលូននោះឡើយ។ ដោយហេតុបែបនេះហើយទើបច្បាប់បានអនុញ្ញាតឱ្យអនីតិជនដែលបានទទួលការអនុញ្ញាតឱ្យប្រកបអាជីវកម្ម មានសមត្ថភាពដូចនីតិជន ចំពោះកិច្ចការជំនួញបាន ដោយសារមានគោលបំណងសម្របសម្រួលទៅដល់ប្រតិបត្តិការជំនួញរបស់អនីតិជន ព្រោះថាបើគ្រប់ប្រតិបត្តិការទាំងអស់ មុននឹងអាចដំណើរការបាន លុះត្រាតែមានការយល់ព្រមពីសំណាក់អ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជននោះសិន នោះការប្រកបអាជីវកម្មនេះអាចនឹងមានសភាពយឺតយ៉ាវ ឬរាំងស្ទះ ជួនកាលអាចធ្វើឱ្យខាតប្រយោជន៍ដល់អាជីវកម្ម ថែមទាំងអាចធ្វើឱ្យអាជីវកម្មនេះខាតបង់ មិនដំណើរការទៅមុខ ហើយហាក់បីដូចមិនសូវមានន័យថែមទៀតផង។

បន្ថែមពីលើនេះ ប្រសិនបើអនីតិជនដែលត្រូវបានអនុញ្ញាតឱ្យប្រកបអាជីវកម្មហើយ បែរជាយកដើមទុនសម្រាប់ រកទទួលទានទៅលេងល្បែងស៊ីសង ឬទិញតែទំនិញដែលលក់មិនដាច់ជាដើម ដែលខុសពីអ្វីដែលអ្នក

[25] មាត្រា ១០ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧

[26] មាត្រា២០ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧

មានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនគិតនោះ អ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាល សម្រាប់អនីតិជនអាចធ្វើការលុបចោល ឬកម្រិតនូវការអនុញ្ញាតដែលខ្លួនបានផ្តល់រួចហើយនោះបាន។ ប៉ុន្តែក្នុងករណីគ្រាន់តែការផ្លាស់ប្តូរគំនិតរបស់អ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជននោះទេ ការលុបចោល ឬការកម្រិតការអនុញ្ញាតមិនអាចប្រព្រឹត្តបានឡើយ។ ប្រសិនបើ អនីតិជនដែលត្រូវបានអនុញ្ញាតឱ្យប្រកបអាជីវកម្ម លុបចោលនូវការអនុញ្ញាតឱ្យមានសមត្ថភាពក្នុងការធ្វើសកម្មភាពរបស់អនីតិជនខ្លួនឯង នោះគឺត្រូវត្រលប់ទៅដូចស្ថានភាពដើមវិញ គឺមានន័យថាដូចអនីតិជនធម្មតា។

## ២. សកម្មភាពដែលអនីតិជនបានធ្វើហើយអាចលុបចោលបាន

ការលុបចោល គឺជារបបមួយសម្រាប់ការពារភាគីដែលរងគ្រោះ។ សកម្មភាពដែលអាចលុបចោលបានមានសុពលភាពរហូតដល់ពេលដែលអ្នកមានសិទ្ធិលុបចោល បានលុបចោលសកម្មភាពដែលអាចលុបចោលនោះ។ ប៉ុន្តែក្នុងករណីដែលអ្នកដែលមានសិទ្ធិលុបចោល បានលុបចោលសកម្មភាពដែលអាចលុបចោលបានសកម្មភាពនោះ ត្រូវចាត់ទុកជាមោឃៈតាំងពីដំបូង។[27]

ជាគោលការណ៍ អនីតិជនមិនអាចធ្វើសកម្មភាពគតិយុត្តដោយឯករាជ្យបានទេ សកម្មភាពដែលបានធ្វើឡើងដោយឯករាជ្យអាចត្រូវបានលុបចោលបាន[28]។ ដើម្បីឱ្យអនីតិជនអាចធ្វើសកម្មភាពគតិយុត្តបាន ចាំបាច់ត្រូវធ្វើសកម្មភាពតាមរយៈអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអនីតិជនខ្លួនឯងអាចធ្វើសកម្មភាពគតិយុត្តបាន ក្រោយពីទទួលបានការយល់ព្រមពីអ្នកតំណាងដែលច្បាប់បានកំណត់។ សកម្មភាពដែលអនីតិជនបានធ្វើ ហើយអាចលុបចោលបានមានដូចជា សកម្មភាពទាក់ទងនឹងកិច្ចសន្យា សកម្មភាពទាក់ទងនឹងបណ្តឹង និងសកម្មភាពទាក់ទងនឹងការធ្វើមតកសាសន៍ជាអាទិ៍។

### ២.១ សកម្មភាពទាក់ទងនឹងការបង្កើតកិច្ចសន្យា

កិច្ចសន្យាគឺជាកិរិយាដែលបុគ្គលពីរនាក់ ឬច្រើននាក់មានឆន្ទៈត្រូវគ្នាព្រមបង្កើត កែប្រែ ឬរលត់នូវកាតព្វកិច្ច។[29] កិច្ចសន្យា មានច្រើនប្រភេទ ដូចជា កិច្ចសន្យាម៉ៅការ កិច្ចសន្យាប្រវាស់ ភតិសន្យា ( កិច្ចសន្យាជួល ) កិច្ចសន្យាបញ្ញើ កិច្ចសន្យាមជ្ឈត្តកម្ម កិច្ចសន្យាការងារជាដើម។

សមត្ថភាពរបស់ភាគីនៃកិច្ចសន្យា គឺជាលក្ខខណ្ឌចាំបាច់មួយដែលទាមទារនៅពេលបង្កើតកិច្ចសន្យា ការកំណត់បែបនេះក្នុងគោលដៅដើម្បីការពារផលប្រយោជន៍ភាគីនៃកិច្ចសន្យា ជៀសវាងការបំពានផ្សេងៗ និងការ

[27] មាត្រា ៣៥៨ នៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧

[28] មាត្រា ៥ នៃក្រមរដ្ឋប្បវេណីជប៉ុន

[29] មាត្រា ៣១១ នៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧

កេងប្រវ័ញ្ចដោយប្រការណាមួយ ហេតុដូចនេះ សមត្ថភាពក្នុងការត្រិះរិះពិចារណា និងការបង្ហាញឆន្ទៈរបស់បុគ្គល ជាធាតុសំខាន់មួយដែលច្បាប់តម្រូវនៅពេលបង្កើតកិច្ចសន្យា។[30] ជាទូទៅ សមត្ថភាពរបស់គូភាគីនៃកិច្ចសន្យា ស្របតាមខ្លឹមសារនៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧ សំដៅទៅលើបុគ្គល ដែលមានសមត្ថភាពតាមផ្លូវច្បាប់។

ជាគោលការណ៍ច្បាប់បានបញ្ញត្តិថា មានតែនីតិជនទេដែលមានសមត្ថភាពចុះកិច្ចសន្យា។ ក្នុងករណីនេះក៏មានអញ្ញត្តិកម្មផងដែរ ដែលអនីតិជនដែលឪពុកម្ដាយបានព្រមព្រៀង រឺយល់ព្រមឱ្យប្រកបអាជីវកម្មហើយនោះគឺ អាចធ្វើកិច្ចសន្យាទៅតាមអ្វីដែលកម្រិតបាន។ ដូចនេះហើយ ក្រោយពីមានការយល់ព្រម អនីតិជនអាចនឹងមានសមត្ថភាពធ្វើសកម្មភាពក្នុងការធ្វើកិច្ចសន្យាជាចាំបាច់សម្រាប់អាជីវកម្មនោះ។ ពោលគឺមានសិទ្ធិក្នុងការធ្វើកិច្ចសន្យាចាំបាច់ផ្សេងៗ សម្រាប់អាជីវកម្ម ប៉ុន្តែអនីតិជននោះពុំមានសមត្ថភាពបង្កើតកិច្ចសន្យាណាផ្សេងដែលអាចធ្វើអោយហួសពីទំហំ នៃភាពចាំបាច់សម្រាប់អាជីវកម្មរបស់ខ្លួនឡើយ។ ការប្រព្រឹត្តទៅបាន លុះត្រាតែមានការយល់ព្រមពីសំណាក់ អ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន ដោយគោរពទៅតាមបញ្ញត្តិដែលបានចែងនៅក្នុងច្បាប់។

### ២.២ សកម្មភាពបណ្ដឹង

បណ្ដឹង គឺជាសកម្មភាពទាមទារមួយ (ពាក្យសុំ ឬពាក្យបណ្ដឹង) ដែលដើមចោទបានធ្វើឡើងចំពោះចុងចម្លើយទៅតុលាការ នៃការជំនុំជម្រះលើកទី១ ដែលត្រូវបានកំណត់ដោយបានលើកឡើងនូវការអះអាងអំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្ត តាមផ្លូវច្បាប់នៃនីតិឯកជនកំណត់មួយ ហើយទាមទារឱ្យតុលាការចេញសាលក្រម ដែលមានខ្លឹមសារកំណត់មួយ ដោយផ្អែកលើការអះអាងទាំងនេះ ហើយជាគោលការណ៍ សកម្មភាពនៃបណ្ដឹង ត្រូវធ្វើឡើងតាមវិធីនៃការដាក់ពាក្យបណ្ដឹង។[31]

**ឧទាហរណ៍៖** A ជាដើមចោទបានធ្វើបណ្ដឹងទាមទារចំពោះ B ជាចុងចម្លើយទៅសាលាដំបូងខេត្តកណ្ដាល ដោយទាមទារឱ្យ B សងប្រាក់ ២០ លានរៀល ដោយផ្អែកទៅលើកិច្ចសន្យាខ្ចីបរិភោគ ដែលបានបង្កើតឡើងនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩។

ការកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពបណ្ដឹង ត្រូវបានធ្វើឡើងចំពោះបុគ្គលដែលត្រូវបានកម្រិតសមត្ថភាពតាមច្បាប់សារធាតុ ដូចជា អនីតិជន ជននៅក្រោមអាណាព្យាបាលទូទៅ ឬជននៅក្រោមហិតូបត្ថម្ភ។ ការកំណត់បែបនេះ មិនមែនមានន័យថា ជនទាំងនោះមិនមានសិទ្ធិក្នុងការធ្វើបណ្ដឹង ឬត្រូវបានគេប្ដឹងនោះទេ

[30] ដកស្រង់ចេញពីសៀវភៅនីតិកិច្ចសន្យាពិសេសភាគ១ របស់លោកស្រី ប៉ូលី បញ្ញា និងលោក ព្រុំ វិទ្ធី បោះពុម្ពលើកទី១ ឆ្នាំ២០២១

[31] មេរៀន ការតាក់តែងបណ្ដឹងរដ្ឋប្បវេណី ឧទ្ទេសនាមដោយ៖ លោក **វ៉ាន់ សុបញ្ញា** ចៅក្រមសាលាដំបូងខេត្តកណ្ដាល

ប៉ុន្តែមិនអាចធ្វើសកម្មភាពតាមផ្លូវតុលាការដោយឯករាជ្យគ្រប់ជ្រុងជ្រោយ គឺតម្រូវឱ្យមានអ្នកតំណាងទៅតាមស្ថានភាពជាក់ស្តែង ដែលត្រូវបានកំណត់ជាមុននៅក្នុងច្បាប់។

សកម្មភាពដែលអនីតិជនធ្វើត្រូវបានកម្រិត ដោយត្រូវការបង្ហាញឆន្ទៈរបស់អ្នកមានអំណាចមេបាសម្រាប់សកម្មភាពបណ្តឹងតាមផ្លូវតុលាការ។[32]

**២.៣ សកម្មភាពទាក់ទងនឹងការធ្វើមតកសាសន៍**

មតកសាសន៍ គឺជាលិខិតបណ្តាំដែលបុគ្គលម្នាក់បានធ្វើឡើងតាមទម្រង់ ដែលកំណត់ដោយច្បាប់ ដើម្បីសំដែងឆន្ទៈចុងក្រោយ អំពីការចាត់ចែងទ្រព្យសម្បត្តិរបស់ខ្លួនជាអាទិ៍ បន្ទាប់ពីមរណភាព។[33] ចំណែកសន្តតិកម្មវិញ គឺជាការផ្ទេរនូវសិទ្ធិ និងករណីយកិច្ចរបស់មតកជនទៅឱ្យសន្តតិជនម្នាក់ ឬច្រើននាក់តាមឆន្ទៈ ឬតាមច្បាប់។[34] យោងតាមមាត្រា ១១៦៨ នៃក្រមរដ្ឋប្បវេណីកម្ពុជា បុគ្គលដែលអាចធ្វើមតកសាសន៍បាន គឺជាបុគ្គលដែលជានីតិជន និងអនីតិជនដែលទទួលបានអត្តាធីនភាព ហើយរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន ឬអំណាចមេបា។

ដូចនេះអនីតិជន មិនអាចធ្វើសន្តតិកម្មបានទេ មានតែបុគ្គលដែលជានីតិជនប៉ុណ្ណោះទើបអាចធ្វើមតកសាសន៍បាន។ ម៉្យាងវិញទៀត ការធ្វើមតកសាសន៍ គឺជាសកម្មភាពឯកតោភាគី ហើយអនីតិជន គឺជាជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពដែលមិនទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ បើពុំដូច្នេះទេនឹងក្លាយជាមូលហេតុនៃការលុបចោល។ នៅក្នុងករណីខ្លះអនីតិជនក៏អាចជៀសផុតពីការកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពបានផងដែរ នៅពេលដែលអនីតិជននោះទទួលបាន**អត្តាធីនភាពដូចមានបញ្ជាក់នៅក្នុងជំពូកទី២ ផ្នែកទី៣ ចំណុចទី៣ អត្តាធីនភាព។**

## ផ្នែកទី២៖ នីតិវិធីនៃការលុបចោល

សកម្មភាពរបស់អនីតិជនក្រោមរូបភាពជាកិច្ចសន្យា ឬសកម្មភាពឯកតោភាគីដែលត្រូវបានលុបចោល គឺមិនមានការខូចខាតផលប្រយោជន៍ណាមួយទៅលើអនីតិជននោះទេ។ សកម្មភាពដែលអាចលុបចោលបានមានសុពលភាពរហូតដល់ពេលដែលអ្នកមានសិទ្ធិលុបចោល លុបចោលសកម្មភាពនោះ។ ដើម្បីលុបចោលសកម្មភាពរបស់អនីតិជនបានត្រូវគោរពនៅលក្ខខណ្ឌមួយចំនួនដូចតទៅ៖

[32] មេរៀនក្រមនីតិវិធីរដ្ឋប្បវេណី ប្រធានបទ ភាគី និងអ្នកតំណាងតាមផ្លូវបណ្តឹងឧទ្ធរណ៍សនាមដោយលោកមេធាវី អ៊ុំ ប៉ូលី នៅក្នុងវគ្គបណ្តុះបណ្តាលជំនាន់ទី៧ នៃវិភាគទានច្បាប់

[33] សន្ធានុក្រមលេខ១១៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[34] សន្ធានុក្រមលេខ១៤៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

## ១. លក្ខខណ្ឌ

### ១.១ សកម្មភាពដែលអាចលុបចោលបាន

គ្រប់សកម្មភាពទាំងអស់ដែលអនីតិជនបានធ្វើ ដោយមិនទទួលបានការអនុញ្ញាត ឬយល់ព្រមពីអ្នកមានសិទ្ធិអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនអាចលុបចោលសកម្មភាពនោះបាន លើកលែងតែសកម្មភាពទទួលសិទ្ធិ សកម្មភាពឱ្យរួចផុតពីកាតព្វកិច្ច និងសកម្មភាពទាក់ទងនឹងជីវភាពប្រចាំថ្ងៃ ដើម្បីការពារផលប្រយោជន៍របស់អនីតិជននោះ។

ជាគោលការណ៍ គេអាចលុបចោលនូវសកម្មភាពដែលធ្វើឡើងដោយអនីតិជន ដោយគ្មានការយល់ព្រមពីអ្នកមានសិទ្ធិអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ ប៉ុន្តែមានករណីពិសេសខ្លះៗ ដែលទទួលស្គាល់នូវការធ្វើកិច្ចសន្យាដោយមានសុពលភាពពេញលេញរបស់អនីតិជន ដូចជា សកម្មភាពចាត់ចែងទ្រព្យសម្បត្តិដែលអ្នកមានសិទ្ធិអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនបានអនុញ្ញាតឱ្យចាត់ចែង និងអនីតិជនដែលត្រូវបានអនុញ្ញាតឱ្យប្រកបអាជីវកម្ម។

### ១.២ បុគ្គលដែលមានសិទ្ធិលុបចោល

ជនដែលត្រូវបានកម្រិតសមត្ថភាពដែលមានដូចជាអនីតិជនជាដើម អាចអនុវត្តនូវសិទ្ធិលុបចោលដោយឯករាជ្យបាន ប៉ុន្តែក្រោយពីបានអនុវត្តសិទ្ធិលុបចោលហើយ ជននោះមិនអាចលុបចោលនូវសិទ្ធិលុបចោលនោះបានឡើយ។ ក្នុងករណីនៃសកម្មភាពដែលអាចលុបចោលបាន មានតែអ្នកមានសិទ្ធិលុបចោលប៉ុណ្ណោះទើបអាចលុបចោលទៅលើសកម្មភាពនោះ។

សកម្មភាពដែលអាចលុបចោលបាន មានសុពលភាពរហូតដល់ពេលដែលអ្នកមានសិទ្ធិលុបចោល លុបចោលសកម្មភាពនោះ។ អ្នកដែលអាចលុបចោលសកម្មភាពបានរួមមាន សាមីខ្លួន ( អនីតិជន ) អ្នកមានសិទ្ធិអំណាចមេបា (ឪពុក ឬម្ដាយ) និងអ្នកអាណាព្យាបាលសម្រាប់អនីតិជនដែលជាអ្នកតំណាងដែលច្បាប់បានកំណត់ប៉ុណ្ណោះ។

### ១.៣ រយៈពេលដែលអាចលុបចោល

ប្រសិនបើអ្នកមានសិទ្ធិលុបចោលមិនអនុវត្តសិទ្ធិលុបចោលក្នុងរយៈពេល ៣ឆ្នាំ ចាប់តាំងពីពេលដែលខ្លួនក្លាយទៅជាអ្នកដែលអាចផ្តល់សច្ចានុមតិ ឬអ្នកដែលមានសិទ្ធិលុបចោលនោះ សិទ្ធិលុបចោលនឹងត្រូវរលត់។ តែប្រសិនបើហួសអំឡុងពេល ១០ឆ្នាំ ចាប់តាំងពីកាលបរិច្ឆេទនៃសកម្មភាពបានប្រព្រឹត្តិ នោះសិទ្ធិលុបចោលក៏ត្រូវរលត់ផងដែរ។[35]

[35] មាត្រា ៣៦៣ នៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧

ច្បាប់បានកំណត់រយៈពេលនៃការរលត់សិទ្ធិលុបចោលនេះ ដើម្បីទុកពេលឱ្យអ្នកមានសិទ្ធិលុបចោល ឬអ្នកដែលអាចផ្តល់សច្ចានុមតិ ពិចារណាអំពីសកម្មភាពទាំងនោះ។ គួរបញ្ជាក់ថា ក្រោយពេលអាជ្ញាយុកាលត្រូវបានរលត់ ជនដែលមានសិទ្ធិលុបចោលមិនអាចលុបចោលសកម្មភាពដែលអាចលុបចោលនោះទៀតបានទេ ដូច្នេះសកម្មភាព នោះត្រូវបានចាត់ទុកថាមានសុពលភាពជាស្ថាពរ។[36]

## ២. នីតិវិធីនៃការបង្ហាញឆន្ទៈលុបចោល

ក្នុងករណីដែលសកម្មភាពអាចលុបចោលបាន អ្នកមានសិទ្ធិលុបចោលអាចលុបចោលសកម្មភាពនោះដោយគ្រាន់តែបង្ហាញឆន្ទៈ[37]ថាលុបចោលតែប៉ុណ្ណោះ។ ការបង្ហាញឆន្ទៈនេះ ត្រូវធ្វើឡើងដោយការជូនដំណឹងទៅភាគីម្ខាងទៀត ហើយអានុភាពនៃការលុបចោល ត្រូវកើតឡើងនៅពេលដែលដំណឹងនោះបានដល់ភាគីម្ខាងទៀត។ ការជូនដំណឹងអាចធ្វើទៅបានតាមរយៈប្រាប់ទៅភាគីម្ខាងទៀតផ្ទាល់ ឬផ្ញើសារ គឺធ្វើយ៉ាងណាឱ្យដំណឹងនោះបានដល់ភាគីម្ខាងទៀត ហើយអានុភាពនៃការលុបចោលនេះ ត្រូវកើតឡើងភ្លាមៗ បន្ទាប់ពីភាគីម្ខាងទៀតបានទទួលដំណឹងអំពីការលុបចោលនេះ។

## ៣. អានុភាព

អានុភាព គឺជាអ្វីដែលនឹងត្រូវកើតមានឡើងបន្ទាប់ពីពេលដែលបានបំពេញចប់រួចរាល់ទៅតាមលក្ខខណ្ឌចាំបាច់ទាំងឡាយ និងបានអនុវត្តតាមច្បាប់បញ្ញត្តិហើយ។[38] ការលុបចោលជាសកម្មភាពឯកតោភាគី ដូច្នេះការលុបចោលត្រូវមានអានុភាពនៅពេលដែលការជូនដំណឹងពីការលុបចោលនោះបានដល់ភាគីម្ខាងទៀត។[39] ក្នុងករណីដែលអ្នកមានសិទ្ធិលុបចោល បានលុបចោលសកម្មភាពដែលអាចលុបចោលបាន សកម្មភាពនេះត្រូវចាត់ទុកជាមោឃៈតាំងពីដំបូង។[40] ឬនៅក្នុងន័យម៉្យាងទៀត សកម្មភាព គឺមានសុពលភាពទោះបីជាសកម្មភាពនោះអាចត្រូវបានគេលុបចោលក៏ដោយ ហើយការលុបចោលគឺជាការបង្ហាញឆន្ទៈ ក្នុងការបដិសេធនូវអានុភាពនោះ។[41] ការលុបចោលកិច្ចសន្យា មានអានុភាពធ្វើឱ្យភាគីទាំងសងខាង ត្រូវបានរួចផុតពីកាតព្វកិច្ចក្នុងកិច្ចសន្យា ហើយមានអានុភាពជាឯកតោភាគី ដោយសារវាជាសកម្មភាពឯកតោភាគី។

---

[36] សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ដែលរៀបចំដោយក្រុមការងារនៃអនាគតគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ

[37] បង្ហាញឆន្ទៈ គឺជាការបង្ហាញឆន្ទៈរបស់ភាគីដែលមានបំណងបង្កើត នូវអានុភាពគតិយុត្តិហៅថាការបង្ហាញឆន្ទៈ និងការបង្ហាញឆន្ទៈមានអានុភាពនៅពេលដំណឹងនៃការបង្ហាញឆន្ទៈបានដល់ភាគីម្ខាងទៀត។

[38] សៀវភៅណែនាំសិក្សា ក្រមរដ្ឋប្បវេណី ដែលនិពន្ធដោយ អ៊ីកិដា ម៉ាសាអូ

[39] សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី

[40] កថាខណ្ឌទី២ មាត្រា៣៥៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[41] សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី

ពេលដែលសកម្មភាពត្រូវបានលុបចោល ភាគីម្ខាងទៀតត្រូវបដិទានត្រឡប់មកវិញនៅរបស់ ឬវត្ថុដែលជាកម្មវត្ថុនៃសកម្មភាពនោះ ក្នុងករណីមានការខូចខាត ភាគីម្ខាងទៀតត្រូវសងសំណងនៃការខូចខាតនោះ ធ្វើយ៉ាងណា ឱ្យថ្លៃសំណងនោះសមរម្យអាចទទួលយកបាន។

ឧទាហរណ៍ : ក ដែលជាអនីតិជនបានលក់រថយន្តទៅឱ្យ ខ ជានីតិជន ក្នុងតម្លៃ ២០០០ $ ។ ពេល គ ដែលជាម្តាយរបស់ ក បានដឹងក៏ទាមទារលុបចោលកិច្ចសន្យា រវាង ក និង ខ ដូច្នេះកិច្ចសន្យាលក់ទិញនេះត្រូវចាត់ទុកជាមោឃៈតាំងពីដំបូង។ ជាលទ្ធផល ខ មិនមានមូលហេតុស្របច្បាប់ក្នុងការកាន់កាប់រថយន្តនោះទេ ដូច្នេះ ខ ត្រូវប្រគល់រថយន្តមកឱ្យ ក វិញ ហើយ ក ក៏ត្រូវប្រគល់ប្រាក់ ២០០០ $ ទៅឱ្យ ខ ផងដែរ។

## ផ្នែកទី៣៖ យន្តការ និងការការពារភាគីម្ខាងទៀត

បើសកម្មភាពដែលអនីតិជនបានធ្វើ មិនទទួលបានការអនុញ្ញាត ពីអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលទូទៅអាចលុបចោលបាន គឺហាក់បីដូចជាមានភាពលម្អៀងចំពោះភាគីម្ខាងទៀតនៃសកម្មភាពនោះ។ ក្នុងករណីភាគីម្ខាងទៀតដែលបានធ្វើកិច្ចសន្យា បានធ្វើកិច្ចសន្យារួចទៅហើយ តែមិនបានដឹង ឬមិនស្គាល់អ្នកដែលខ្លួនបានធ្វើកិច្ចសន្យានោះជានរណា ភាគីម្ខាងទៀតនោះអាចនឹងមានភាពកង្វល់ ថាមនុស្សដែលខ្លួនធ្វើសកម្មភាពជាមួយនោះនឹងលុបចោលសកម្មភាពនៅពេលណាមួយ? ភាគីម្ខាងទៀតដែលប្រកបកិច្ចការជាមួយនឹងជនដែលត្រូវបានកម្រិតសមត្ថភាព គឺតែងតែប្រឈមមុខនឹងហានិភ័យនៃការលុបចោលកិច្ចសន្យា ទោះបីជាភាគីនោះមិនបានដឹងថាភាគីម្ខាងទៀត គឺជាជនដែលត្រូវបានកម្រិតសមត្ថភាពដោយសុចរិត និងគ្មានកំហុស។ ទន្ទឹមនឹងនេះ វាហាក់ដូចជាអយុត្តិធម៌ចំពោះជនដែលត្រូវបានកម្រិតសមត្ថភាព មានសិទ្ធិលុបចោល ខណៈពេលដែលភាគីម្ខាងទៀតស្ថិតនៅក្នុងទំនាក់ទំនងនៃកិច្ចសន្យាដែលអស្ថេរភាព ដែលអាចត្រូវបានគេលុបចោលដោយគ្មានទីបញ្ចប់។ ជាងនេះទៅទៀត ប្រសិនបើជនដែលត្រូវបានកម្រិតសមត្ថភាព បានប្រើមធ្យោបាយឆបោកដើម្បីឱ្យគេជឿថាខ្លួនគឺ ជាសមត្ថជននោះ ជនដែលត្រូវបានកម្រិតសមត្ថភាពមិនត្រូវបានអនុញ្ញាតឱ្យបដិសេធសកម្មភាពរបស់ខ្លួនឡើយ ដោយសារតែលទ្ធិដែលមានលក្ខណៈជារូបភាព។ ដើម្បីជៀសវាងស្ថានភាពចាញ់ប្រៀបបែបនេះ ក្រមរដ្ឋប្បវេណី បានបញ្ញត្តិទុកលទ្ធភាពឱ្យភាគីម្ខាងទៀតធ្វើការតវ៉ាបានផងដែរ។

នៅក្នុងករណីដែលជនដែលត្រូវបានកម្រិតសមត្ថភាព ( អនីតិជន ជននៅក្រោមអាណាព្យាបាលទូទៅ ជននៅក្រោមហិតូបត្ថម្ភ ) បានធ្វើសកម្មភាពក្រៅពីទំហំសមត្ថភាពរបស់ខ្លួន ជនដែលត្រូវបានកម្រិតសមត្ថភាពនោះអាចអនុវត្តសិទ្ធិលុបចោលបាន។

ដូច្នេះ ក្រមរដ្ឋប្បវេណីបានបញ្ញត្តអំពីសិទ្ធិដាស់តឿន និងការកម្រិតការលុបចោលនៅក្នុងករណីដែលជនដែលត្រូវបានកម្រិតសមត្ថភាពបានប្រើមធ្យោបាយឆបោក ម៉្យាងវិញទៀតអនីតិជនដែលទទួលបានអត្តាធីនភាព ការធ្វើសកម្មភាពរបស់ពួកគេមិនអាចលុបចោលបានផងដែរ។

### ១. ការដាស់តឿន

ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ទទួលស្គាល់សិទ្ធិដាស់តឿនរបស់ភាគីម្ខាងទៀត។[42] ការដាស់តឿន គឺជាការតឿនឱ្យភ្ញាក់ស្មារតី ឬឱ្យនឹកឃើញ។[43] ការដាស់តឿននេះ គឺចង់បញ្ជាក់ទៅភាគីណាម្ខាងថាយល់ព្រម ឬមិនយល់ព្រមចំពោះសកម្មភាពណាមួយ។ ប្រសិនបើមិនមានភាពច្បាស់លាស់ទេថា សកម្មភាពរបស់ជនដែលត្រូវកម្រិតសមត្ថភាពត្រូវបានលុបចោល ឬមិនលុបចោល ធ្វើឱ្យអំឡុងពេលនោះ ភាគីម្ខាងទៀត ស្ថិតក្នុងស្ថានភាពដែលគ្មានស្ថេរភាព។ ម៉្យាងវិញទៀតការចែងផ្ដល់សិទ្ធិដាស់តឿនដល់ភាគីម្ខាងទៀត នៃជនដែលត្រូវបានកម្រិតនូវសមត្ថភាពក្នុងការធ្វើសកម្មភាព គឺដើម្បីអាចកំណត់ឱ្យបានច្បាស់លាស់នូវទំនាក់ទំនងគតិយុត្តឱ្យបានឆាប់រហ័សផងដែរ។

ក្រមរដ្ឋប្បវេណីថ្មីបានបញ្ញត្តឱ្យភាគីម្ខាងទៀតដែលធ្វើពាណិជ្ជកម្មជាមួយអាចធ្វើការដាស់តឿនចំពោះជនដែលត្រូវបានកម្រិតសមត្ថភាព និងអ្នកថែរក្សាជននោះឱ្យធ្វើការឆ្លើយតបថាផ្ដល់សច្ចានុម័ត[44] ឬមិនផ្ដល់សច្ចានុម័តនូវសកម្មភាពដែលអាចលុបចោលបានក្នុងអំឡុងពេលកំណត់មួយ។ រីឯអ្នកដែលការពារជនដែលត្រូវបានកម្រិតនូវសមត្ថភាព ដែលបានទទួលការដាស់តឿននោះវិញ ក៏ចាំបាច់មានពេលវេលាមួយដើម្បីពិចារណាមើលដែរ ហេតុនេះហើយ ការដាស់តឿននេះ ត្រូវបានកំណត់នូវអំឡុងពេលយ៉ាងតិចមួយខែ។ ចំពោះការដាស់តឿននេះ ត្រូវចាត់ចែងទៅតាមចម្លើយ បើមានចម្លើយអំពីការផ្ដល់ ឬមិនផ្ដល់ នូវសច្ចានុមតិនោះ ហើយប្រសិនបើមិនមានចម្លើយទេ ត្រូវចាត់ទុកថាបានផ្ដល់សច្ចានុមតិ។ [45]

ក្នុងករណីជនដែលត្រូវកម្រិតសមត្ថភាពមានសមត្ថភាពឡើងវិញ ភាគីម្ខាងទៀតក៏អាចធ្វើការដាស់តឿនចំពោះជនដែលត្រូវបានកម្រិតសមត្ថភាពដែលមានសមត្ថភាពឡើងវិញនោះផងដែរ ដោយកំណត់អំឡុងពេលលើសពីមួយខែ ប្រសិនបើមិនទទួលបានការឆ្លើយតបក្នុងអំឡុងពេលនោះទេ ត្រូវចាត់ទុកថាបានផ្ដល់សច្ចានុម័តចំពោះសកម្មភាពនោះ។ [46]

គួរបញ្ជាក់ថា ការដាស់តឿននេះ គឺធ្វើឡើងដើម្បីឱ្យភាគីម្ខាងទៀតផ្ដល់សច្ចានុម័ត ឬមិនផ្ដល់សច្ចានុម័ត។ ការផ្ដល់សច្ចានុមតិ គឺជាសកម្មភាពជាឯកតោភាគី ហើយវាត្រូវមានអានុភាពចាប់ពីពេលដែលការជូនដំណឹងនោះបានដល់ភាគីម្ខាងទៀត។ ប្រសិនបើជនដែលមានសិទ្ធិក្នុងការលុបចោល បានផ្ដល់នូវសច្ចានុមតិចំពោះ

---

[42] មាត្រា ៣២ នៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៧

[43] វចនានុក្រមសម្តេចសង្ឃរាជជួន ណាត

[44] សច្ចានុម័ត គឺជាការបញ្ជាក់ការយល់ព្រមជាផ្លូវការនូវអំពើណាមួយដែលធ្វើឡើងដោយមនុស្សណាម្នាក់។

[45] សេចក្តីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមរដ្ឋប្បវេណីកម្ពុជា

[46] កថាខណ្ឌទី១ មាត្រា៣២ នៃក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៧

សកម្មភាពដែលអាចលុបចោលបាន សកម្មភាពនោះត្រូវបានចាត់ទុកថាមានសុពលភាពជាស្ថាពរ ហើយមិនអាចត្រូវបានគេលុបចោលទៀតទេ។

## ២. ការឆបោក

ការឆបោក គឺជាស្ថានភាពដែលបុគ្គល ( ភាគីម្ខាងនៃកិច្ចសន្យា ឬតតិយជន ) បានធ្វើឱ្យភាគីម្ខាងទៀតយល់ច្រឡំទៅលើអង្គហេតុ និងបង្ហាញឆន្ទៈដោយសារសកម្មភាពបំភ្លៃអង្គហេតុ ឬជាសកម្មភាពលាក់បាំងអង្គហេតុពិត។[47] យោងតាមគោលគំនិតក្រមរដ្ឋប្បវេណី ភាគីដែលបង្ហាញឆន្ទៈថាមានការឆបោក អាចលុបចោលកិច្ចសន្យានោះបាន ទោះបីការឆបោកត្រូវបានធ្វើឡើងដោយភាគីម្ខាង ឬដោយទង្វើរបស់តតិយជនក៏ដោយ។ ការឆបោក គឺជាការបង្ហាញឆន្ទៈក្នុងគោលបំណងបោកបញ្ឆោត ដើម្បីឱ្យភាគីម្ខាងទៀតយល់ច្រឡំ។ ការឆបោកមានលក្ខណៈស្រដៀងគ្នាទៅនឹងការភាន់ច្រឡំ ត្រង់ចំណុចដែលឆន្ទៈពិតប្រាកដ និងការបង្ហាញឆន្ទៈចេញមកក្រៅមិនត្រូវគ្នា។ ក៏ប៉ុន្តែ ភាពខុសគ្នានេះកើតឡើងពីសកម្មភាពឆបោករបស់ភាគីម្ខាងទៀត ឬតតិយជន នៅក្នុងករណីនៃការឆបោកដែលមានលក្ខណៈខុសគ្នាពីការភាន់ច្រឡំ។[48]

**មធ្យោបាយឆបោក** គឺជាវិធីបោកបញ្ឆោត ដើម្បីធ្វើឱ្យភាគីម្ខាងទៀតជឿថាជនដែលត្រូវបានកម្រិតសមត្ថភាពនោះ មានសមត្ថភាពក្នុងការធ្វើសកម្មភាព។ សកម្មភាពដែលត្រូវចាត់ទុកថាជាមធ្យោបាយឆបោកត្រូវធ្វើការសម្រេច ដោយធ្វើការពិចារណាទៅលើលក្ខខណ្ឌជាក់ស្តែងមួយចំនួនដូចជា ប្រភេទនៃការកម្រិតសមត្ថភាព ( អនិតិជន ជននៅក្រោមអាណាព្យាបាលទូទៅ ឬជននៅក្រោមហិតូបត្ថម្ភ ) សកម្មភាព ( កិច្ចសន្យាធ្វើទល់មុខគ្នា ឬអត់ ប្រភេទ ឬទំហំ នៃកិច្ចសន្យាជាអាទិ៍) និងវិធីកំណត់អត្តសញ្ញាណប័ណ្ណក្លែងក្លាយ ឯកសារក្លែងក្លាយដែលបង្ហាញពីការយល់ព្រមរបស់អ្នកអាណាព្យាបាលជាអាទិ៍ ជាមូលដ្ឋានប្រសិនបើការការពារជនដែលត្រូវបានកម្រិតសមត្ថភាព ត្រូវបានគេសង្កត់ធ្ងន់ នោះទំហំនៃវិធីឆបោកនឹងត្រូវបានកម្រិតផងដែរ។ ចេតនា នៃការឆបោកគឺដើម្បីឱ្យការឆបោកកើតមាន លុះត្រាតែអ្នកឆបោកបានដឹងថាអង្គហេតុដែលខ្លួននិយាយនោះជាអង្គហេតុមិនពិត។[49]

### ២.១ លក្ខខណ្ឌ

លក្ខខណ្ឌដែលអនីតិជនបានធ្វើការឆបោកនោះគឺ អនីតិជនបានប្រើមធ្យោបាយឆបោកដោយមធ្យោបាយឆបោកត្រូវប្រើទាក់ទងនឹងសមត្ថភាពក្នុងការធ្វើសកម្មភាព ដែលជនដែលត្រូវបានកម្រិតសមត្ថភាពបានប្រើ

[47] ដកស្រង់ចេញពីសៀវភៅនីតិកិច្ចសន្យាពិសេសភាគ១ របស់លោកស្រី ប៉ូលី បញ្ញា និងលោក ព្រុំ រឹទ្ធី បោះពុម្ពលើកទី១ ឆ្នាំ២០២១

[48] សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ដែលរៀបចំដោយក្រុមការងារនៃអនាគតគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិត្យសភាវិជ្ជាជីវៈតុលាការ

[49] មាត្រា ៣៤៧ នៃក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ ២០០៧

មធ្យោបាយឆបោកដោយមានចេតនា និងភាគីម្ខាងទៀតត្រូវបានជឿទុកចិត្តថា អនីតិជន គឺជាជនដែលមានសមត្ថភាពពេញលេញ។

ចំពោះលក្ខខណ្ឌទាំងនេះ តម្រូវឱ្យមាន ជាពិសេសទំនាក់ទំនងហេតុ និងផលរវាងមធ្យោបាយឆបោក និងការជឿជាក់ទៅលើភាពមិនពិត។ យោងតាមសេចក្ដីពន្យល់របស់ក្រមរដ្ឋប្បវេណី បានកំណត់ថាជាការឆបោកមានលក្ខខណ្ឌមួយចំនួនដូចជា ភាគីម្ខាងទៀត ឬតតិយជនមានគោលបំណងឆបោក សកម្មភាពឆបោកនោះត្រូវបានទទួលស្គាល់ថាខុសច្បាប់ អ្នកបង្ហាញឆន្ទៈបានភាន់ច្រឡំ ដោយសារសកម្មភាពឆបោក និងអ្នកបង្ហាញឆន្ទៈបានបង្ហាញឆន្ទៈដោយមានវិការៈ ដោយសារតែការភាន់ច្រឡំ។

**ឧទាហរណ៍៖** អនីតិជនបាននិយាយថាខ្លួនមានអាយុ ២១ឆ្នាំ ដោយបង្ហាញអត្តសញ្ញាណប័ណ្ណក្លែងក្លាយនៅពេលដែលបង្កើតកិច្ចសន្យា គេចាត់ទុកថាវាឆ្លើយតបទៅនឹងមធ្យោបាយឆបោកដែលទាក់ទងនឹងសមត្ថភាពផ្ទុយទៅវិញ ប្រសិនបើអនីតិជនបាននិយាយថាគាត់មានប្រាក់គ្រប់គ្រាន់ ដោយបង្ហាញសៀវភៅគណនីធនាគាររបស់ឪពុកគាត់ នោះវាមិនមែនជាមធ្យោបាយបោកដែលទាក់ទងនឹងសមត្ថភាពក្នុងការធ្វើសកម្មភាពនោះទេ។ ប្រសិនបើជនដែលត្រូវបានកម្រិតសមត្ថភាព បានប្រើប្រាស់មធ្យោបាយឆបោក ដើម្បីឱ្យគេជឿជាក់ថាខ្លួនជាសមត្ថជន ជននោះមិនអាចលុបចោលសកម្មភាពបានឡើយ។

### ២.២ អានុភាព

ប្រសិនបើអនីតិជនបានប្រើប្រាស់មធ្យោបាយ ឬវិធីឆបោក ធ្វើឱ្យភាគីម្ខាងទៀតទុកចិត្ត ជឿថាខ្លួនជាសមត្ថជនរហូតឈានដល់ចុះកិច្ចសន្យាជាមួយគ្នានោះ អានុភាពនៃសកម្មភាពរបស់អនីតិជននេះ មិនអាចលុបចោលកិច្ចសន្យានោះបានទេ។

## ៣. អត្តាធីនភាព

ជាទូទៅ រាល់សកម្មភាពដែលបានប្រព្រឹត្តឡើងដោយអនីតិជនដោយគ្មានការអនុញ្ញាតពីសំណាក់អ្នកដែលមានអំណាចមេបា ឬអ្នកអាណាព្យាបាលទេនោះ ជាគោលការណ៍ គឺអាចលុបចោលបាន លុះត្រាតែជននោះបានដល់នីតិភាព។[50] ពាក្យនីតិភាព ត្រូវបានកំណត់អាយុចាប់ពី១៨ឆ្នាំឡើងទៅដែលជានីតិជន ប៉ុន្តែមានករណីមួយចំនួន ដែលអាចទទួលស្គាល់អំពីការដល់នីតិភាពមុនអាយុកំណត់បាន ដោយករណីដែលអនីតិជនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ អាចទ្រទ្រង់ជីវភាពខ្លួនឯងដោយឯករាជ្យ ហើយត្រូវបានតុលាការប្រកាសផ្ដល់ឱ្យរួចផុតពីឋានៈជាអនីតិជន ឬអនីតិជននោះបានរៀបអាពាហ៍ពិពាហ៍ ដែលករណីទាំងនេះហៅថា « **អត្តាធីនភាព** »។

[50] មាត្រា១៨ នៃក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៧

ពាក្យថា «**អត្តាធីនភាព**» គឺជាលក្ខណៈពិសេសមួយដែលច្បាប់បានផ្ដល់ឱ្យអនីតិជនដែលមានអាយុចាប់ពី ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ ឱ្យរួចផុតពីការស្ថិតនៅក្រោមអំណាចមេបា ឬអាណាព្យាបាលសម្រាប់អនីតិជន ហើយមានសមត្ថភាពគ្រប់គ្រាន់ក្នុងការធ្វើសកម្មភាពដូចនីតិជនដែរ។ យោងតាមក្រមរដ្ឋប្បវេណីរបស់កម្ពុជាឆ្នាំ ១៩៦៧ មាត្រា ៤២៩ បានឱ្យនិយមន័យ អត្តាធីនភាពថាជាអំពើមួយដែលមានគោលដៅតែមួយ គឺបើកឱ្យអនីតិជនគ្រប់គ្រងនូវខ្លួនរបស់ខ្លួន និងចាត់ចែងនូវទ្រព្យរបស់ខ្លួនដោយខ្លួនឯង ចំណែកឯអត្តាធីនភាពនៅក្នុងក្រមរដ្ឋប្បវេណីចាស់ឆ្នាំ ១៩៦៧ គឺអាយុ១៨ ឆ្នាំ។

អត្តាធីនភាពអាចមានអានុភាពធ្វើឱ្យច្បាប់ចាត់ទុកថា អនីតិជននោះបានដល់នីតិភាព (ក្លាយជាជនដែលមានសិទ្ធិដូចទៅនឹងនីតិជនមានអាយុ ១៨ឆ្នាំដែរ) ព្រមទាំងអាចធ្វើសកម្មភាពសម្រេចផ្សេងៗបាន ដូចនីតិជនដែរ។ ចំពោះអនីតិជនដែលចង់មានសមត្ថភាពតាមផ្លូវច្បាប់ក្នុងការធ្វើសកម្មភាពដូចនីតិជន អត្តាធីនភាពគឺពិតជាមានសារសំខាន់ណាស់សម្រាប់ពួកគេ ដោយអត្តាធីនភាពនេះអាចឱ្យពួកគេបានដល់នីតិភាព ដែលអាចធ្វើសកម្មភាពតាមផ្លូវច្បាប់ អាចធ្វើសកម្មភាពពាណិជ្ជកម្ម អាចធ្វើសកម្មភាពដែលទាក់ទងទៅនឹងការទទួលយកនូវសិទ្ធិ និងកាតព្វកិច្ចបាន អាចមានជីវិតដែលឯករាជ្យ ដោយមិនមានការកម្រិតសមត្ថភាពដូចអនីតិជន ហើយអាចរស់នៅដោយពឹងផ្អែកលើខ្លួនឯងទាំងស្រុង និងអាចរួចផុតពីអំណាចមេបា ឬអ្នកអាណាព្យាបាលទូទៅ ជាពិសេសនោះអាចធ្វើនូវសកម្មភាពឯកតោភាគីបានថែមទៀតផង។

អត្តាធីនភាព ត្រូវប្រគល់ទៅឱ្យអនីតិជនតាមច្បាប់ ដោយស្ម័គ្រចិត្ត និងដោយតុលាការ។ ការទទួលបានអត្តាធីនភាពអាចកើតឡើងបានតាមពីររបៀបគឺ តាមរយៈការដាក់ពាក្យសុំទៅតុលាការ ប្រសិនបើអនីតិជនមានអាយុ ១៦ឆ្នាំ និងអាចទ្រទ្រង់ជីវភាពខ្លួនឯងដោយឯករាជ្យ និងតាមរយៈការរៀបអាពាហ៍ពិពាហ៍។[51]

## ៣.១ លក្ខខណ្ឌទទួលបានអត្តាធីនភាព

### ៣.១.១ អត្តាធីនភាពតាមរយៈតុលាការ

ទោះបីជាអនីតិជនមានសមត្ថភាពគ្រប់គ្រាន់អាចប្រកបរបររកស៊ីចិញ្ចឹមជីវិត មានជីវិតឯករាជ្យយ៉ាងណាក៏ដោយ អនីតិជននោះក៏មិនអាចក្លាយជានីតិជនបានដែរ ទោះបីជាមានការទទួលស្គាល់អត្តាធីនភាពពីអ្នកមានអំណាចមេបាក៏ដោយ លក្ខខណ្ឌតែមួយគត់ដែលឱ្យអនីតិជននោះអាចក្លាយជានីតិជន គឺចាំបាច់ត្រូវដាក់ពាក្យសុំទៅតុលាការ។

ក្នុងករណីដែលអនីតិជនដែលបានដល់អាយុ ១៦(ដប់ប្រាំមួយ) ឆ្នាំ ទ្រទ្រង់ជីវភាពខ្លួនឯងដោយឯករាជ្យ តុលាការអាចប្រកាសនូវអត្តាធីនភាពរបស់អ្នកនោះបានតាមពាក្យសុំរបស់អនីតិជននោះ ប្រសិនបើតុលាការ

[51] មាត្រា២១ នៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៧

យល់ឃើញថា អត្តាធីនភាពស្របនឹងផលប្រយោជន៍របស់អនីតិជននោះ។ ក្នុងករណីនេះ តុលាការត្រូវសួរយោបល់ពីអ្នកមានសិទ្ធិអំណាចមេបា។[52] ប៉ុន្តែមុននឹងតុលាការសម្រេចការប្រកាសនូវអត្តាធីនភាពដល់អនីតិជនណាម្នាក់ នោះតុលាការគប្បីធ្វើការវិនិច្ឆ័យ និងពិចារណាយ៉ាងលម្អិតហើយត្រូវឆ្លងកាត់ការសាកសួរយោបល់អ្នកដែលមានអំណាចមេបា ឬអ្នកអាណាព្យាបាលជាមុនសិន ដើម្បីចៀសវាងការខូចខាតប្រយោជន៍របស់អនីតិជននោះ ឬប្រយោជន៍របស់ភាគីនៃចំណងគតិយុត្តម្ខាងទៀត នៃទំនាក់ទំនងសកម្មភាពរបស់អនីតិជននោះ។

### ៣.១.២ អត្តាធីនភាពតាមរយៈអាពាហ៍ពិពាហ៍

ពេលដែលលឺពាក្យថាអាពាហ៍ពិពាហ៍ គេច្រើនស្រមៃទៅលើការរៀបចំពិធីមង្គលការតាមប្រពៃណីក្នុងកម្រិតអប្បរមាមួយ។ **ឧទាហរណ៍** ការសែនព្រេន សំពះផ្ទឹម ព្រះថោងតោងស្បៃនាងនាគ ពិធីផ្សំដំណេកជាដើម។ ពាក្យអាពាហ៍ពិពាហ៍មានន័យច្រើនយ៉ាង អាពាហ៍ពិពាហ៍ ទោះជាមានការរៀបចំកម្មវិធីយ៉ាងអធឹកអធម្ម យ៉ាងណាក៏ដោយ ប្រសិនបើមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ ឬធ្វើឡើងដោយមិនស្របតាមច្បាប់ទេគឺនឹងមិនមានអំណាចក្នុងផ្លូវច្បាប់ឡើយ។ អាពាហ៍ពិពាហ៍ នឹងមានអានុភាពពេញលក្ខណៈច្បាប់បាន លុះត្រាតែអាពាហ៍ពិពាហ៍ នោះធ្វើឡើងស្របតាមក្បួនខ្នាតដែលមានចែងក្នុងច្បាប់។ អាពាហ៍ពិពាហ៍ស្របច្បាប់ អនីតិជនក៏អាចទទួលបានអត្តាធីនភាពតាមអាពាហ៍ពិពាហ៍ផងដែរ។ យោងតាមមាត្រា ១១៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ ១៩៦៧ បានឱ្យនិយមន័យ អាពាហ៍ពិពាហ៍ គឺជាកិច្ចសន្យាយ៉ាងឧឡារិកមួយ ដែលប្រុសម្នាក់ និងស្រីម្នាក់ ប្តេជ្ញាគ្នាថា ខ្លួននឹងរួមអនីតិសង្វាសជាមួយគ្នាតាមច្បាប់ ដែលបានបញ្ញត្តិមក ហើយមិនអាចរំលាយបានតាមទំនើងចិត្តរបស់ខ្លួន។

អនីតិជនដែលមិនទាន់គ្រប់អាយុ ១៦ឆ្នាំ គឺមិនអាចរៀបអាពាហ៍ពិពាហ៍បានឡើយ។ ជាទូទៅអនីតិជនដែលអាចរៀបអាពាហ៍បានលុះត្រាតែមានអាយុចាប់ពី១៦ឆ្នាំ និងត្រូវគោរពតាមលក្ខខណ្ឌមួយចំនួនដែលមានចែងក្នុងមាត្រា ៩៤៨ នៃក្រមរដ្ឋប្បវេណីថ្មី។ ចំពោះអនីតិជន អាយុចាប់ពី១៦ឆ្នាំឡើយ ដែលបានពេញវ័យ មានគំនិតចាស់ទុំ អាចរៀបអាពាហ៍ពិពាហ៍បាន លុះត្រាតែភាគីម្ខាងទៀតជានីតិជន មានអាយុចាប់ពី ១៨ឆ្នាំឡើង ហើយអនីតិជននោះចាំបាច់ត្រូវទទួលការយល់ព្រមពីឪពុកម្តាយ ឬអ្នកមានអំណាចមេបា។ នៅពេលអាពាហ៍ពិពាហ៍បានកើតឡើង អានុភាពតាមផ្លូវច្បាប់ជាក់លាក់មួយចំនួនក៏ត្រូវកើតឡើងដូចគ្នា។

អនីតិជនដែលបានរៀបអាពាហ៍ពិពាហ៍ហើយ ត្រូវទទួលបានអត្តាធីនភាពដោយមិនចាំបាច់មានការប្រកាសពីតុលាការទេ[53] ជាអត្តាធីនភាពដោយស្វ័យប្រវត្តិមិនចាំបាច់ដាក់ពាក្យសុំទៅតុលាការ។ ការចាត់ទុកជានីតិជនដោយសារអាពាហ៍ពិពាហ៍នេះ មានន័យថាប្រសិនបើអនីតិជននោះបានរៀបអាពាហ៍ពិពាហ៍ហើយ គាត់

[52] មាត្រា២១ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ ២០០៧

[53] មាត្រា២១ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ ២០០៧

នឹងត្រូវបានចាត់ទុកថា ជាបុគ្គលដែលមានសមត្ថភាពពេញលេញនៅក្នុងការធ្វើសកម្មភាពស្របតាមច្បាប់ លើសពីនេះថែមទាំងអាចធ្វើសកម្មភាពទាក់ទងឋានៈបុគ្គល ក៏ដូចជាសកម្មភាពក្នុងជីវភាពអាពាហ៍ពិពាហ៍ផ្សេងទៀតដោយឯករាជ្យ ដោយមិនចាំបាច់អន្តរាគមន៍ពីឪពុកម្តាយ ឬអ្នកមានអំណាចមេបាផងដែរ។ យោងតាមមាត្រា៩៦៨ នៃក្រមរដ្ឋប្បវេណី ចែងថាប្រសិនបើអនីតិជនបានរៀបអាពាហ៍ពិពាហ៍ អនីតិជននោះត្រូវបានចាត់ទុកថា បានដល់នីតិភាពដោយអាពាហ៍ពិពាហ៍នោះ ក្នុងការអនុវត្តក្រមរដ្ឋប្បវេណីនេះ។ នេះមានន័យថានៅក្រោយពេលរៀបអាពាហ៍ពិពាហ៍ អនីតិជនត្រូវរួចផុតពីអំណាចមេបា ដោយចាត់ទុកជានីតិជន។

### ៣.២ អានុភាពនៃអត្តាធីនភាព

អនីតិជនដែលទទួលបានអត្តាធីនភាពត្រូវបានចាត់ទុកថាបានដល់នីតិភាព[54]។ នេះមានន័យថា អត្តាធីនភាព គឺមានអានុភាពអាចធ្វើឱ្យច្បាប់ចាត់ទុកថាអនីតិជន ជាជនដែលមានសិទ្ធិដូចនីតិជនដែលមានអាយុគ្រប់ ១៨ឆ្នាំ ហើយអាចធ្វើសកម្មភាពបានដូចនីតិជនដែរ។ ដោយសារតែអានុភាពនេះហើយ អនីតិជនអាចធ្វើសកម្មភាពទូទៅបានដូចនីតិជន ដូចជាសកម្មភាពពាណិជ្ជកម្ម ការបើកអាជីវកម្មផ្ទាល់ខ្លួនដោយមិនចាំបាច់មានការអនុញ្ញាតពីឪពុកម្តាយ ឬអាណាព្យាបាល ឬអ្នកដែលមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនឡើយ។ ជនដែលទទួលបានអត្តាធីនភាព ត្រូវមានសិទ្ធិ និងករណីយកិច្ចដូចគ្នានឹងនីតិជនដែរ អនីតិជនព្រមទាំងអាចធ្វើសកម្មភាពកិច្ចសន្យា ដោយអាចបង្កើត កែប្រែ និងរលត់កាតព្វកិច្ចបាន និងអាចធ្វើសកម្មភាពឯកតោភាគីបានថែមទៀតផង។ លើសពីនេះទៅទៀត អនីតិជនអាចទទួលបាននូវបុគ្គលភាពគតិយុត្ត (ភាពជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ច) យ៉ាងពេញលេញ។ មិនត្រឹមតែប៉ុណ្ណោះ អនីតិជនដែលចាត់ទុកថាជានីតិជន មិនត្រឹមតែទទួលបានសមត្ថភាពក្នុងការធ្វើសកម្មភាពស្របច្បាប់ទាក់ទងនឹងទ្រព្យសម្បត្តិទេ តែថែមទាំងអាចធ្វើសកម្មភាពដែលទាក់ទងនឹងឋានៈបុគ្គល ក៏ដូចជាសកម្មភាពក្នុងជីវភាពអាពាហ៍ពិពាហ៍ផ្សេងទៀត ដោយឯករាជ្យ និងមិនចាំបាច់អន្តរាគមន៍ពីឪពុកម្តាយឡើយ។ អនីតិជនដែលទទួលបានអត្តាធីនភាពនឹងត្រូវទទួលខុសត្រូវចំពោះកាតព្វកិច្ច ដែលបានកើតឡើងចាប់តាំងពីពេលទទួលបាននូវអត្តាធីនភាពរហូតមកដោយគោរពដូចគ្នាទៅនឹងនីតិជនដែរ។

ក្នុងករណីអនីតិជនដែលទទួលបានអត្តាធីនភាពតាមរយៈអាពាហ៍ពិពាហ៍ ទោះបីជាអនីតិជននោះបានលែងលះគ្នា(នៅក្នុងអំឡុងពេលមានអាយុចាប់ពី ១៦ឆ្នាំ ទៅក្រោម ១៨ឆ្នាំ) ក៏ដោយ បន្ទាប់ពីលែងលះរួចអានុភាពនៃអត្តាធីនភាពនោះមិនរលត់ឡើយដោយយោងតាមមាត្រា២១ នៃក្រមរដ្ឋប្បវេណី កថាខណ្ឌទី៣ ដែលចែងថា ក្រោយពីលែងលះហើយ អនីតិជននោះនៅតែត្រូវបានចាត់ទុកថាមានអត្តាធីនភាពដោយមានសិទ្ធិ និង

[54] មាត្រា២២ នៃក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៧

កាតព្វកិច្ចដូចនីតិជនដដែល។ មូលហេតុដែលច្បាប់ចែងបែបនេះ ពីព្រោះគេពិនិត្យមើលទៅលើសមត្ថភាពបុគ្គល កាលណាដែលបុគ្គលមួយដែលធ្លាប់រៀបអាពាហ៍ពិពាហ៍ហើយ នោះមានន័យថាបុគ្គលនោះធ្លាប់បានចាត់ចែងទ្រព្យសម្បត្តិ ធ្លាប់បានសម្រេចចិត្តទៅលើរឿងអ្វីមួយដោយខ្លួនឯងដោយមិនពឹងអ្នកដទៃ។ នេះសបញ្ជាក់ថាបុគ្គលនោះមានសមត្ថភាពពេញលេញក្នុងការធ្វើសកម្មភាពរបស់ខ្លួនដោយមិនចាំបាច់មានអ្នកមើលថែ ឬត្រួតពិនិត្យទៀតហើយ។ ដូចនេះ បានជាច្បាប់ចែងថា ទោះបីជាអនីតិជនលែងលះក៏ដោយ ក៏នៅទទួលបានអត្តាធីនភាពដដែល។

សូមធ្វើការកត់សម្គាល់ថា អានុភាពនៃអត្តាធីនភាព មិនត្រូវលាតសន្ធឹងទៅដល់វិស័យសាធារណៈនោះទេ ដូចជាការកំណត់អំពីសិទ្ធិបោះឆ្នោត សិទ្ធិទទួលទានគ្រឿងស្រវឹង ឬការទទួលខុសត្រូវព្រហ្មទណ្ឌជាដើម។[55]

[55] ដកស្រង់ចេញពីកម្រងករណីសិក្សា និងសំនួរចម្លើយអំពីការអនុវត្តជាក់ស្តែងទាក់ទងនឹងក្រមរដ្ឋប្បវេណីរបស់គម្រោងអភិវឌ្ឍន៍ច្បាប់ និងតុលាការក្រុមការងាររាជបណ្ឌិត្យសភាវិជ្ជាជីវៈតុលាការ

# ជំពូកទី ៣

# ជននៅក្រោមអាណាព្យាបាលទូទៅ

# ជំពូកទី ៣

# ជននៅក្រោមអាណាព្យាបាលទូទៅ

## ផ្នែកទី១៖ របបអាណាព្យាបាលទូទៅ

### ១. និយមន័យ

របបអាណាព្យាបាលទូទៅ គឺជារបបមួយសម្រាប់ការពារសិទ្ធិចំពោះបុគ្គលដែលមានដូចជាជីវិត រូបកាយ សេរីភាព ទ្រព្យសម្បត្តិជាដើម របស់ជនដែលខ្វះសមត្ថភាពក្នុងការវិនិច្ឆ័យ។ ដើម្បីអាចធ្វើការគ្រប់គ្រង និងការពារសិទ្ធិរបស់ជននៅក្រោមអាណាព្យាបាលទូទៅបាន គឺចាំបាច់ណាស់ក្នុងការបង្កើតឱ្យមានអ្នកអាណាព្យាបាលទូទៅ។ អាណាព្យាបាលទូទៅ គឺជារបបមួយដែលជនម្នាក់ធ្វើសកម្មភាពគតិយុត្ត ជំនួសជនម្នាក់ទៀតដែលស្ថិតនៅក្នុងស្ថានភាពជានិរន្តរ៍ ដែលខ្វះសមត្ថភាពយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនដោយសារមានវិបត្តិផ្នែកស្មារតី និងការពារជននោះនៅក្នុងការធ្វើការជួញដូរ។ បុគ្គលដែលត្រូវបានការពារដោយរបបនេះ ហៅថា «**ជននៅក្រោមអាណាព្យាបាលទូទៅ**» ហើយបុគ្គលដែលផ្តល់ការការពារ ហៅថា «**អ្នកអាណាព្យាបាលទូទៅ**» ។

អ្នកអាណាព្យាបាលទូទៅ គឺជាអ្នកតំណាងដែលច្បាប់បានកំណត់ និងមានសិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិរបស់ជននៅក្រោមអាណាព្យាបាលទូទៅ ហើយត្រូវធ្វើជាអ្នកតំណាងឱ្យជននោះ ចំពោះសកម្មភាពដែលទាក់ទងនឹងទ្រព្យសម្បត្តិដែលខ្លួនគ្រប់គ្រង[56]។ មានន័យថាអ្នកអាណាព្យាបាលទូទៅ មានសិទ្ធិតំណាងទាំងស្រុង ចំពោះការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ជននៅក្រោមអាណាព្យាបាលទូទៅ និងចំពោះសកម្មភាពដែលទាក់ទងនឹងទ្រព្យសម្បត្តិរបស់ជននៅក្រោមអាណាព្យាបាលទូទៅ លើកលែងតែសកម្មភាពទាក់ទងនឹងទ្រព្យសម្បត្តិ សកម្មភាពបង្កើតកាតព្វកិច្ចដែលមានកម្មវត្ថុ ជាសកម្មភាពរបស់ជននៅក្រោមអាណាព្យាបាលទូទៅ ដែលតម្រូវឱ្យមានទទួលការយល់ព្រមពីជននោះ។ ករណីយកិច្ចរបស់អ្នកអាណាព្យាបាលទូទៅ គឺធ្វើកិច្ចសន្យាដែលចាំបាច់សម្រាប់ការថែទាំសុខភាព ឬព្យាបាលជម្ងឺ និងបង់ថ្លៃចំណាយដែលចាំបាច់ផ្សេងៗ។

ជននៅក្រោមអាណាព្យាបាលទូទៅ គឺជាជនដែលស្ថិតនៅក្នុងស្ថានភាពជានិរន្តរ៍ដែលខ្វះសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន[57]ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី ហើយតុលាការអាចចាប់ផ្តើមអាណាព្យាបាលទូទៅតាមពាក្យសុំ ។

[56] មាត្រា ១១១៤ នៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៧

[57] ស្ថានភាពជានិរន្តរ៍ ដែលខ្វះសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន សំដៅទៅលើស្ថានភាពដែលខ្វះនូវសមត្ថភាពខាងឆន្ទៈអាចមិនជាប្រចាំទេ ជួនកាលបុគ្គលនោះអាចមានសមត្ថភាពបង្ហាញឆន្ទៈក្នុងកម្រិតអប្បបរមា។

## ២. ការប្រកាសចាប់ផ្ដើមអាណាព្យាបាលទូទៅ

ដើម្បីយល់អំពីការប្រកាសចាប់ផ្ដើមអាណាព្យាបាលទូទៅ យើងគប្បីយល់អំពីលក្ខខណ្ឌដែលអាចក្លាយជាជននៅអាណាព្យាបាលទូទៅ និងនីតិវិធីដើម្បីទទួលបានរបបអាណាព្យាបាលទូទៅជាមុនសិន។

### ២.១ លក្ខខណ្ឌដែលអាចក្លាយជាជននៅអាណាព្យាបាលទូទៅ

ជនដែលអាចក្លាយជាជននៅក្រោមអាណាព្យាបាលទូទៅបានលុះត្រាតែគោរពតាមលក្ខខណ្ឌដូចជា៖

#### ២.១.១ អាយុ

ការប្រកាសការចាប់ផ្ដើមអាណាព្យាបាលទូទៅ អាចធ្វើទៅបានលុះត្រាតែសាមីខ្លួននោះមានអាយុយ៉ាងតិច ១៥ឆ្នាំនៅពេលដាក់ពាក្យសុំប៉ុណ្ណោះ។

#### ២.១.២ សមត្ថភាព

ដើម្បីអាចក្លាយជាជននៅក្រោមអាណាព្យាបាលទូទៅបាន លុះត្រាតែជននោះស្ថិតនៅក្នុងស្ថានភាពជានិរន្តរ៍[58] ដែលខ្វះសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី ឧទាហរណ៍ដូចជាជនដែលមិនអាចទិញអីវ៉ាន់ប្រចាំថ្ងៃដោយខ្លួនឯងបាន ហើយចាំបាច់ត្រូវមានអ្នកណាធ្វើជំនួស ជនដែលមិនដឹងអ្វីៗដែលកើតមានឡើងរៀងរាល់ថ្ងៃ (ឈ្មោះ គ្រួសារ ទីកន្លែងដែលខ្លួនរស់នៅ ជាដើម) ជនដែលធ្លាក់ខ្លួនក្នុងស្ថានភាពជាមនុស្សរុក្ខជាតិ (ស្ថានភាពស្លាប់ខួរក្បាល) ជាអាទិ៍ ។

### ២.២ នីតិវិធីដើម្បីទទួលបានរបបអាណាព្យាបាលទូទៅ

#### ២.២.១ ការស្នើសុំ

ដើម្បីទទួលបានរបបអាណាព្យាបាលទូទៅ លុះត្រាតែដាក់ពាក្យសុំទៅតុលាការមានសមត្ថកិច្ច។ អ្នកដែលមានសិទ្ធិដាក់ពាក្យសុំ មានដូចជា សាមីខ្លួនផ្ទាល់ សហព័ទ្ធ ញាតិដែលស្ថិតនៅក្នុង ៤ (បួន) ថ្នាក់ អ្នកអាណាព្យាបាលសម្រាប់អនីតិជន អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ហិតូបត្ថម្ភកៈ មេឃុំ ឬចៅសង្កាត់នៃលំនៅឋានរបស់ជននោះ ឬតំណាងអយ្យការ។[59]

កាលដែលអនុញ្ញាតឱ្យអាណាព្យាបាលសម្រាប់អនីតិជន អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជនអាចដាក់ពាក្យសុំឱ្យប្រកាសចាប់ផ្ដើមអាណាព្យាបាលទូទៅបាននោះ ព្រោះអ្នកត្រួតពិនិត្យអាចធ្វើការសន្និដ្ឋានបានថា វាមានសារៈសំខាន់សម្រាប់អនីតិជនដែលមានសមត្ថភាពខ្សោយ ត្រូវបានប្រកាសឱ្យចាប់ផ្ដើមអាណាព្យាបាលទូទៅ។

---

[58]ស្ថានភាពជានិរន្តរ៍ ចង់សំដៅទៅលើស្ថានភាពជានិច្ចខ្វះសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន។

[59] មាត្រា២៤ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧

**សាមីខ្លួន** ក្នុងន័យនេះគឺចង់សំដៅទៅលើអ្នកដែលត្រូវបានកម្រិតសមត្ថភាព ហើយបានបង្ហាញឆន្ទៈឡើងមក។ **សហព័ទ្ធ** គឺជាប្តី ឬប្រពន្ធ ឬទាំងប្តី ទាំងប្រពន្ធដែលទទួលបានឋានៈជាសហព័ន្ធនេះក្រោយពីបានចុះបញ្ជីអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់។[60] **អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន** គឺជាអ្នកត្រួតពិនិត្យកិច្ចការរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ប៉ុន្តែករណីខ្លះក៏ជាអ្នកតំណាងឱ្យអនីតិជនដែរ ចំណែក **ហិតូបត្ថម្ភកៈ**វិញ គឺជាជាជនដែលតុលាការចាត់តាំងឱ្យអនុវត្តហិតូបត្ថម្ភ។[61]

ម្យ៉ាងវិញទៀតចំពោះជនដែលស្ថិតនៅក្រោមហិតូបត្ថម្ភ ប្រសិនបើជននោះមានវិបត្តិផ្នែកស្មារតីកាន់តែធ្ងន់ធ្ងរទៅ ហើយគ្មានសមត្ថភាពនៅក្នុងការធ្វើសកម្មភាព ហិតូបត្ថម្ភកៈ ឬអ្នកត្រួតពិនិត្យហិតូបត្ថម្ភកៈ អាចនឹងដាក់ពាក្យសុំប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅបាន។

### ២.២.២ ការវិនិច្ឆ័យ និងការប្រកាសរបស់តុលាការ

ការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅប្រព្រឹត្តទៅបានលុះត្រាតែដាក់ពាក្យសុំទៅតុលាការ ( ដូចបានបង្ហាញនៅ **ផ្នែកទី១ ចំណុច ២.២ នីតិវិធីដើម្បីទទួលបានរបបអាណាព្យាបាលទូទៅ** ) ហើយតុលាការចេញដីកាសម្រេចដើម្បីចាប់ផ្តើមអាណាព្យាបាលទូទៅ ទើបជននោះអាចក្លាយជាជននៅក្រោមអាណាព្យាបាលទូទៅតាមផ្លូវច្បាប់បាន។ ប្រសិនបើមានពាក្យសុំឱ្យប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ ពីសាមីខ្លួន ឬពីគ្រួសារជាអាថ៌ តុលាការត្រូវពិនិត្យមើលស្ថានភាពជាក់ស្តែងរបស់ជននោះ ដើម្បីវិនិច្ឆ័យនូវការចាប់ផ្តើមអាណាព្យាបាលទូទៅ ហើយជ្រើសតាំងអ្នកដែលសមរម្យឱ្យធ្វើជាអ្នកអាណាព្យាបាលទូទៅ។ ក្នុងករណីដែលជនទទួលការប្រកាសការចាប់ផ្តើមហិតូបត្ថម្ភមានស្ថានភាពកាន់តែធ្ងន់ធ្ងរទៅនោះ ហិតូបត្ថម្ភកៈ និងអ្នកត្រួតពិនិត្យហិតូបត្ថម្ភកៈក៏អាចដាក់ពាក្យសុំដើម្បីឱ្យប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅបានផងដែរ។ ក្នុងករណីបែបនេះ តុលាការត្រូវលុបចោលការប្រកាសចាប់ផ្តើមហិតូបត្ថម្ភនោះដោយឆន្ទានុសិទ្ធិរបស់ខ្លួនជាមុនសិន ទើបតុលាការប្រកាសរបបអាណាព្យាបាលទូទៅនេះជាក្រោយ។

គួរបញ្ជាក់ថាមុនពេលប្រកាសរបបអាណាព្យាបាលទូទៅ តុលាការត្រូវស្តាប់មតិយោបល់របស់វេជ្ជបណ្ឌិត និងផ្តល់ឱកាសឱ្យសាមីខ្លួនធ្វើសេចក្តីថ្លែងការណ៍ ដើម្បីពិចារណាថាសាមីខ្លួន ពិតជាមានបញ្ហាផ្នែកស្មារតីពិតប្រាកដមែន។ ប្រសិនបើតុលាការយល់ឃើញថា គួរតែប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅចំពោះជននោះ នោះតុលាការត្រូវចេញដីកាសម្រេច។ ដីកាសម្រេច គឺជាការសម្រេចសេចក្តីដែលតុលាការ ឬចៅក្រមអាចធ្វើដោយមិនឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់បាន ហើយមិនមែនជាសាលក្រម។[62]

---

[60] សន្ធានុក្រមលេខ១៥០ នៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៧

[61] សន្ធានុក្រមលេខ១៧២ នៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៧

[62] មាត្រា ១៧៩ ប្រភេទនៃការសម្រេចសេចក្តី នៃក្រមនីតិវិធីរដ្ឋប្បវេណី

### ២.២.៣ ការជ្រើសតាំងអ្នកអាណាព្យាបាលទូទៅ

#### ២.២.៣.១ បុគ្គលដែលអាចត្រូវបានជ្រើសតាំង

កាលបើតុលាការប្រកាសចាប់ផ្ដើមអាណាព្យាបាលទូទៅនោះតុលាការត្រូវជ្រើសតាំងអ្នកអាណាព្យាបាលទូទៅដោយឆន្ទានុសិទ្ធិ ប៉ុន្តែត្រូវដកបុគ្គលមួយចំនួនដែលមានចែងក្នុងមាត្រា ១១០៩ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧។ ដើម្បីជ្រើសតាំងអ្នកអាណាព្យាបាលទូទៅ តុលាការត្រូវគិតពិចារណាអំពីស្ថានភាពផ្លូវកាយ ផ្លូវចិត្ត ស្ថានភាពជីវភាព និងទ្រព្យសម្បត្តិរបស់ជននៅក្រោមអាណាព្យាបាលទូទៅ វិជ្ជាជីវៈ និងប្រវត្តិរូបរបស់អ្នកដែលត្រូវធ្វើជាអ្នកអាណាព្យាបាលទូទៅ និងអត្ថិភាព ឬនត្ថិភាព នៃទំនាក់ទំនងទៅនឹងផលប្រយោជន៍ រវាងអ្នកអាណាព្យាបាលទូទៅ និងជននៅក្រោមអាណាព្យាបាលទូទៅ និងយោបល់របស់ជននៅក្រោមអាណាព្យាបាលទូទៅ និងស្ថានភាពផ្សេងៗទៀតទាំងស្រុង។

រូបវន្តបុគ្គល និងនីតិបុគ្គលសុទ្ធសឹងតែអាចក្លាយជាអ្នកអាណាព្យាបាលទូទៅបាន។ នីតិបុគ្គលក្នុងន័យនេះសំដៅទៅលើអង្គការក្រៅរដ្ឋាភិបាល មន្ទីរពេទ្យ ឬស្ថាប័នសង្គមកិច្ចជាដើមដែលមាននីតិបុគ្គលភាព។ អ្នកអាណាព្យាបាលទូទៅ មិនត្រូវបានកម្រិតចំនួននោះទេ ដូចនេះតុលាការអាចជ្រើសតាំងអ្នកអាណាព្យាបាលទូទៅលើសពីម្នាក់បាន។ ម៉្យាងទៀតតុលាការក៏អាចជ្រើសតាំងអ្នកអាណាព្យាបាលទូទៅ ដែលម្នាក់ជារូបវន្តបុគ្គល ឯម្នាក់ទៀតជានីតិបុគ្គលបានថែមទៀតផង។ ក្នុងករណីដែលអ្នកអាណាព្យាបាលទូទៅជានីតិបុគ្គល តុលាការត្រូវគិតពិចារណាផងដែរអំពីប្រភេទ និងខ្លឹមសារនៃកិច្ចការរបស់នីតិបុគ្គល និងអត្ថិភាព ឬនត្ថិភាព នៃទំនាក់ទំនងទៅនឹងផលប្រយោជន៍ រវាងនីតិបុគ្គល និងអ្នកតំណាងរបស់នីតិបុគ្គលនោះ និងជននៅក្រោមអាណាព្យាបាលទូទៅ។

ក្នុងករណីខ្វះអ្នកអាណាព្យាបាលទូទៅ ឬអ្នកអាណាព្យាបាលទូទៅដែលបានជ្រើសតាំងពីអតីតកាលនោះបានទទួលមរណៈភាព ហើយចាំបាច់ត្រូវជ្រើសតាំងអ្នកអាណាព្យាបាលទូទៅថ្មី តុលាការត្រូវជ្រើសតាំងអ្នកអាណាព្យាបាលទូទៅ តាមការទាមទាររបស់អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅ ជននៅក្រោមអាណាព្យាបាលទូទៅ សហព័ទ្ធរបស់ជននៅក្រោមអាណាព្យាបាលទូទៅ ញាតិនៅក្នុង៤(បួន) ថ្នាក់ របស់ជននៅក្រោមអាណាព្យាបាលទូទៅ មេឃុំ ឬចៅសង្កាត់នៃលំនៅឋានរបស់ជននៅក្រោមអាណាព្យាបាលទូទៅ តំណាងអយ្យការ ឬបុគ្គលផ្សេងៗទៀតដែលមានទំនាក់ទំនងនឹងផលប្រយោជន៍ ឬដោយឆន្ទានុសិទ្ធិ។

#### ២.២.៣.២ បុគ្គលដែលមិនអាចក្លាយជាអាណាព្យាបាលទូទៅ

មិនមែនគ្រប់មនុស្សទាំងអស់ អាចក្លាយជាអ្នកអាណាព្យាបាលទូទៅបាននោះទេ។ នៅក្នុងច្បាប់បានកំណត់ច្បាស់លាស់អំពីបុគ្គលមួយចំនួនដែលមិនអាចក្លាយជាអ្នកអាណាព្យាបាលទូទៅមានដូចជា៖[63]

---

[63] មាត្រា១១០៩ នៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧

ក. អនីតិជន ជននៅក្រោមអាណាព្យាបាលទូទៅ និងជននៅក្រោមហិតូបត្ថម្ភ។

ខ. អ្នកតំណាងដែលច្បាប់បានកំណត់ និងហិតូបត្ថម្ភកៈ ព្រមទាំងអ្នកត្រួតពិនិត្យជនទាំងនោះ ដែលធ្លាប់ត្រូវបានតុលាការដកចេញ។

គ. ជនដែលក្ស័យធន។

ឃ. ជនដែលគ្មានដំណឹងអំពីទីរស់នៅ។

ប្រសិនបើមានបុគ្គលណាម្នាក់ ដែលត្រូវនឹងលក្ខខណ្ឌតែមួយក្នុងចំណោមលក្ខខណ្ឌណាមួយខាងលើនេះ បុគ្គលនោះក៏មិនអាចក្លាយជាអ្នកអាណាព្យាបាលទូទៅបានឡើយ។ ទោះបីក្នុងករណីមានតែបុគ្គលម្នាក់ត្រូវបានកំណត់ធ្វើជាអ្នកអាណាព្យាបាលទូទៅ តាមរយៈមតកសាសន៍ក៏ដោយ ក៏បុគ្គលនោះមិនអាចក្លាយជាអ្នកអាណាព្យាបាលទូទៅបានទេ ប្រសិនបើបុគ្គលនោះត្រូវជាបុគ្គលនៅក្នុងចំណោមលក្ខខណ្ឌខាងលើ។

### ២.២.៤ ការផ្លាស់ប្តូរអ្នកអាណាព្យាបាលទូទៅ

មានហេតុផលពីរ ដែលអាចធ្វើការផ្លាស់ប្តូរអ្នកអាណាព្យាបាលទូទៅបាននោះគឺដោយការលាឈប់របស់អ្នកអាណាព្យាបាលទូទៅផ្ទាល់ និងការបញ្ឈប់អ្នកអាណាព្យាបាលទូទៅ។

#### ក. ការលាឈប់របស់អ្នកអាណាព្យាបាលទូទៅ

ប្រសិនបើមានមូលហេតុត្រឹមត្រូវ អ្នកអាណាព្យាបាលទូទៅ អាចលាឈប់បាន ដោយទទួលការអនុញ្ញាតពីតុលាការ[64]។ មូលហេតុត្រឹមត្រូវក្នុងន័យនេះ គឺសំដៅទៅលើហេតុផលសមស្រប និងត្រឹមត្រូវ រួមមានដូចជាដោយជម្ងឺ វ័យចំណាស់ និងការផ្លាស់ទីលំនៅទៅឆ្ងាយជាដើម។

ក្នុងករណីដែលអ្នកអាណាព្យាបាលទូទៅបានលាឈប់ តុលាការត្រូវជ្រើសតាំងអ្នកអាណាព្យាបាលទូទៅថ្មីទៀតឱ្យបានឆាប់រហ័ស ដើម្បីទទួលខុសត្រូវជននៅក្រោមអាណាព្យាបាលទូទៅបន្ត។ ចំពោះនីតិវិធីនៃការជ្រើសតាំងអ្នកអាណាព្យាបាលទូទៅថ្មីនេះ គឺដូចទៅនឹងការជ្រើសតាំងលើកដំបូងដែរ ( ដូចមានបង្ហាញនៅក្នុង **ជំពូកទី៣ ផ្នែកទី១ ចំណុច ២.២.៣ ការជ្រើសតាំងអ្នកអាណាព្យាបាលទូទៅ** )។

#### ខ. ការបញ្ឈប់អ្នកអាណាព្យាបាលទូទៅ

តុលាការក៏អាចបញ្ឈប់អ្នកអាណាព្យាបាលទូទៅបានផងដែរ ប្រសិនបើអ្នកអាណាព្យាបាលទូទៅនោះបានធ្វើសកម្មភាពពុំត្រឹមត្រូវ ឬមានហេតុផ្សេងទៀតដែលមិនសមរម្យនឹងភារកិច្ចជាអ្នកអាណាព្យាបាលទូទៅ បានតាមការទាមទាររបស់អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅ ជននៅក្រោមអាណាព្យាបាលទូទៅ សហព័ទ្ធ របស់ជននៅក្រោមអាណាព្យាបាលទូទៅ ញាតិនៅក្នុង ៤ (បួន) ថ្នាក់ របស់ជននៅក្រោមអាណាព្យាបាល

[64] មាត្រា១១០៦ នៃក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៧

ទូទៅ មេឃុំ ឬចៅសង្កាត់នៃលំនៅឋានរបស់ជននៅក្រោមអាណាព្យាបាលទូទៅតំណាងអយ្យការ ឬបុគ្គលផ្សេងទៀតដែលមានទំនាក់ទំនងទៅនឹងផលប្រយោជន៍ ឬដោយឆន្ទានុសិទ្ធិបាន ។

ចំពោះសកម្មភាពមិនត្រឹមត្រូវក្នុងន័យនេះ ចង់សំដៅទៅលើអំពើដែលមិនសមរម្យជាអ្នកអាណាព្យាបាលទូទៅ មានដូចជាការលួចបន្លំទ្រព្យសម្បត្តិរបស់នៅក្រោមអាណាព្យាបាលទូទៅ ការប្រើប្រាស់អំពើហិង្សា ការបៀតបៀន ការឆបោកលើជននៅក្រោមអាណាព្យាបាលទូទៅជាដើម។

## ៣. ការលុបចោលការប្រកាសចាប់ផ្ដើមអាណាព្យាបាលទូទៅ

នៅពេលដែលកង្វះសមត្ថភាពខាងឆន្ទៈរបស់ជននៅក្រោមអាណាព្យាបាលទូទៅមានសមត្ថភាពល្អឡើងវិញ មិនត្រូវបន្តនូវការកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពរបស់ពួកគេទៀតទេ។ ដូច្នេះ តុលាការត្រូវលុបចោលនូវការប្រកាសចាប់ផ្ដើមអាណាព្យាបាលទូទៅតាមពាក្យសុំរបស់ជនមួយចំនួនដែលមានចែងក្នុងមាត្រា ២៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

### ៣.១ លក្ខខណ្ឌ

យោងតាមមាត្រា ២៧ នៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧ ការលុបចោលការប្រកាសចាប់ផ្ដើមអាណា-ព្យាបាលទូទៅ បានចែងថា បើមូលហេតុដែលបានកំណត់នៅក្នុងមាត្រា ២៤ ( ការប្រកាសការចាប់ផ្ដើមអាណា-ព្យាបាលទូទៅ ) នៃក្រមនេះបានរលាយ តុលាការត្រូវលុបចោលនូវការប្រកាសចាប់ផ្ដើមអាណាព្យាបាលទូទៅតាមពាក្យសុំរបស់សាមីខ្លួន សហព័ទ្ធ ញាតិដែលស្ថិតនៅក្នុង ៤ (បួន) ថ្នាក់ អ្នកអាណាព្យាបាល អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាល មេឃុំ ឬចៅសង្កាត់នៃលំនៅឋានរបស់ជននោះ ឬតំណាងអយ្យការ ។

ដូចនេះ មានន័យថាលក្ខខណ្ឌដែលអាចលុបចោលការប្រកាសចាប់ផ្ដើមអាណាព្យាបាលទូទៅបាននោះគឺត្រូវគោរពតាមលក្ខខណ្ឌស្ថានភាពរបស់ជននៅក្រោមអាណាព្យាបាលទូទៅ។ កាលណាជននៅក្រោមអាណាព្យាបាលទូទៅមានស្មារតីដូចដើមឡើងវិញ មានស្ថានភាពក្នុងការយល់ដឹងឡើងវិញ ហើយអាចវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនបាននោះ អ្នកពាក់ព័ន្ធ អាចដាក់ពាក្យសុំទៅតុលាការបាន។

**ឧទាហរណ៍៖** A បានបាត់បង់ការចងចាំដោយសារគ្រោះថ្នាក់ចរាចរណ៍ ហើយត្រូវបានតុលាការប្រកាសចាប់ផ្ដើមអាណាព្យាបាលទូទៅនៅថ្ងៃទី០១ ខែសីហា ឆ្នាំ២០២១ បន្ទាប់មកនៅថ្ងៃទី០១ ខែសីហា ឆ្នាំ២០២៣ A បានដឹងស្មារតី និងចងចាំឡើងវិញ ដូច្នេះតុលាការមិនត្រូវកម្រិតសមត្ថភាព A ទៀតទេ ហើយ A អាចស្នើសុំលុបចោលការប្រកាសចាប់ផ្ដើមអាណាព្យាបាលទូទៅបាន។

### ៣.២ នីតិវិធីនៃការលុបចោល

ដើម្បីលុបចោលរបបការប្រកាសចាប់ផ្ដើមអាណាព្យាបាលទូទៅ ត្រូវគោរពតាមនីតិវិធីដូចតទៅ៖

#### ៣.២.១ ការដាក់ពាក្យសុំ

តុលាការ អាចប្រកាសលុបចោលការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅបានលុះត្រាតែមានពាក្យសុំទៅតុលាការ។ ដូច្នេះហើយ អ្នកពាក់ព័ន្ធត្រូវដាក់ពាក្យសុំទៅតុលាការមានសមត្ថកិច្ច ហើយអ្នកដែលអាចដាក់ពាក្យសុំនោះ មានដូចជា សាមីខ្លួនផ្ទាល់ សហព័ទ្ធរបស់ជនដែលស្ថិតនៅក្រោមអាណាព្យាបាលទូទៅ ញាតិដែលស្ថិតនៅក្នុង ៤ (បួន) ថ្នាក់ អ្នកអាណាព្យាបាល អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាល មេឃុំ ឬចៅសង្កាត់នៃលំនៅឋានរបស់ជននោះ ឬតំណាងអយ្យការ។

#### ៣.២.២ ការវិនិច្ឆ័យ និងការប្រកាសរបស់តុលាការ

តុលាការត្រូវវិនិច្ឆ័យអំពីស្ថានភាពក្នុងការយល់ដឹង ស្មារតីដឹងខុស ដឹងត្រូវ ការអាចវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនបានឡើងវិញរបស់ជននៅក្រោមអាណាព្យាបាលទូទៅ ដោយឆន្ទានុសិទ្ធិតាមពាក្យសុំរបស់អ្នកពាក់ព័ន្ធដែលច្បាប់បានកំណត់ ហើយតុលាការត្រូវចេញសេចក្តីសម្រេចដើម្បីបញ្ចប់ការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅនេះ។

## ផ្នែកទី២៖ សកម្មភាពរបស់ជននៅក្រោមអាណាព្យាបាលទូទៅ

ជាគោលការណ៍ ជននៅក្រោមអាណាព្យាបាលទូទៅមិនអាចធ្វើសកម្មភាពគតិយុត្តដោយឯករាជ្យបានទេ គឺត្រូវផ្ទេរឱ្យអ្នកតំណាងដែលច្បាប់បានកំណត់។ បើអនុវត្តផ្ទុយពីគោលការណ៍នេះ សកម្មភាពដែលអនុវត្តដោយជននៅក្រោមអាណាព្យាបាលទូទៅអាចត្រូវបានលុបចោល។

សកម្មភាពគតិយុត្ត គឺជាសកម្មភាពដែលបង្កើតឱ្យមានអានុភាពគតិយុត្តស្របតាមឆន្ទៈ ផ្អែកតាមរយៈការបង្ហាញឆន្ទៈ។

### ១. សកម្មភាពដែលជននៅក្រោមអាណាព្យាបាលទូទៅបានធ្វើហើយមិនអាចលុបចោលបាន

សកម្មភាពដែលធ្វើឡើងដោយជននៅក្រោមអាណាព្យាបាលទូទៅ ត្រូវបានកម្រិតដោយការយល់ព្រមរបស់អ្នកអាណាព្យាបាលទូទៅ ឬការផ្តល់សច្ចានុមតិ លើកលែងតែសកម្មភាពទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃរបស់ជននៅក្រោមអាណាព្យាបាលទូទៅ។

សកម្មភាពដែលជននៅក្រោមអាណាព្យាបាលទូទៅអាចធ្វើបានមានដូចខាងក្រោម៖

#### ១.១ សកម្មភាពដែលទាក់ទងនឹងជីវភាពប្រចាំថ្ងៃ

សកម្មភាពដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ គឺជាសកម្មភាពពាក់ព័ន្ធនឹងជីវភាពរស់នៅរាល់ថ្ងៃមានដូចជា ការទិញរបស់សម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ ម្ហូប ចំណីអាហារជាដើម។ មិនខុសគ្នាពីអនីតិជនឡើយប្រសិនបើយើងអនុញ្ញាតឱ្យលុបចោលនូវសកម្មភាពប្រភេទនេះ ទោះបីជាអ្នកនៅក្រោមអាណាព្យាបាលទូទៅ

មានសមត្ថភាពខាងឆន្ទៈឡើងមកវិញ ហើយមានបំណងធ្វើសកម្មភាពពាក់ព័ន្ធនឹងជីវភាពរស់នៅរាល់ថ្ងៃក៏ដោយ ក៏ភាគីម្ខាងទៀត នៃសកម្មភាពនោះបារម្ភថា សកម្មភាពនោះនឹងត្រូវបានលុបចោលវិញ ហើយមិនអាចធ្វើកិច្ចការជួញដូរជាមួយ ដែលធ្វើឱ្យមានការលំបាកដល់ជននៅក្រោមអាណាព្យាបាលទូទៅ។ ម៉្យាងទៀត មានភាពចាំបាច់ត្រូវគិតដល់សុវត្ថិភាព នៃកិច្ចការជួញដូររបស់ភាគីម្ខាងទៀត នៃកិច្ចការជួញដូរពាក់ព័ន្ធនឹងសកម្មភាពរស់នៅប្រចាំថ្ងៃ។ ហេតុនេះហើយបានជាច្បាប់ចែងមិនអាចលុបចោលនូវសកម្មភាពដែលទាក់ទងនឹងសកម្មភាពប្រចាំថ្ងៃ។ ដូចនេះសកម្មភាពដែលទាក់ទងនឹងជីវភាពប្រចាំថ្ងៃ ជននៅក្រោមអាណាព្យាបាលទូទៅអាចធ្វើបាន។

### ១.២ សកម្មភាពទាក់ទងនឹងការធ្វើមតកសាសន៍

នីតិជន ឬអនីតិជនដែលទទួលបានរបបអត្តាធីនភាព គឺជាបុគ្គលដែលមានសមត្ថភាព ក្នុងការធ្វើបណ្តាំមតកសាសន៍[65]។ នេះមានន័យថាបុគ្គលដែលជានីតិជនអាចធ្វើមតកសាសន៍បាន ទោះបីជាអ្នកនៅក្រោមអាណាព្យបាលទូទៅ ដែលទទួលបានការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅក៏ដោយ ក៏អាចធ្វើមតកសាសន៍បានផងដែរ ពីព្រោះពួកគេជានីតិជន។ ម៉្យាងវិញទៀត អ្នកនៅក្រោមអាណាព្យាបាលទូទៅ ក៏អាចមានពេលដែលបុគ្គលនោះជាសះស្បើយមួយរយៈឡើងវិញនូវសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យនូវលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនដែរ។ ក៏ប៉ុន្តែដើម្បីធ្វើមតកសាសន៍បាន ជននៅក្រោមអាណាព្យាបាលទូទៅត្រូវតែមានសមត្ថភាពខាងឆន្ទៈជាមុនសិន ហើយចំពោះការធ្វើមតកសាន៍របស់អ្នកនៅក្រោមអាណាព្យាបាលទូទៅ ជននោះត្រូវជាសះស្បើយមួយរយៈពេលឡើងវិញ នូវសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ហើយចាំបាច់ត្រូវមានវត្តមានរបស់វេជ្ជបណ្ឌិតយ៉ាងតិច ២នាក់ ហើយវេជ្ជ-បណ្ឌិតនោះទៀតសោត ត្រូវសរសេរបញ្ជាក់បន្ថែមលើលិខិតមតកសាសន៍នោះថា នៅពេលធ្វើមតកសាសន៍ម្ចាស់បណ្តាំ ពុំស្ថិតក្នុងស្ថានភាពខ្វះសមត្ថភាពខាងឆន្ទៈឡើយ។

មូលហេតុដែលជននៅក្រោមអាណាព្យាបាលទូទៅអាចធ្វើមតកសាសន៍ ( សកម្មភាពឯកតោភាគី ) បានដោយអ្នកអាណាព្យាបាលទូទៅមិនអាចលុបចោលបាននោះ ព្រោះដោយផ្អែកតាមមាត្រា១១៦៨ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីបានចែងថា « **សិទ្ធិលុបចោលតាមបញ្ញត្តិនៃមាត្រា ២៦ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីមតកសាសន៍** » ។ ហេតុនេះអាចបកស្រាយបានថា ជននៅក្រោមអាណាព្យាបាលទូទៅ អាចធ្វើមតកសាសន៍បាន ហើយអ្នកអាណាព្យាបាលទូទៅមិនអាចលុបចោលបានឡើយ។ មូលហេតុដែលមានការទទួលស្គាល់ជននៅក្រោមអាណាព្យាបាលទូទៅឱ្យធ្វើមតកសាសន៍បាននេះ ដោយសារតែមតកសាសន៍នោះនឹងមានអានុភាពក្រោយពេលដែលជននៅក្រោមអាណាព្យាបាលទូទៅនោះ បានទទួលមរណភាព ដូច្នេះ អានុភាពនៃ

[65] សៀវភៅជំនួយស្មារតី នីតិបេតិកភ័ណ្ឌ និងគ្រួសារ បោះពុម្ពផ្សាយលើកទី១ របស់ លោក ព្រំ រិទ្ធី

មតកសាសន៍នោះ មិនមានឥទ្ធិពលទៅលើជីវភាពរស់នៅរបស់បុគ្គលនោះទេ ម្យ៉ាងវិញទៀត មតកសាសន៍ ធ្វើឡើងដើម្បីចាត់ចែងទ្រព្យសម្បត្តិដែលមាន គឺមិនមែនដើម្បីឱ្យខ្ចីទ្រព្យថ្មីទៀត ជាអាទិ៍នោះទេ។

### ២. សកម្មភាពដែលជននៅក្រោមអាណាព្យាបាលទូទៅបានធ្វើហើយអាចលុបចោលបាន

សកម្មភាពរបស់ជននៅក្រោមអាណាព្យាបាលទូទៅ អាចលុបចោលបាន ទោះបីជាមានការយល់ព្រមពីអ្នកអាណាព្យាបាលទូទៅក៏ដោយ ក៏ជននៅក្រោមអាណាព្យាបាលទូទៅមិនអាចធ្វើសកម្មភាពដែលមានសុពលភាពតែម្នាក់ឯងបានទេ ហើយសូម្បីតែធ្វើកិច្ចសន្យាក៏ដោយ ក៏កិច្ចសន្យានោះអាចលុបចោលបានដែរ។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះសកម្មភាពដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ។[66]

ខុសគ្នាពីអនីតិជន សកម្មភាពដែលបានធ្វើដោយអ្នកនៅក្រោមអាណាព្យាបាលទូទៅ ទោះបីជាមានការយល់ព្រមពីអាណាព្យាបាលទូទៅក៏ដោយ ក៏អាចលុបចោលបានដែរ ព្រោះថាអ្នកនៅក្រោមអាណាព្យាបាលទូទៅជាជនខ្វះសមត្ថភាពខាងឆន្ទៈ ហេតុនេះហើយ ទោះបីជាអ្នកអាណាព្យាបាលទូទៅ បានយល់ព្រមដោយវិនិច្ឆ័យថា អ្នកនៅក្រោមអាណាព្យាបាលទូទៅនោះ មានសមត្ថភាពខាងឆន្ទៈឡើងមកវិញក៏ដោយ ក៏ប៉ុន្តែវាអាចបាត់បង់ម្តងទៀតនូវសមត្ថភាពខាងឆន្ទៈនោះ ពេលធ្វើសកម្មភាពក៏ថាបាន។

សកម្មភាពដែលជននៅក្រោមអាណាព្យាបាលទូទៅមិនអាចធ្វើបានមានដូចខាងក្រោម៖

#### ២.១ សកម្មភាពទាក់ទងនឹងការបង្កើតកិច្ចសន្យា

ជាគោលការណ៍ មិនថានៅក្រមរដ្ឋប្បវេណីថ្មី ឬក្នុងច្បាប់ពិសេសនោះទេ ការបង្កើតកិច្ចសន្យាណាក៏ដោយ អាចមានអានុភាព និងអនុវត្តបាន លុះត្រាតែគូភាគីនៃកិច្ចសន្យា គឺជាសមត្ថជន (ជនដែលមិនត្រូវបានកម្រិតសមត្ថភាព) ដែលមានសមត្ថភាពគ្រប់គ្រាន់ ដែលច្បាប់ទទួលស្គាល់ និងមានសិទ្ធិពេញលេញនៅក្នុងការធ្វើសកម្មភាព[67]ស្របតាមច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា។[68]

រាល់សកម្មភាពដែលទាក់ទងនឹងការធ្វើកិច្ចសន្យា ដែលបង្កើតឡើងដោយជននៅក្រោមអាណាព្យាបាលទូទៅឯកឯង គឺត្រូវចាត់ទុកថាមានវិការៈខាងសមត្ថភាពរបស់ភាគី ដែលជាហេតុនាំឱ្យកិច្ចសន្យា ឬសកម្មភាពទាំងនោះ អាចត្រូវបានគេលុបចោល។ ម៉្យាងវិញទៀត គ្រប់កិច្ចសន្យាទាំងអស់ ដែលជននៅក្រោមអាណា

[66] មាត្រា២៦ នៃក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៧

[67] មាត្រា១៥ នៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៧ និងសទ្ទានុក្រម ផ្នែករដ្ឋប្បវេណី ដកស្រង់ចេញពីសទ្ទានុក្រមពាក្យច្បាប់ខ្មែរ-អង់គ្លេស-បារាំង ផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី ដែលត្រូវបានរៀបចំដោយគណៈកម្មការបណ្ឌិត្យសភា ទទួលបន្ទុកអនុម័តពាក្យច្បាប់ និងបោះពុម្ពដោយទីស្តីការគណៈរដ្ឋមន្ត្រី ឆ្នាំ២០០៧ ។

[68] ក្រឹត្យ-ច្បាប់, លេខ ៣៨ ក្រ.ច, ២៨ តុលា ១៩៨៨, មាត្រា ៣

ព្យាបាលទូទៅបានធ្វើ ទោះបីជាមានការយល់ព្រមពីអ្នកអាណាព្យាបាលទូទៅក៏ដោយ ក៏អាចលុបចោលបានដែរ លើកលែងតែកិច្ចសន្យាដែលទាក់ទងនឹងសកម្មភាពប្រចាំថ្ងៃ។

**២.២ សកម្មភាពបណ្តឹង**

បណ្តឹងគឺជាពាក្យសុំទាមទារឱ្យតុលាការចេញសាលក្រម ដែលមានខ្លឹមសារកំណត់មួយ។[69] ក្រៅពីការកម្រិតសម្ថភាពនៅក្នុងការធ្វើសកម្មភាព ជននៅក្រោមអាណាព្យាបាលទូទៅ ក៏ត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពបណ្តឹងដោយខ្លួនឯងដែរ ដោយតម្រូវឱ្យមានអ្នកតំណាងដែលច្បាប់បានកំណត់ គឺអ្នកអាណាព្យាបាលទូទៅ។[70] ដូចនេះ ជននៅក្រោមអាណាព្យាបាលទូទៅ មិនអាចធ្វើសកម្មភាពបណ្តឹងដោយខ្លួនឯងបានទេ។

ទោះបីជាអនីតិជន ឬជននៅក្រោមអាណាព្យាបាលទូទៅ គឺជាជនដែលត្រូវបានចាត់ទុកថា មិនអាចធ្វើសកម្មភាពបណ្តឹងដោយខ្លួនឯងបានក៏ដោយ នៅក្នុងបណ្តឹងឋានៈបុគ្គល គឺត្រូវធ្វើសកម្មភាពដោយផ្អែកលើឆន្ទៈរបស់សាមីខ្លួន មិនមែនអ្នកតំណាងនោះទេ ដូចនេះគឺមានសមត្ថភាពក្នុងការធ្វើបណ្តឹង។ ប៉ុន្តែតាមការពិត អាចបណ្តាលឱ្យខូចប្រយោជន៍ពួកគេ ដូចនេះ តុលាការអាចជ្រើសតាំងមេធាវីធ្វើជាអ្នកតំណាងដោយអាណត្តិឱ្យភាគីតាមពាក្យសុំ ឬដោយឆន្ទានុសិទ្ធិ។

## ផ្នែកទី៣៖ នីតិវិធីនៃការលុបចោលសកម្មភាព

សកម្មភាពដែលអាចលុបចោលបាន មានសុពលភាពរហូតដល់ពេលដែលអ្នកមានសិទ្ធិលុបចោល លុបចោលសកម្មភាពនោះ។ ដើម្បីលុបចោលសកម្មភាពរបស់ជននៅក្រោមអាណាព្យាបាលទូទៅបានត្រូវគោរពតាមលក្ខខណ្ឌមួយចំនួនដូចតទៅ៖

**១. លក្ខខណ្ឌ**

**១.១ សកម្មភាពដែលអាចលុបចោលបាន**

គ្រប់សកម្មភាពទាំងអស់ដែលបានធ្វើដោយជននៅក្រោមអាណាព្យាបាលទូទៅ ហើយមិនទទួលបានការអនុញ្ញាត ឬយល់ព្រមពីអ្នកព្យាបាលទូទៅ អាចលុបចោលសកម្មភាពនោះបាន លើកលែងតែសកម្មភាពទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ ដើម្បីការពារផលប្រយោជន៍របស់ជននៅក្រោមអាណាព្យាបាលទូទៅ។

សកម្មភាពដែលបានធ្វើដោយអ្នកនៅក្រោមអាណាព្យាបាលទូទៅ ដោយមានការយល់ព្រមពីអ្នកអាណាព្យាបាលទូទៅ ក៏អាចលុបចោលបានដែរ ដោយសារតែអ្នកនៅក្រោមអាណាព្យាបាលទូទៅ ជាជនដែលខ្វះ

[69] មេរៀន ការតាក់តែងបណ្តឹងរដ្ឋប្បវេណី ឧទ្ទេសនាមដោយ៖ លោក **វ៉ាន់ សុបញ្ញា** ចៅក្រមសាលាដំបូងខេត្តកណ្តាល

[70] មាត្រា៣២ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា

សមត្ថភាពខាងឆន្ទៈ ហេតុនេះហើយទោះបីជាអ្នកអាណាព្យាបាលទូទៅ បានយល់ព្រមដោយវិនិច្ឆ័យថាអ្នកនៅក្រោមអាណាព្យាបាលទូទៅនោះ មានសមត្ថភាពខាងឆន្ទៈឡើងវិញក៏ដោយ ក៏ប៉ុន្តែវាអាចបាត់បង់ម្តងទៀតនូវសមត្ថភាពខាងឆន្ទៈនោះ នាពេលធ្វើសកម្មភាពក៏ថាបាន។

**១.២ បុគ្គលដែលមានសិទ្ធិលុបចោល**

ចំពោះការលុបចោលបានអនុញ្ញាត គឺចំពោះតែអ្នកដែលមានសិទ្ធិលុបចោលប៉ុណ្ណោះ ទើបអាចលុបចោលសកម្មភាពបាន។ អ្នកដែលមានសិទ្ធិលុបចោលសកម្មភាពមានសាមីខ្លួន ( ជននៅក្រោមអាណាព្យាបាលទូទៅផ្ទាល់ ឬអ្នកអាណាព្យាបាលទូទៅ។ ដើម្បីលុបចោលសកម្មភាពបាន អ្នកដែលមានបំណងលុបចោលសកម្មភាពនោះ គ្រាន់តែបង្ហាញឆន្ទៈថាលុបចោលគឺគ្រប់គ្រាន់។

**១.៣ រយៈពេលដែលអាចលុបចោល**

ចំពោះរយៈពេលពេលនៃការលុបចោលនេះ ក៏មិនខុសអ្វីពីអនីតិជនដែរ ច្បាប់បានកំណត់រយៈពេល ៣ឆ្នាំ ដើម្បីធ្វើការលុបចោលសកម្មភាពនោះ។ ដើម្បីយល់កាន់តែច្បាស់សូមមើលនៅ **ជំពូកទី២ អនីតិជន ផ្នែកទី២ ចំណុច ១.៣ រយៈពេលដែលអាចលុបចោល**។

**២. នីតិវិធីនៃការបង្ហាញឆន្ទៈលុបចោល**

ដើម្បីលុបចោលសកម្មភាពបាន អ្នកដែលមានបំណងលុបចោលសកម្មភាពនោះ គ្រាន់តែបង្ហាញឆន្ទៈថាលុបចោលគឺគ្រប់គ្រាន់។ ការបង្ហាញឆន្ទៈនេះ ត្រូវធ្វើឡើងដោយការជូនដំណឹងទៅភាគីម្ខាងទៀត ហើយអានុភាពនៃការលុបចោល ត្រូវកើតឡើងនៅពេលដែលដំណឹងនោះបានដល់ភាគីម្ខាងទៀតដូចបានបញ្ជាក់នៅក្នុង **ជំពូកទី២ អនីតិជន ផ្នែកទី២ ចំណុច ២ នីតិវិធីនៃការបង្ហាញឆន្ទៈ** ។

**៣. អានុភាព**

អានុភាពនៃការលុបចោលកើតមានឡើងនៅពេលដែលការជូនដំណឹងនោះបានទៅដល់ភាគីម្ខាងទៀត។ នៅពេលដែលសកម្មភាពមួយត្រូវបានគេលុបចោល សកម្មភាពនេះ ត្រូវបានគេចាត់ទុកជាមោឃៈតាំងពីដំបូង ដូចមានបង្ហាញនៅ**ជំពូកទី២ អនីតិជន ផ្នែកទី២ ចំណុច ៣ អានុភាព**ដែរ។

## ផ្នែកទី៤៖ យន្តការ និងការការពារភាគីម្ខាងទៀត

**១. ការដាស់តឿន**

ជាបឋម ក្នុងករណីដែលជននៅក្រោមអាណាព្យាបាលទូទៅ មិនទាន់មានសមត្ថភាពល្អប្រសើរឡើងវិញ ភាគីម្ខាងទៀតអាចធ្វើការដាស់តឿន ចំពោះជនដែលបំពេញបន្ថែមនូវសមត្ថភាពរបស់ជននោះបាន ដើម្បីឱ្យបញ្ជាក់ច្បាស់លាស់ថា តើផ្តល់ ឬមិនផ្តល់សច្ចានុមតិលើសកម្មភាពដែលអាចលុបចោលបាន រីឯអ្នកដែលការពារជននៅក្រោមអាណាព្យាបាលទូទៅនោះវិញ ពេលដែលបានទទួលការដាស់តឿនហើយ ក៏ចាំបាច់មានពេល

ផលាមួយដើម្បីពិចារណាមើលដែរ ហេតុនេះហើយច្បាប់បានបញ្ញត្តិការដាស់តឿននេះ ត្រូវបានកំណត់នូវអំឡុងពេលយ៉ាងតិចមួយខែ ។ ចំពោះការដាស់តឿននេះ ត្រូវចាត់ចែងទៅតាមចម្លើយ បើមានចម្លើយអំពីការផ្តល់ ឬមិនផ្តល់នូវសច្ចានុមតិ ហើយប្រសិនបើមិនមានចម្លើយទេ ត្រូវចាត់ទុកថាបានផ្តល់សច្ចានុមតិ ដូចមានបង្ហាញនៅក្នុង **ជំពូកទី២ ផ្នែកទី៣ ចំណុច ១ ការដាស់តឿន**។

**២. ការឆបោក**

ជាមូលដ្ឋាន ប្រសិនបើការការពារជនដែលត្រូវបានកម្រិតសមត្ថភាព ត្រូវបានគេសង្កត់ធ្ងន់នោះគឺទំហំនៃវិធីឆបោកនឹងត្រូវបានកម្រិត។[71]មធ្យោបាយឆបោក គឺជាវិធីបោកបញ្ឆោតដើម្បីធ្វើឱ្យភាគីម្ខាងទៀតជឿថាជនដែលត្រូវបានកម្រិតសមត្ថភាពនោះ មានសមត្ថភាពក្នុងការធ្វើសកម្មភាព។

ក្នុងករណីដែលជននៅក្រោមអាណាព្យាបាលទូទៅ បានប្រើវិធីឆបោក ធ្វើឱ្យភាគីម្ខាងទៀត យល់ច្រឡំថាខ្លួនជាសមត្ថជន ហើយធ្វើកិច្ចសន្យាជួញដូរជាមួយនោះ មិនចាំបាច់ការពារជននៅក្រោមអាណាព្យាបាលទូទៅនោះទេ ដូច្នេះក្នុងករណីនេះ មិនត្រូវទទួលស្គាល់ឱ្យលុបចោលឡើយ។ ការវិនិច្ឆ័យថាតើសកម្មភាពប្រភេទណាជាការឆបោកនោះ គឺត្រូវមើលទៅតាមស្ថានភាពនីមួយៗ ដូចជា តើជនដែលបានធ្វើសកម្មភាពជាជនដែលត្រូវបានកម្រិតនូវសមត្ថភាពប្រភេទណាដែរ ខ្លឹមសារនៃសកម្មភាពនោះយ៉ាងណាដែរ ប្រភេទនៃសកម្មភាពរបស់ជនដែលត្រូវបានកម្រិតនូវសមត្ថភាពនោះយ៉ាងណាដែរ ។

**២.១ លក្ខខណ្ឌ**

លក្ខខណ្ឌដែលជននៅក្រោមអាណាព្យាបាលទូទៅបានប្រើមធ្យោបាយឆបោកនោះគឺ ជននៅក្រោមអាណាព្យាបាលទូទៅបានប្រើមធ្យោបាយឆបោក មធ្យោបាយឆបោកត្រូវប្រើដោយទាក់ទងនឹងសមត្ថភាពក្នុងការធ្វើសកម្មភាព ជនដែលត្រូវបានកម្រិតសមត្ថភាពបានប្រើមធ្យោបាយឆបោកដោយមានចេតនា និងភាគីម្ខាងទៀតត្រូវបានជឿទុកចិត្តថា ជននៅក្រោមអាណាព្យាបាលទូទៅ គឺជាជនដែលមានសមត្ថភាពពេញលេញ។

ចំពោះលក្ខខណ្ឌទាំងនេះ តម្រូវឱ្យមានជាពិសេសទំនាក់ទំនងហេតុ និងផលរវាងមធ្យោបាយឆបោក និងការជឿជាក់ទៅលើភាពមិនពិត។ (ដូចមានបញ្ជាក់នៅ**ជំពូកទី២ ផ្នែកទី៣ ចំណុច ២.១ លក្ខខណ្ឌ**) ។

**២.២ អានុភាព**

បើជននៅក្រោមអាណាព្យាបាលទូទៅបានប្រើមធ្យោបាយឆបោក ធ្វើឱ្យភាគីម្ខាងទៀតទុកចិត្តរហូតឈានដល់ចុះកិច្ចសន្យានោះ អានុភាពនៃសកម្មភាពរបស់ជននៅក្រោមអាណាព្យាបាលទូទៅ មិនអាចលុបចោលកិច្ចសន្យានោះបានទេ។ (សូមមើលបន្ថែមនៅ**ជំពូកទី២ ផ្នែកទី៣ ចំណុច ២.២ អានុភាព** ) ។

[71] សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ដែលរៀបចំដោយក្រុមការងារនៃអនាគតគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ

# ជំពូកទី ៤

# ជននៅក្រោមហិតូបត្ថម្ភ

# ជំពូកទី ៤

# ជននៅក្រោមហិតូបត្ថម្ភ

## ផ្នែកទី១៖ របបហិតូបត្ថម្ភ

### ១. និយមន័យ

ហិតូបត្ថម្ភ គឺជាប្រព័ន្ធមួយសម្រាប់ការពារបុគ្គលដែលមានសមត្ថភាពតិចតួចពេកក្នុងការយល់ដឹង និង វិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់ នៃសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី ហើយមានតែតុលាការទេទើបអាចប្រកាសចាប់ផ្តើមហិតូបត្ថម្ភបាន។ ជននៅក្រោមហិតូបត្ថម្ភ គឺជាអ្នកដែលមានសមត្ថភាពតិចតួចពេក[72]ក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី មានន័យថាអ្នកដែលគ្រាន់តែអាចទិញរបស់របរសម្រាប់ជីវភាពប្រចាំថ្ងៃតែប៉ុណ្ណោះ ប៉ុន្តែមិនអាចធ្វើកិច្ចសន្យាសំខាន់ៗ ដោយឯកឯងបាន ហើយចាំបាច់មានជំនួយពីអ្នកផ្សេងជានិច្ចកាល ដូចជាជនមានជំងឺទាក់ទងនឹងប្រព័ន្ធប្រសាទ ជាអាទិ៍។

ហិតូបត្ថម្ភមានលក្ខណៈខុសពីអាណាព្យាបាលទូទៅត្រង់ថា ជននៅក្រោមអាណាព្យាបាលទូទៅស្ថិតក្នុងស្ថានភាពជានិរន្តរ៍ដែលខ្វះសមត្ថភាពក្នុងការវិនិច្ឆ័យ ចំណែកឯជននៅក្រោមហិតូបត្ថម្ភមិនមានសមត្ថភាពគ្រប់គ្រាន់ក្នុងការវិនិច្ឆ័យ។ អាស្រ័យហេតុនេះស្ថានភាពស្មារតីរបស់ជននៅក្រោមអាណាព្យាបាលទូទៅ មានលក្ខណៈធ្ងន់ធ្ងរជាងស្ថានភាពស្មារតីរបស់ជននៅក្រោមហិតូបត្ថម្ភ។ លើសពីនេះទៀត ដោយសារវិបត្តិនានាទាំងឡាយនេះ ជននៅក្រោមអាណាព្យាបាលទូទៅស្ថិតនៅក្នុងស្ថានភាពដែលមានការបង្កការរំខានដល់ជីវភាពប្រចាំថ្ងៃ និងស្ថានភាពដែលទាមទារឱ្យមានការបីបាច់ថែរក្សារូបកាយរបស់ខ្លួន។ ផ្ទុយទៅវិញ ជននៅក្រោមហិតូបត្ថម្ភទទួលការយល់ព្រមពីហិតូបត្ថម្ភកៈចំពោះសកម្មភាពជាក់លាក់មួយចំនួនដែលទាមទារឱ្យមានសមត្ថភាពគ្រប់គ្រាន់ក្នុងការយល់ដឹងតែប៉ុណ្ណោះ ដោយផ្អែកលើមូលដ្ឋានថា ជននៅក្រោមហិតូបត្ថម្ភអាចដឹកនាំជីវភាពប្រចាំថ្ងៃដោយផ្ទាល់ខ្លួនបាន។

### ២. ការប្រកាសចាប់ផ្តើមហិតូបត្ថម្ភ

ការប្រកាសចាប់ផ្តើមហិតូបត្ថម្ភ គឺមាននីតិវិធីជាច្រើន ហើយមិនមែនគ្រប់បុគ្គលទាំងអស់អាចធ្វើការប្រកាសបាននោះទេ។ ដើម្បីធ្វើការប្រកាសចាប់ផ្តើមរបបហិតូបត្ថម្ភបាន យើងគប្បីយល់អំពីលក្ខខណ្ឌមួយចំនួនដើម្បីអាចក្លាយជាជននៅហិតូបត្ថម្ភ និងនីតិវិធីដើម្បីទទួលបានរបបហិតូបត្ថម្ភនេះជាមុនសិន។

[72] សមត្ថភាពតិចតួចពេក សំដៅថាមានសមត្ថភាពខាងឆន្ទៈដែរ តែសមត្ថភាពវិនិច្ឆ័យដែលទាក់ទងនឹងការគ្រប់គ្រងទ្រព្យសម្បត្តិ គឺទាបខ្លាំងជាងធម្មតា។

### ២.១ លក្ខខណ្ឌដែលអាចក្លាយជាជននៅក្រោមហិតូបត្ថម្ភ

ដើម្បីប្រកាសចាប់ផ្តើមហិតូបត្ថម្ភបាន លុះត្រាតែជននោះ គឺជាជនដែលមានសមត្ថភាពតិចតួចពេកក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី។ ជននៅក្រោមហិតូបត្ថម្ភអាចជា មនុស្សចាស់ជរា ដែលឧស្សាហ៍ភ្លេចភ្លាំងជាដើម។

### ២.២ នីតិវិធីដើម្បីទទួលបានរបបហិតូបត្ថម្ភ

#### ២.២.១ ការស្នើសុំ

ជននៅក្រោមហិតូបត្ថម្ភ មិនអាចធ្វើការសន្មតដោយខ្លួនឯង ឬសន្មតដោយអ្នកមានអំណាចមេបា ឬអ្នកគ្រប់គ្រងឡើយ។ ដើម្បីទទួលបានរបបហិតូបត្ថម្ភនេះបាន លុះត្រាតែមានពាក្យសុំទៅតុលាការមានសមត្ថកិច្ចដូចទៅនឹងរបបអាណាព្យាបាលទូទៅដែរ។ តុលាការអាចប្រកាសការចាប់ផ្តើមហិតូបត្ថម្ភលើជននោះបានតាមពាក្យសុំរបស់សាមីខ្លួន សហព័ទ្ធ ញាតិដែលស្ថិតក្នុង ៤ (បួន)ថ្នាក់ អ្នកអាណាព្យាបាល អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាល មេឃុំ ឬចៅសង្កាត់នៃលំនៅឋានរបស់ជននោះ ឬតំណាងអយ្យការ។

ប្រសិនបើតុលាការធ្វើការប្រកាសចំពោះជនដែលធ្លាប់ស្ថិតនៅក្រោមអាណាព្យាបាលទូទៅនោះ អ្នកអាណាព្យាបាល អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាល ត្រូវបានបញ្ចូលជាអ្នកដែលមានសិទ្ធិដាក់ពាក្យសុំឱ្យចាប់ផ្តើមហិតូបត្ថម្ភនេះផងដែរ គឺដោយសារតែគិតដល់ករណីដែលពិការភាពខាងផ្លូវចិត្តរបស់ជនដែលធ្លាប់នៅក្រោមអាណាព្យាបាលទូទៅបានធូរស្រាល ហើយត្រូវប្តូរឱ្យទៅនៅក្រោមរបបហិតូបត្ថម្ភវិញ។ ម៉្យាងវិញទៀត ដើម្បីកុំឱ្យមានអំឡុងពេលមួយដែលគ្មានការការពារ នៅពេលដែលអនីតិជនដែលមានពិការភាពខាងបញ្ញា ឬខាងផ្លូវចិត្តក្លាយជានីតិជននោះ ទើបច្បាប់បានអនុញ្ញាតឱ្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន និងអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជនដែលត្រូវបានជ្រើសតាំងសម្រាប់អនីតិជននោះ ដាក់ពាក្យសុំឱ្យចាប់ផ្តើមហិតូបត្ថម្ភបាន។

#### ២.២.២ ការវិនិច្ឆ័យ និងការប្រកាសរបស់តុលាការ

កាលណាមានពាក្យសុំទៅតុលាការមានសមត្ថកិច្ច ហើយតុលាការបានវិនិច្ឆ័យថាជននោះជាជនដែលមានសមត្ថភាពតិចតួចពេកក្នុងការយល់ដឹង និងវិនិច្ឆ័យ ដោយសារមានវិបត្តិផ្នែកស្មារតីពិតមែនតុលាការត្រូវចេញដីកាសម្រេចដើម្បីបញ្ចប់នីតិវិធី។ តុលាការត្រូវពិនិត្យមើលស្ថានភាពជាក់ស្តែងរបស់ជននោះ ដើម្បីអាចធ្វើការ វិនិច្ឆ័យនូវការចាប់ផ្តើមហិតូបត្ថម្ភ ហើយជ្រើសតាំងអ្នកដែលសមរម្យឱ្យធ្វើជាហិតូបត្ថម្ភកៈ។

ហិតូបត្ថម្ភកៈ គឺមានសិទ្ធិអំណាចក្នុងការយល់ព្រមឱ្យជននៅក្រោមហិតូបត្ថម្ភអាចធ្វើសកម្មភាពដែលបានកំណត់នៅក្នុងមាត្រា ៣០ នៃក្រមរដ្ឋប្បវេណី (សិទ្ធិលុបចោលសកម្មភាព) (មានមូលហេតុនៃការលុបចោល

បាន) (ដូចមានបង្ហាញនៅ **ជំពូកទី៤ ផ្នែកទី ២ ចំណុច ១.៣ សកម្មភាពដែលផ្ទុយនឹងបញ្ញត្តនៅក្នុងមាត្រា ៣០ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧** )។

### ២.២.២ ការជ្រើសតាំងហិតូបត្ថម្ភកៈ

ការជ្រើសតាំងហិតូបត្ថម្ភកៈ មិនមែននរណាក៏អាចជ្រើសតាំងបាននោះទេ ហើយដើម្បីធ្វើជាហិតូបត្ថម្ភកៈក៏ត្រូវគោរពនូវលក្ខខណ្ឌមួយចំនួនផងដែរ។ កថាខណ្ឌទី២ នៃមាត្រា ១១៣៧ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ដែលចែងអំពីការជ្រើសតាំងហិតូបត្ថម្ភកៈ គឺត្រូវយកមកអនុវត្តដូចគ្នានឹងការជ្រើសតាំងអាណាព្យាបាលទូទៅចាប់ពីមាត្រា ១១០៥ រហូតដល់ មាត្រា ១១០៩ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ ដែរ។

#### ២.២.២.១ បុគ្គលដែលអាចត្រូវបានជ្រើសតាំង

អ្នកដែលមានសិទ្ធិជ្រើសតាំង គឺតុលាការ។ ប្រសិនបើប្រកាសការចាប់ផ្តើមហិតូបត្ថម្ភ តុលាការត្រូវជ្រើសតាំងហិតូបត្ថម្ភកៈដោយឆន្ទានុសិទ្ធិ[73]។ ដើម្បីជ្រើសតាំងហិតូបត្ថម្ភកៈ តុលាការត្រូវគិតពិចារណាអំពីស្ថានភាពផ្លូវកាយ ផ្លូវចិត្ត ស្ថានភាពជីវភាព និងទ្រព្យសម្បត្តិរបស់ជននៅក្រោមហិតូបត្ថម្ភ វិជ្ជាជីវៈ និងប្រវត្តិរូបរបស់អ្នកដែលត្រូវធ្វើជាហិតូបត្ថម្ភកៈ និងអត្ថិភាព ឬនត្ថិភាព នៃទំនាក់ទំនងទៅនឹងផលប្រយោជន៍ រវាងហិតូបត្ថម្ភកៈ និងជននៅក្រោមហិតូបត្ថម្ភ និងយោបល់របស់ជននៅក្រោមហិតូបត្ថម្ភ និងស្ថានភាពផ្សេងៗទៀតទាំងស្រុង។ ក្នុងករណីដែលហិតូបត្ថម្ភកៈជានីតិបុគ្គល តុលាការត្រូវគិតពិចារណាផងដែរអំពីប្រភេទ និងខ្លឹមសារនៃកិច្ចការរបស់នីតិបុគ្គល និងអត្ថិភាព ឬនត្ថិភាព នៃទំនាក់ទំនងទៅនឹងផលប្រយោជន៍ រវាងនីតិបុគ្គល និងអ្នកតំណាងរបស់នីតិបុគ្គលនោះ និងជននៅក្រោមហិតូបត្ថម្ភ។

ប្រសិនបើខ្វះហិតូបត្ថម្ភកៈ ឬហិតូបត្ថម្ភកៈ ដែលបានជ្រើសតាំងពីអតីតកាលនោះបានទទួលមរណភាព ហើយមានការចាំបាច់ត្រូវជ្រើសតាំងអ្នកហិតូបត្ថម្ភកៈថ្មី តុលាការត្រូវជ្រើសតាំងហិតូបត្ថម្ភកៈ តាមការទាមទាររបស់អ្នកត្រួតពិនិត្យហិតូបត្ថម្ភកៈ ជននៅក្រោមហិតូបត្ថម្ភផ្ទាល់ សហព័ទ្ធរបស់ជននៅក្រោមហិតូបត្ថម្ភ ញាតិនៅក្នុង៤(បួន) ថ្នាក់ របស់ជននៅក្រោមហិតូបត្ថម្ភ មេឃុំ ឬចៅសង្កាត់នៃលំនៅឋានរបស់ជននៅក្រោមហិតូបត្ថម្ភ តំណាងអយ្យការ ឬបុគ្គលផ្សេងៗទៀតដែលមានទំនាក់ទំនងនឹងផលប្រយោជន៍ ឬដោយឆន្ទានុសិទ្ធិ។

ហិតូបត្ថម្ភកៈ មិនត្រូវបានកម្រិតចំនួនដូចអ្នកអាណាព្យាបាលទូទៅដែរ ដូចនេះតុលាការអាចជ្រើសតាំងហិតូបត្ថម្ភកៈ លើសពីម្នាក់បាន។ នៅក្នុងរបបហិតូបត្ថម្ភនេះ មិនថារូបវន្តបុគ្គល ឬនីតិបុគ្គលសុទ្ធសឹងតែអាចក្លាយជាហិតូបត្ថម្ភកៈបានទាំងអស់។ ម៉្យាងទៀតតុលាការក៏អាចជ្រើសតាំងហិតូបត្ថម្ភកៈ ដែលម្នាក់ជារូបវន្តបុគ្គល ឯម្នាក់ទៀតជានីតិបុគ្គលបានផងដែរ។

---

73 មាត្រា១១៣៧ នៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧

មាត្រា ១១៣៧ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី ចែងអំពីសកម្មភាពដែលផលប្រយោជន៍របស់ហិតូបត្ថម្ភកៈ ឬជនដែលហិតូបត្ថម្ភកៈនោះធ្វើតំណាងឱ្យ និងជននៅក្រោមហិតូបត្ថម្ភ មានភាពផ្ទុយគ្នា ហិតូបត្ថម្ភកៈត្រូវទាមទារឱ្យតុលាការជ្រើសតាំងហិតូបត្ថម្ភកៈជាបណ្តោះអាសន្ន ។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយចំពោះករណីដែលមានអ្នកត្រួតពិនិត្យហិតូបត្ថម្ភកៈ។ កថាខណ្ឌទី៣ នេះ អ្នកតាក់តែងច្បាប់បានប្រមើលមើលនូវករណីមួយចំនួន ជាទូទៅចំពោះសកម្មភាពដែលផលប្រយោជន៍របស់ហិតូបត្ថម្ភកៈ និងជននៅក្រោមហិតូបត្ថម្ភមានភាពផ្ទុយគ្នាសំដៅលើករណីដូចជា ការលក់ទិញរវាងជននៅក្រោមហិតូបត្ថម្ភ និងហិតូបត្ថម្ភកៈ ត្រូវបានធ្វើឡើងចំពោះអចលនវត្ថុដែលជាកម្មសិទ្ធិរបស់ជននៅក្រោមហិតូបត្ថម្ភ ចំណែកឯសកម្មភាពដែលផលប្រយោជន៍របស់ជនដែលហិតូបត្ថម្ភកៈធ្វើតំណាងឱ្យ និងជននៅក្រោមហិតូបត្ថម្ភមានភាពផ្ទុយគ្នា មានដូចជាករណីដែលហិតូបត្ថម្ភកៈ មានកូនដែលជាអនីតិជន និងហិតូបត្ថម្ភកៈក្លាយជាអ្នកតំណាងរបស់កូននោះ តាមការអនុវត្តអំណាចមេបា ហើយការលក់ទិញអចលនវត្ថុរវាងកូននោះ និងជននៅក្រោមហិតូបត្ថម្ភត្រូវបានធ្វើឡើង។ ក្នុងករណីនេះ តាមភាពជាក់ស្តែងការលក់ទិញនេះអាចត្រូវបានវាយតម្លៃថាជាប្រតិបត្តិការរវាងហិតូបត្ថម្ភកៈ និងជននៅក្រោមហិតូបត្ថម្ភ។ ដើម្បីការពារផលប្រយោជន៍ដល់ជននៅក្រោមហិតូបត្ថម្ភចំពោះប្រតិបត្តិការនេះ បញ្ញត្តិនេះតម្រូវឱ្យមានការជ្រើសតាំងហិតូបត្ថម្ភកៈជាបណ្តោះអាសន្នសិន ហើយដកហិតូបត្ថម្ភកៈពីតួនាទីចំពោះប្រតិបត្តិការនោះមួយរយៈ។ ចំពោះសកម្មភាពដែលផលប្រយោជន៍ផ្ទុយគ្នា រវាងជននៅក្រោមហិតូបត្ថម្ភច្រើននាក់ ដែលស្ថិតនៅក្រោមហិតូបត្ថម្ភកៈដូចគ្នាក៏ត្រូវបានអនុវត្តដូចទៅនឹងករណីខាងលើដែរ។

### ២.២.២.២ បុគ្គលដែលមិនអាចក្លាយជាហិតូបត្ថម្ភកៈ

មិនខុសអ្វីពីរបបអាណាព្យាបាលទូទៅឡើយ ដោយយោងតាមមាត្រា ១១៣៧ កថាខណ្ឌទី២ បានបញ្ញត្តិអំពីមាត្រា ១១០៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះហិតូបត្ថម្ភ។ ដូចនេះបុគ្គលដែលមិនអាចក្លាយជាហិតូបត្ថម្ភកៈមានដូចដែលបានរៀបរាប់នៅ**ជំពូកទី៣ ផ្នែកទី២ ចំណុច ២.២.៣.២ បុគ្គលដែលមិនអាចក្លាយជាអាណាព្យាបាលទូទៅ** ដែរ។

ប្រសិនបើមានបុគ្គលណាម្នាក់ ដែលត្រូវនឹងលក្ខខណ្ឌតែមួយក្នុងចំណោមលក្ខខណ្ឌណាមួយខាងលើនេះ បុគ្គលនោះក៏មិនអាចក្លាយជាហិតូបត្ថម្ភកៈបានឡើយ។

### ២.២.៤ ការផ្លាស់ប្តូរហិតូបត្ថម្ភកៈ

ដូចគ្នាទៅនឹងរបបអាណាព្យាបាលទូទៅដែរ ដើម្បីធ្វើការផ្លាស់ប្តូរហិតូបត្ថម្ភកៈបាន លុះត្រាតែមានមូលហេតុច្បាស់លាស់ ដែលកំណត់ក្នុងច្បាប់។ មូលហេតុដែលធ្វើការផ្លាស់ប្តូរហិតូបត្ថម្ភកៈបាន មាន២ គឺផ្លាស់ប្តូរដោយការលាឈប់របស់ហិតូបត្ថម្ភកៈផ្ទាល់ និងការបញ្ឈប់ហិតូបត្ថម្ភកៈ។

**ក. ការលាឈប់របស់ហិតូបត្ថម្ភកៈ**

ហិតូបត្ថម្ភកៈក៏អាចលាឈប់ដោយខ្លួនឯងបានផងដែរ ប្រសិនបើពួកគេមានហេតុផលសមរម្យ សមស្រប ដែលតុលាការអាចទទួលយកបាន និងទទួលការយល់ព្រម និងអនុញ្ញាតពីតុលាការ[74]។

**ខ. ការបញ្ឈប់ហិតូបត្ថម្ភកៈ**

តុលាការអាចបញ្ឈប់ហិតូបត្ថម្ភកៈ ប្រសិនបើហិតូបត្ថម្ភកៈនោះបានធ្វើសកម្មភាពពុំត្រឹមត្រូវ ឬមានមូលហេតុផ្សេងទៀតដែលមិនសមរម្យនឹងភារកិច្ចជាហិតូបត្ថម្ភកៈបាន តាមការទាមទាររបស់អ្នកត្រួតពិនិត្យហិតូបត្ថម្ភកៈ ជននៅក្រោមហិតូបត្ថម្ភ សហព័ទ្ធរបស់ជននៅក្រោមហិតូបត្ថម្ភ ញាតិនៅក្នុង ៤ (បួន) ថ្នាក់ របស់ជននៅក្រោមហិតូបត្ថម្ភ មេឃុំ ឬចៅសង្កាត់នៃលំនៅឋានរបស់ជននៅក្រោមហិតូបត្ថម្ភ តំណាងអយ្យការ ឬបុគ្គលផ្សេងទៀតដែលមានទំនាក់ទំនងទៅនឹងផលប្រយោជន៍ ឬដោយឆន្ទានុសិទ្ធិបាន ។

អំពើពុំត្រឹមត្រូវនោះអាចជា ការឆបោក ការបន្លំ ការលួចទ្រព្យសម្បត្តិជននៅក្រោមហិតូបត្ថម្ភ ឬការបំពានហិតូបត្ថម្ភជាដើម។

## ៣. ការលុបចោលការប្រកាសចាប់ផ្ដើមហិតូបត្ថម្ភ

បើមូលហេតុដែលប្រកាសចាប់ផ្ដើមហិតូបត្ថម្ភបានរលាយ តុលាការត្រូវលុបចោលការប្រកាសចាប់ផ្ដើមហិតូបត្ថម្ភនោះ។

### ៣.១ លក្ខខណ្ឌ

មិនខុសអ្វីពីជននៅក្រោមហិតូបត្ថម្ភឡើយ ក្នុងករណីដែលជននៅក្រោមហិតូបត្ថម្ភមានភាពប្រក្រតីផ្នែកបញ្ញាស្មារតីធម្មតាវិញ ឬពេលដែលកង្វះខ្លាំងនៃសមត្ថភាពខាងឆន្ទៈ មានស្ថានភាពល្អឡើងវិញ លែងចាំបាច់ទុកឱ្យស្ថិតនៅក្រោមរបបហិតូបត្ថម្ភទៀតហើយ និងគ្មានលក្ខខណ្ឌអ្វីមកធ្វើការកម្រិតនូវសមត្ថភាពក្នុងការធ្វើសកម្មភាពរបស់ពួកគេទៀតទេ។

### ៣.២ នីតិវិធីនៃការលុបចោល

#### ៣.២.១ ការដាក់ពាក្យសុំ

តុលាការត្រូវលុបចោលការប្រកាសចាប់ផ្ដើមហិតូបត្ថម្ភតាមពាក្យសុំ របស់សាមីខ្លួន សហព័ទ្ធ ញាតិដែលស្ថិតនៅក្នុង ៤ (បួន) ថ្នាក់ អ្នកអាណាព្យាបាលសម្រាប់អនីតិជន អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ហិតូបត្ថម្ភកៈ អ្នកត្រួតពិនិត្យហិតូបត្ថម្ភកៈ មេឃុំ ឬចៅសង្កាត់នៃលំនៅឋានរបស់ជននោះ ឬតំណាងអយ្យការ។[75]

---

[74] មាត្រា១១០៦ នៃក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៧

[75] មាត្រា ៣១ នៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧

### ៣.២.២ ការវិនិច្ឆ័យ និងការប្រកាសរបស់តុលាការ

មុននឹងប្រកាសរបបហិតូបត្ថម្ភនេះ តុលាការត្រូវស្តាប់មតិយោបល់របស់វេជ្ជបណ្ឌិត និងផ្តល់ឱកាសឱ្យសាមីខ្លួនធ្វើសេចក្តីថ្លែងការណ៍ ដើម្បីពិចារណាថាសាមីខ្លួន ពិតជាមានបញ្ហាផ្នែកស្មារតីពិតប្រាកដមែន ។ ដូច្នេះ ហើយដើម្បីលុបចោលការប្រកាសរបបនេះ តុលាការត្រូវពិចារណាជុំវិញករណីខាងលើដូចគ្នា ថាតើពួកគេមានស្មារតី ឬស្ថានភាពល្អឡើងវិញហើយឬនៅ ហើយតុលាការនឹងចេញដីកាសម្រេចលុបចោលការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅនោះ។

## ផ្នែកទី២៖ សកម្មភាពរបស់ជននៅក្រោមហិតូបត្ថម្ភ

នៅក្នុងរបបហិតូបត្ថម្ភ អ្នកធ្វើសកម្មភាព គឺជននៅក្រោមហិតូបត្ថម្ភផ្ទាល់ខ្លួនឯង ។ ក៏ប៉ុន្តែ នៅពេលដែលសកម្មភាពនោះ គឺជាសកម្មភាពចាត់ចែងទ្រព្យសម្បត្តិដែលសំខាន់ ដើម្បីធ្វើឱ្យសកម្មភាពរបស់ជននៅក្រោមហិតូបត្ថម្ភមានសុពលភាពពេញលេញ ចាំបាច់ត្រូវមានការយល់ព្រមពីហិតូបត្ថម្ភកៈ។ ហិតូបត្ថម្ភកៈ ត្រូវអនុវត្តសិទ្ធិយល់ព្រម ឬសិទ្ធិលុបចោលដោយត្រូវគោរពដល់សិទ្ធិស្វ័យសម្រេចរបស់ជននៅក្រោមហិតូបត្ថម្ភ និងត្រូវគិតគូរពិចារណាដល់រាល់ស្ថានភាពផ្សេងៗរបស់ជននៅក្រោមហិតូបត្ថម្ភ ។

### ១. សកម្មភាពដែលជននៅក្រោមហិតូបត្ថម្ភបានធ្វើហើយមិនអាចលុបចោល

ជននៅក្រោមហិតូបត្ថម្ភ អាចធ្វើសកម្មភាពជាទូទៅបានដោយខ្លួនឯង រួមទាំងសកម្មភាពទាក់ទងនឹងជីវភាពប្រចាំថ្ងៃ លើកលែងតែសកម្មភាពដែលមានបញ្ញត្តិនៅក្នុងមាត្រា ៣០ ចំណុច « ក » ដល់ចំណុច « ញ » ចាំបាច់មានការយល់ព្រមពីហិតូបត្ថម្ភកៈ។

#### ១.១ សកម្មភាពដែលទាក់ទងនឹងជីវភាពប្រចាំថ្ងៃ

យើងបានសិក្សា ២ជំពូកកន្លងមកហើយដែលទាក់ទងទៅនឹងអនីតិជន ជននៅក្រោមអាណាព្យាបាលទូទៅ សកម្មភាពដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ គឺពួកគេអាចធ្វើបាន។ ចំណែកឯសកម្មភាពដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ ធ្វើឡើងដោយជននៅក្រោមហិតូបត្ថម្ភនោះក៏មិនអាចលុបចោលបានដូចគ្នា។ ក៏ប៉ុន្តែ នៅក្នុងករណីដែលសកម្មភាពនៅក្នុងបញ្ញត្តិមាត្រា ៣០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ត្រូវបានធ្វើឡើងទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ ជនដែលស្ថិតនៅក្រោមហិតូបត្ថម្ភ អាចធ្វើសកម្មភាពដោយមិនចាំបាច់មានការយល់ព្រមពីហិតូបត្ថម្ភកៈឡើយ។

ឧទាហរណ៍ : ជននៅក្រោមហិតូបត្ថម្ភអាចដកប្រាក់បន្តិចបន្តួចពីគណនីបញ្ញើ ជាដើម ...។

#### ១.២ សកម្មភាពទាក់ទងនឹងការធ្វើមតកសាសន៍

មិនខុសគ្នាពីជននៅក្រោមអាណាព្យាបាលទូទៅឡើយ ជនដែលស្ថិតនៅក្រោមហិតូបត្ថម្ភកៈក៏អាចធ្វើសន្តតិកម្មបានផងដូចគ្នា។ មូលហេតុដែលមានការទទួលស្គាល់ឱ្យអ្នកដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើ

សកម្មភាព ឱ្យធ្វើមតកសាសន៍នេះ ដោយសារតែមតកសាសន៍នោះនឹងមានអានុភាព ក្រោយពេលដែលជនដែលត្រូវបានកម្រិតនូវសមត្ថភាពនោះបានទទួលមរណៈភាព ដូច្នេះអានុភាពនៃមតកសាសន៍នោះ មិនមានឥទ្ធិពលទៅលើជីវភាពរស់នៅរបស់បុគ្គលនោះទេ ម៉្យាងទៀត មតកសាសន៍ធ្វើឡើងដើម្បីចាត់ចែងទ្រព្យដែលមាន គឺមិនមែនដើម្បីឱ្យខ្ចីទ្រព្យថ្មីទៀតជាអាថ៌ទេ។

**១.៣ សកម្មភាពដែលផ្ទុយនឹងបញ្ញត្តិនៅក្នុងមាត្រា៣០ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧**

គ្រប់សកម្មភាពទាំងអស់ដែលបានធ្វើឡើងដោយជនដែលស្ថិតនៅក្រោមហិតូបត្ថម្ភ មិនផ្ទុយពីមាត្រា៣០ នៃក្រមរដ្ឋប្បវេណី គឺមិនអាចលុបចោលបានឡើយ។ សកម្មភាពដែលបញ្ញត្តិនៅក្នុងមាត្រា៣០ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ នឹងបកស្រាយនៅចំណុចបន្ទាប់គឺ**ជំពូកទី៤ ផ្នែកទី២ ចំណុច ២ សកម្មភាពដែលជននៅក្រោមហិតូបត្ថម្ភបានធ្វើហើយអាចលុបចោលបាន**។

**២. សកម្មភាពដែលជននៅក្រោមហិតូបត្ថម្ភបានធ្វើហើយអាចលុបចោលបាន**

ប្រសិនបើ ជននៅក្រោមហិតូបត្ថម្ភបានធ្វើសកម្មភាពដែលចាំបាច់ត្រូវមានការយល់ព្រមពីហិតូបត្ថម្ភកៈ ហើយសកម្មភាពនោះប្រព្រឹត្ត ឬធ្វើឡើងដោយគ្មានការយល់ព្រមពីហិតូបត្ថម្ភកៈទេ ហិតូបត្ថម្ភកៈ ឬជននៅក្រោមហិតូបត្ថម្ភ អាចធ្វើការលុបចោលសកម្មភាពនោះបាន។ ដោយផ្អែកតាមអង្គច្បាប់ មាត្រា៣០ សិទ្ធិលុបចោលសកម្មភាព នៃក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៧ ចែង លើកលែងចំពោះសកម្មភាពដែលទាក់ទងនឹងជីវភាពប្រចាំថ្ងៃ សកម្មភាពដែលបានធ្វើឡើងដោយ ជននៅក្រោមហិតូបត្ថម្ភ ដោយគ្មានការយល់ព្រមពីហិតូបត្ថម្ភកៈដូចខាងក្រោមនេះ អាចលុបចោលបាន។

**ក. ការទទួល ឬការប្រើប្រាស់ទុន**

ការប្រើប្រាស់ទុន នៅក្នុងន័យនេះចង់សំដៅទៅលើ ការចាត់ចែង ប្រើប្រាស់នូវប្រាក់ សម្រាប់ធ្វើអ្វីមួយ ដូចជា សម្រាប់ប្រើប្រកបកិច្ចការឱ្យចម្រើនផលប្រយោជន៍ឡើងជាដើម។

ការទទួល ឬការប្រើប្រាស់ទុន អាចជាការដកប្រាក់ពីគណនីបញ្ញើ ការទទួលសំណងនៃបំណុល ការឱ្យគេខ្ចីប្រាក់ ការឱ្យគេជួលអចលនវត្ថុដោយកំណត់អំឡុងពេលជួលជាអាទិ៍។

**ខ. ការខ្ចីទ្រព្យ ឬការធានា**

ការខ្ចីទ្រព្យ គឺជាការខ្ចីវត្ថុ ធនធាន ឬទ្រព្យសម្បត្តិជាដើមដែលមានម្ចាស់ ដែលខ្ចីពីគេមកប្រើហើយឱ្យទៅវិញ ចំណែកការធានា គឺជាការទទួលអះអាង ទទួលរ៉ាប់រងលើខ្លួន ដូចជាចាំខ្ញុំធានាជូនអ្នកជាដើម។[76]

ឧទាហរណ៍៖ ខ្ញុំហ៊ានធានាថា A នឹងសងប្រាក់ជូនអ្នកវិញជាដើម។

[76] វចនានុក្រមសម្ដេចសង្ឃ ជួនណាត

### គ. សកម្មភាពដែលមានបំណងទទួលបាន ឬធ្វើឱ្យបាត់បង់សិទ្ធិទាក់ទងនឹងទ្រព្យសម្បត្តិ

សកម្មភាពដែលមានគោលបំណងទទួល ឬធ្វើឱ្យបាត់បង់សិទ្ធិដែលទាក់ទងនឹងអចលនវត្ថុ ទ្រព្យសម្បត្តិដែលមានសារៈសំខាន់ផ្សេងទៀត ក្រៅពីកិច្ចសន្យាការងារ កិច្ចសន្យាគាំពារមនុស្សចាស់ជរា កិច្ចសន្យាធានារ៉ាប់រងជាដើម សកម្មភាពដែលមានគោលបំណងទទួល ឬធ្វើឱ្យបាត់បង់សិទ្ធិដែលទាក់ទងនឹងទ្រព្យសំខាន់សម្បត្តិដែលមានសារៈសំខាន់ផ្សេងទៀត ឱ្យតែជាកិច្ចសន្យាដែលមានតម្លៃថ្នូរសមស្រប។

### ឃ. ការធ្វើសកម្មភាពបណ្តឹង

ជាគោលការណ៍ ជននៅក្រោមហិតូបត្ថម្ភ អាចធ្វើសកម្មភាពបណ្តឹងបាន លុះត្រាតែមានការយល់ព្រមពីហិតូបត្ថម្ភកៈ (មាត្រា ៣០ ចំណុច «ឃ» នៃក្រមរដ្ឋប្បវេណី) ប៉ុន្តែប្រសិនបើកំណត់បែបនេះ ភាគីម្ខាងទៀត ដែលមានបំណងធ្វើបណ្តឹងចំពោះជននៅក្រោមហិតូបត្ថម្ភនឹងបាត់បង់ផ្លូវដើម្បីដោះស្រាយវិវាទក្នុងករណីហិតូបត្ថម្ភកៈមិនយល់ព្រម។ ម្យ៉ាងវិញទៀត ហិតូបត្ថម្ភកៈ មិនមែនជាអ្នកតំណាងដែលច្បាប់បានកំណត់របស់ជននៅក្រោមហិតូបត្ថម្ភទេ នាំឱ្យភាគីម្ខាងទៀតមិនអាចធ្វើបណ្តឹងដោយយកហិតូបត្ថម្ភកៈ ជាអ្នកតំណាងបាន។ ហេតុនេះ មាត្រា ៣៣ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី បញ្ញត្តិពិសេសឱ្យភាគីម្ខាងទៀត អាចធ្វើបណ្តឹង ចំពោះជននៅក្រោមហិតូបត្ថម្ភបាន ដោយមិនចាំបាច់ទទួលការយល់ព្រមពីហិតូបត្ថម្ភកៈ ដើម្បីសង្គ្រោះអលទ្ធភាពបុគ្គលដែលមានបំណងធ្វើបណ្តឹងប្រឆាំងនឹងជននៅក្រោមហិតូបត្ថម្ភ។

ផ្អែកតាមមាត្រា ៣៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ទោះបីជាជននៅក្រោមហិតូបត្ថម្ភ ជាអ្នកធ្វើបណ្តឹង ឬទទួលបណ្តឹងរបស់ភាគីម្ខាងទៀតក៏ដោយ ចំពោះសកម្មភាពបណ្តឹងដែលទាក់ទងនឹងការដកពាក្យបណ្តឹង ការផ្សះផ្សា ការលះបង់ការទាមទារ ឬការទទួលស្គាល់នូវការទាមទារ ការដកពាក្យបណ្តឹងឧទ្ធរណ៍ ឬបណ្តឹងសាទុក្ខចាំបាច់ត្រូវទទួលការប្រគល់សិទ្ធិពិសេសពីហិតូបត្ថម្ភកៈ ឬអ្នកត្រួតពិនិត្យហិតូបត្ថម្ភកៈ។

### ង. ការធ្វើប្រទានកម្ម ឬធ្វើកិច្ចសន្យាស្រុះស្រួល ឬកិច្ចសន្យាមជ្ឈត្តកម្ម

ប្រទានកម្ម សំដៅដល់កិច្ចសន្យាមួយ ដែលត្រូវមានអានុភាព ដោយភាគីម្ខាងបង្ហាញឆន្ទៈផ្តល់ទៅឱ្យភាគីម្ខាងទៀតនូវទ្រព្យសម្បត្តិ ដោយមិនយកថ្លៃ ហើយភាគីម្ខាងទៀតយល់ព្រមទទួល។ ប្រទានកម្ម អាចត្រូវបានធ្វើឡើងដោយផ្ទាល់មាត់ ឬជាលាយល័ក្ខណ៍អក្សរ ហើយកម្មវត្ថុនៃកិច្ចសន្យាប្រទានកម្ម អាចជាវត្ថុ ប្រាក់ ប៉ុន្តែចំពោះអចលនវត្ថុវិញ ប្រទានកម្មនឹងមានអានុភាពតាមផ្លូវច្បាប់ លុះត្រាតែបានធ្វើលិខិតយថាភូត។ ដូចនេះ យើងអាចធ្វើការសន្និដ្ឋានបានថា កិច្ចសន្យាប្រទានកម្ម គឺជាការស្ម័គ្រចិត្ត ក្នុងការប្រគល់នូវ វត្ថុ ឬទ្រព្យសម្បត្តិរបស់ខ្លួន ឱ្យទៅភាគីម្ខាងទៀត ដោយមានភ្ជាប់បន្ទុក ឬករណីមរណភាពរបស់ភាគីជាដើម។[77] ចំណែកកិច្ចសន្យា

[77] មាត្រា ៥៦៨ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា

មជ្ឈត្តកម្ម គឺជាកិច្ចសន្យាដែលធ្វើឡើងដោយភាគីនៃវិវាទ ដើម្បីជ្រើសរើសតតិយជនណាម្នាក់ឱ្យធ្វើជាមជ្ឈត្តករ ដើម្បីដោះស្រាយវិវាទ។[78]

ដូចនេះជននៅក្រោមហិតូបត្ថម្ភ មិនអាចធ្វើកិច្ចសន្យាប្រទានកម្ម កិច្ចសន្យាស្រុះស្រួល កិច្ចសន្យាមជ្ឈត្តកម្មបាននោះទេ គឺដើម្បីការពារផលប្រយោជន៍របស់ជននៅក្រោមហិតូបត្ថម្ភ។

**ច. ការទទួលស្គាល់នូវសន្តតិកម្ម ឬការបោះបង់ចោលនូវសិទ្ធិសន្តតិកម្ម ឬការបែងចែកនូវមត៌ក**

សន្តតិកម្ម គឺជាការផ្ទេរនូវសិទ្ធិ និងករណីយកិច្ចរបស់មតកជនម្នាក់ ឬច្រើននាក់តាមឆន្ទៈ ឬតាមច្បាប់។[79] ចំណែកការបោះបង់ចោលនូវសន្តតិកម្ម សំដៅទៅដល់ការបោះបង់ទ្រព្យសម្បត្តិ និងបំណុលសន្តតិកម្ម រីឯការបែងចែកមត៌ក គឺជាការចាត់ចែងទ្រព្យសម្បត្តិជាអាចិ៍។[80] ដោយសារតែសកម្មភាពប្រភេទនេះ ធ្វើឱ្យជននៅក្រោមហិតូបត្ថម្ភខាតប្រយោជន៍ ដូចនេះហើយច្បាប់បានចែងការពារជននៅក្រោមហិតូបត្ថម្ភ បើសកម្មភាពទាំងនេះបានធ្វើឡើងដោយមិនមានការអនុញ្ញាតពីហិតូបត្ថម្ភកៈ ឬអ្នកដែលច្បាប់បានកំណត់ទេ នោះសកម្មភាពទាំងនេអាចលុបចោលបាន។

**ឆ. ការប្រកែកមិនទទួល ឬការយល់ព្រមទទួលនូវប្រទានកម្ម ឬអច្ច័យទាន**

អច្ច័យទាន គឺជាប្រទានកម្ម ដែលម្ចាស់បណ្តាំធ្វើទៅឱ្យមនុស្សម្នាក់ ឬច្រើននាក់នូវទ្រព្យសម្បត្តិរបស់ខ្លួនតាមរយៈមតកសាសន៍។ [81] អច្ច័យទានដែលភ្ជាប់បន្ទុក មានន័យថាជាអច្ច័យទានដែលភ្ជាប់ទៅនឹងលក្ខខណ្ឌអ្វីមួយ។ ដូចនេះ សកម្មភាពដែលប្រកែកមិនទទួលអច្ច័យទាន ឬយល់ព្រមទទួលនូវប្រទានកម្ម មានមូលហេតុនៃការលុបចោល កាលណាសកម្មភាពដែលជននៅក្រោមហិតូបត្ថម្ភធ្វើមិនមានការយល់ព្រមពីហិតូបត្ថម្ភកៈទេ។ ម៉្យាងវិញទៀតចំពោះការយល់ព្រមទទួលនូវប្រទានកម្ម ឬអច្ច័យទានដែលភ្ជាប់នឹងបន្ទុក ក៏មានមូលហេតុនៃការលុបចោលផងដែរ ព្រោះសកម្មភាពទទួលប្រទានកម្ម ឬអច្ច័យទាននេះ ពេលខ្លះបានផលប្រយោជន៍ដល់ជននៅក្រោមហិតូបត្ថម្ភ ដើម្បីទទួលបានទ្រព្យសម្បត្តិអ្វីមួយនោះ ប៉ុន្តែពេលខ្លះទៀតសកម្មភាពទាំងនេះធ្វើឱ្យខូចខាតផលប្រយោជន៍ដល់ជននៅក្រោមហិតូបត្ថម្ភ ដូច្នេះ ជននៅក្រោមហិតូបត្ថម្ភមិនគួរធ្វើការសម្រេចចិត្តដោយខ្លួនឯងនោះទេ។

---

[78] សទ្ទានុក្រមពាក្យច្បាប់ ខ្មែរ-អង់គ្លេស-បារាំង ផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី រៀបចំដោយគណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ ឆ្នាំ២០០៧

[79] សទ្ទានុក្រមលេខ១៤៤ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[80] មេរៀន ការយល់ព្រម និងការបោះបង់សន្តតិកម្ម ឧទ្ទេសនាមដោយ លោក ង៉ី ភីរក្ស

[81] សទ្ទានុក្រមលេខ១៧៧ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

**ជ. ការសាងសង់សំណង់ថ្មី ការសង់ឡើងវិញ ការសង់បន្ថែម ឬការជួសជុលធំ**

ការសាងសង់សំណង់ថ្មី គឺជាការសង់អ្វីមួយដែលថ្មី ដែលមិនធ្លាប់មានពីមុនមក។ ការសាងសង់សំណង់ថ្មី ការសង់ឡើងវិញ ការសង់បន្ថែម ឬការជួសជុលធំនេះរួមបញ្ចូលនឹងការបញ្ជាឱ្យធ្វើ ឬអនុម័តឱ្យធ្វើផងដែរ។ ដោយសារតែការសាងសង់នេះ ត្រូវធ្វើការចំណាយច្រើនហួសប្រមាណ ច្បាប់បានការពារ និងលុះត្រាតែមានការអនុញ្ញាតពីហិតូបត្ថម្ភកៈ ទើបជននៅក្រោមហិតូបត្ថម្ភអាចធ្វើបាន។

**ឈ. ការធ្វើភតិសន្យា ដែលមានអំឡុងពេលលើសពី ៣ ឆ្នាំ ចំពោះដីធ្លី លើសពី ២ ឆ្នាំ ចំពោះអាគារ លើសពី ៦ ខែ ចំពោះចលនវត្ថុ**

ភតិសន្យាសំដៅទៅលើកិច្ចសន្យាមួយដែលភាគីម្ខាង ឱ្យភាគីម្ខាងទៀតប្រើប្រាស់ និងអាស្រ័យផល ពីវត្ថុណាមួយដោយយកថ្លៃ។ វត្ថុដែលជាកម្មវត្ថុនៃភតិសន្យា មានចលនវត្ថុ និងអចលនវត្ថុ។[82]

កាលណាដែលជននៅក្រោមហិតូត្ថម្ភធ្វើកិច្ចសន្យាជួលលើសពី៣ (បី) ឆ្នាំ ចំពោះដីធ្លី លើសពី ២ (ពីរ) ឆ្នាំ ចំពោះអាគារ លើសពី ៦ (ប្រាំមួយ) ខែ ចំពោះចលនវត្ថុនោះមានមូលហេតុនៃការលុបចោល តែប្រសិនបើជននៅក្រោមហិតូត្ថម្ភនោះធ្វើកិច្ចសន្យាជួលដោយគ្មានការអនុញ្ញាតពីហិតូបត្ថម្ភកៈដែលមានរយៈពេលតិចជាង (បី) ឆ្នាំ ចំពោះដីធ្លី តិចជាង ២ (ពីរ) ឆ្នាំ ចំពោះអាគារ តិចជាង ៦ (ប្រាំមួយ) ខែ ចំពោះចលនវត្ថុនោះគ្មានមូលហេតុនៃការលុបចោលឡើយ។

**ឧទាហរណ៍៖** A ជាជននៅក្រោមហិតូបត្ថម្ភបានធ្វើកិច្ចសន្យាជួលរយៈពេល ២ ឆ្នាំ លើដីមួយកន្លែង ឱ្យ B ជានីតិជន។ ដូចនេះគ្មានមូលហេតុនៃការលុបចោលឡើយ។

***ញ. សកម្មភាពដែលតុលាការបានប្រកាសថាចាំបាច់ត្រូវមានការយល់ព្រមពីហិតូបត្ថម្ភកៈ***

ក្រៅពីសកម្មភាពពីចំណុច ក ដល់ ឈ ប្រសិនបើមានកិច្ចសន្យាផ្សេងទៀត ដែលប្រសិនជាប្រគល់ឱ្យសាមីខ្លួនធ្វើទៅ មានការព្រួយបារម្ភ គឺអាចពង្រីកវិសាលភាពនៃសិទ្ធិយល់ព្រមរបស់ហិតូបត្ថម្ភកៈបាន។ ដើម្បីពង្រីកវិសាលភាពនៃសិទ្ធិនេះ ចាំបាច់ត្រូវដាក់ពាក្យសុំទៅសាលាដំបូងឱ្យគេវិនិច្ឆ័យទៅតាមករណីនីមួយៗ។ ក្នុងករណីដែលជននៅក្រោមហិតូបត្ថម្ភបានធ្វើសកម្មភាពទាំងនោះដោយគ្មានការយល់ព្រមពីហិតូបត្ថម្ភកៈ ឬសាមីខ្លួន ឬហិតូបត្ថម្ភកៈ អាចលុបចោលសកម្មភាពនោះបាន[83]។

គួរបញ្ជាក់ថា សិទ្ធិអំណាចរបស់ហិតូបត្ថម្ភកៈ គឺជាការផ្តល់នូវការយល់ព្រមចំពោះសកម្មភាពដែលជននៅក្រោមហិតូបត្ថម្ភមិនអាចធ្វើដោយឯករាជ្យបាន។ នេះមិនមែនជាការផ្តល់សិទ្ធិអំណាចឱ្យធ្វើជាអ្នកតំណាងសាមី

[82] មាត្រា ៥៩៦ នៃក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៧

[83] វាក្យខណ្ឌទី ១ នៃមាត្រា៣០ ក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៧

ខ្លួន ដូចអ្នកមានសិទ្ធិអំណាចមេបា ឬអ្នកអាណាព្យាបាលទេ។ ដូច្នេះ ហិតូបត្ថម្ភកៈ មិនមែនជាអ្នកតំណាងដែលច្បាប់បានកំណត់ឡើយ។

ក្នុងចំណោមសកម្មភាពដែលមានរៀបរាប់ខាងលើនេះ បើពិនិត្យមើលតាមខ្លឹមសារទៅ មានសកម្មភាពជាច្រើនដែលមិនមែនជាសកម្មភាពទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃទេ ក៏ប៉ុន្តែ មានសកម្មភាពខ្លះៗ ដូចជា ការដកប្រាក់បន្តិចបន្តួចពីគណនីបញ្ញើ គឺអាចគិតថាជាសកម្មភាពទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ ដែលមានចែងក្នុងមាត្រា ៣០ នៃក្រមរដ្ឋប្បវេណីថ្មី ហេតុនេះហើយ ដើម្បីកុំឱ្យមានចម្ងល់ បានជាចែងថែមទៀតនៅក្នុងអញ្ញត្តិកម្ម ។ម្យ៉ាងទៀត សិទ្ធិអំណាចរបស់ហិតូបត្ថម្ភកៈ គឺជាការផ្តល់នូវការយល់ព្រមចំពោះសកម្មភាពដែលជននៅក្រោមហិតូបត្ថម្ភមិនអាចធ្វើដោយឯករាជ្យបាន នេះមិនមែនជាការផ្តល់សិទ្ធិអំណាចឱ្យធ្វើជាអ្នកតំណាងសាមីខ្លួន ដូចអ្នកមានសិទ្ធិអំណាចមេបា ឬអ្នកអាណាព្យាបាលទេ។

គួរបញ្ជាក់ថា ហិតូបត្ថម្ភកៈ មិនមែនជាអ្នកតំណាងដែលច្បាប់បានកំណត់ឡើយ។

## ផ្នែកទី៣៖ នីតិវិធីនៃការលុបចោលសកម្មភាពរបស់ជននៅក្រោមហិតូបត្ថម្ភ

ដើម្បីធ្វើការលុបចោលសកម្មភាពរបស់ជននៅក្រោមហិតូបត្ថម្ភបាន យើងគប្បីយល់អំពីលក្ខខណ្ឌ និងនីតិវិធីនៃការបង្ហាញឆន្ទៈលុបចោល ជាមុនសិន។

### ១. លក្ខខណ្ឌ

ចំពោះការលុបចោល ដោយមូលហេតុជាជននៅក្រោមហិតូបត្ថម្ភ ដែលត្រូវបានកម្រិតសមត្ថភាពនៅក្នុងការធ្វើសកម្មភាព ច្បាប់បានបញ្ញត្តិថាអាចលុបចោលសកម្មភាពនោះបាន។

#### ១.១ សកម្មភាពដែលអាចលុបចោលបាន

ចំពោះគ្រប់សកម្មភាពទាំងអស់ដែលជននៅក្រោមអាណាព្យាបាលទូទៅបានធ្វើ ដោយមិនទទួលបានការអនុញ្ញាត ឬយល់ព្រមពីហិតូបត្ថម្ភកៈ អាចលុបចោលសកម្មភាពនោះបាន លើកលែងតែសកម្មភាពទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ និងសកម្មភាពដែលផ្ទុយនឹងបញ្ញត្តិមាត្រា ៣០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

#### ១.២ បុគ្គលដែលមានសិទ្ធិលុបចោល

សកម្មភាពដែលអាចលុបចោលបាន មានតែអ្នកមានសិទ្ធិលុបចោលប៉ុណ្ណោះទើបអាចលុបចោលទៅលើសកម្មភាពនោះ។ អ្នកដែលមានសិទ្ធិលុបចោលសកម្មភាពមានសាមីខ្លួន និងហិតូបត្ថម្ភកៈ។ ក្នុងករណីខ្លះចំពោះហិតូបត្ថម្ភកៈគឺ មិនគួរធ្វើការអនុវត្តសិទ្ធិលុបចោលសកម្មភាពដោយគ្រាន់តែគ្មានការយល់ព្រមពីខ្លួនប៉ុណ្ណោះទេ ព្រោះក្នុងករណីដែលជននៅក្រោមហិតូបត្ថម្ភចង់ធ្វើសកម្មភាពនោះ ហើយសកម្មភាពនោះមិនប៉ះពាល់ទៅដល់ផលប្រយោជន៍របស់ជននៅក្រោមហិតូបត្ថម្ភទេ វាធ្វើឱ្យជននៅក្រោមហិតូបត្ថម្ភ គ្មានសិទ្ធិនៅក្នុងការធ្វើអ្វីមួយតាមអ្វីដែលខ្លួនចង់បានឡើយ។ ទន្ទឹមនឹងនេះ ការលុបចោលក៏អាចធ្វើបានដោយមូលហេតុនៃការ

កម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព ជាជននៅក្រោមហិតូបត្ថម្ភ ជននោះអាចលុបចោលសកម្មភាពបាន មុនពេលជននោះមានសមត្ថភាពក្នុងការធ្វើសកម្មភាពឡើងវិញផងដែរ ។

**១.៣ រយៈពេលដែលអាចលុបចោល**

ចំពោះរយៈពេលដែលអាចលុបចោលវិញ គឺមិនខុសអ្វីពីអនីតិជន និងជននៅក្រោមអាណាព្យាបាលទូទៅដែរ ច្បាប់បានកំណត់រយៈពេល ៣ឆ្នាំ ចាប់តាំងពីពេលដែលខ្លួនក្លាយទៅជាអ្នកដែលអាចផ្តល់សច្ចានុមតិ ឬអ្នកដែលមានសិទ្ធិលុបចោលនោះ និងប្រសិនបើហួសអំឡុងពេល ១០ឆ្នាំ ចាប់តាំងពីកាលបរិច្ឆេទនៃសកម្មភាពបានប្រព្រឹត្ត ដើម្បីធ្វើការលុបចោលសកម្មភាពនោះ សិទ្ធិលុបចោលនឹងត្រូវរលត់ដូចគ្នា។

ដើម្បីយល់កាន់តែច្បាស់សូមមើលនៅ **ជំពូកទី២ អនីតិជន ផ្នែកទី២ ចំណុច ១.៣ រយៈពេលដែលអាចលុបចោល**។

**២. នីតិវិធីនៃការបង្ហាញឆន្ទៈលុបចោល**

ចំពោះការលុបចោលនេះវិញ ភាគីគ្រាន់តែបង្ហាញឆន្ទៈថាលុបចោលសកម្មភាពនោះគឺគ្រប់គ្រាន់ហើយ មិនចាំបាច់ឆ្លងកាត់តាមនីតិវិធីតុលាការទេ។ ដើម្បីយល់កាន់តែច្បាស់សូមមើលនៅ **ជំពូកទី២ អនីតិជន ផ្នែកទី២ ចំណុច ២ នីតិវិធីនៃការបង្ហាញឆន្ទៈ**។

**៣. អានុភាព**

អានុភាពនៃការលុបចោលកើតមានឡើងនៅពេលដែលការជូនដំណឹងនោះបានទៅដល់ភាគីម្ខាងទៀត។ នៅពេលដែលសកម្មភាពមួយត្រូវបានគេលុបចោល សកម្មភាពនោះ ត្រូវបានគេចាត់ទុកជាមោឃៈតាំងពីដំបូង ដូចមានបង្ហាញនៅ**ជំពូកទី២ អនីតិជន ផ្នែកទី២ ចំណុច ៣ អានុភាព**ដែរ។

## ផ្នែកទី៤៖ យន្តការ និងការការពារភាគីម្ខាងទៀត

**១. ការដាស់តឿន**

មិនខុសពីអនីតិជន និងជននៅក្រោមអាណាព្យាបាលទូទៅឡើយ ច្បាប់បានបញ្ញត្តិទុករយៈពេលយ៉ាងតិច ១ខែ ម្យ៉ាងទៀត ក្នុងករណីដែលស្ថានភាពនៃសមត្ថភាពរបស់ជនដែលត្រូវបានកម្រិតនូវសមត្ថភាព មិនទាន់ល្អឡើងវិញ នាពេលទទួលការដាស់តឿននោះ ក៏មានការទទួលស្គាល់នូវវិធីដាស់តឿន ចំពោះជននៅក្រោមហិតូបត្ថម្ភ ដើម្បីទទួលនូវសច្ចានុមតិពីហិតូបត្ថម្ភកៈផងដែរ។ ក្នុងករណីជននៅក្រោមហិតូបត្ថម្ភ នៅតែជាជនដែលត្រូវកម្រិតសមត្ថភាពដដែល ភាគីម្ខាងទៀតក៏អាចដាស់តឿនឱ្យឆ្លើយតបដូចគ្នាចំពោះសកម្មភាពដែលស្ថិតក្នុងទំហំនៃសិទ្ធិនោះ ទៅកាន់អ្នកតំណាងដែលច្បាប់បានកំណត់ ហិតូបត្ថម្ភកៈ ឬអ្នកជួយទំនុកបម្រុងបាន ហើយបើគ្មានការឆ្លើយតបក្នុងអំឡុងពេលដូចគ្នានេះទេ ត្រូវចាត់ទុកថា បានផ្តល់សច្ចានុម័ត។ លើសពីនេះ ភាគីម្ខាងទៀតក៏អាចដាស់តឿនទៅកាន់ជននៅក្រោមហិតូបត្ថម្ភ ឱ្យទៅទទួលសច្ចានុម័តពីហិតូបត្ថម្ភកៈ ឬអ្នកជួយទំនុកបម្រុង

ក្នុងអំឡុងពេលលើសពី ១ខែបានដូចគ្នា ហើយបើសិនជាជននៅក្រោមហិតូបត្ថម្ភ មិនបានផ្តល់ដំណឹងអំពីការទទួលបានសច្ចានុម័តក្នុងអំឡុងពេលនោះទេ ត្រូវចាត់ទុកថា បានលុបចោលសកម្មភាព។ ដើម្បីយល់កាន់តែច្បាស់បន្ថែមសូមមើលនៅក្នុង **ជំពូកទី២ ផ្នែកទី៣ ចំណុច ១ ការដាស់តឿន**។

## ២. ការឆបោក

ក្នុងករណីដែលភាគីម្ខាងទៀតគិតស្មានថា ខ្លួនជាសមត្ថជន ហើយជននោះលាក់ការណ៍ ដោយមិនប្រាប់ថាខ្លួនជាជននៅក្រោមហិតូបត្ថម្ភ ការណ៍នេះគ្រាន់តែជាការរក្សាការស្ងៀមស្ងាត់ប៉ុណ្ណោះមិនអាចថាជាការឆបោកទេ ប៉ុន្តែប្រសិនបើបានប្រើពាក្យសំដីផ្សេងៗ ដែលធ្វើឱ្យភាគីម្ខាងទៀតយល់ច្រឡំ នេះអាចក្លាយទៅជាការឆបោកបាន។ យោងតាមពាក្យពេចន៍ដែលបានប្រើក្នុងបញ្ញត្តិនេះ គឺមិនជាច្បាស់លាស់ទេ ប៉ុន្តែចំពោះករណីដែលជនដែលត្រូវបានកម្រិតនូវសមត្ថភាព បានភូតកុហកថា ខ្លួនបានទទួលការយល់ព្រមពីជនដែលមានសិទ្ធិផ្តល់ការយល់ព្រម ហើយបានបង្ហាញលិខិតយល់ព្រមក្លែងក្លាយដល់ភាគីម្ខាងទៀត សកម្មភាពនោះចាត់ទុកជាការឆបោកផងដែរដូចបានបង្ហាញនៅ**ជំពូកទី២ ផ្នែកទី៣ ចំណុច២ ការឆបោក**។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ឆ្លងតាមការសិក្សាស្រាវជ្រាវ និងបកស្រាយលើប្រធានបទស្តីពី « **ជនដែលត្រូវបានកម្រិតសមត្ថភាពនៅក្នុងការធ្វើសកម្មភាព** » យ៉ាងលម្អិតមក យើងសង្កេតឃើញថា វាមានភាពចាំបាច់ណាស់នៅក្នុងការកម្រិតសមត្ថភាពនៅក្នុងការធ្វើសកម្មភាពចំពោះជនដែលគាត់មិនមានសមត្ថភាពគ្រប់គ្រាន់ក្នុងការយល់ដឹង និងធ្វើការវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់ នៃសកម្មភាពរបស់ខ្លួនបាន។ ការធ្វើសកម្មភាពរបស់ជនដែលត្រូវបានកម្រិតសមត្ថភាព គឺច្បាប់មានគោលបំណងការពារកុំឱ្យពួកគេមានការខូចខាតដោយកត្តាណាមួយដែលកើតឡើង ដោយកិច្ចការដែលអ្នកពុំមានសមត្ថភាពគ្រប់គ្រាន់ក្នុងការធ្វើសកម្មភាពធ្វើ។

ជាការពិតណាស់ មិនថានៅក្នុងសង្គមណាទេ សុទ្ធសឹងតែមានប្រភេទ នៃជនដែលត្រូវបានកម្រិតសមត្ថភាពនៅក្នុងការធ្វើសកម្មភាពនេះ មិនថាពួកគេជាជាតិសាសន៍ណាក៏ដោយ ប៉ុន្តែជនប្រភេទនេះ មានអ្នកខ្លះត្រូវបានប្រកាសដោយតុលាការ ឯអ្នកខ្លះទៀតមិនត្រូវបានធ្វើការប្រកាសឡើយ។ មូលហេតុដែលគេប្រកាសរបបនេះ ព្រោះដើម្បីរក្សាការពារ និងជួយចាត់ចែងទ្រព្យសម្បត្តិរបស់អ្នកដែលមិនអាចចាត់ចែងទ្រព្យសម្បត្តិរបស់ខ្លួនបាន។

ផ្អែកតាមទិដ្ឋភាពសង្គមជាក់ស្តែង កាលណាបុគ្គលគ្រប់រូបអាចធ្វើសកម្មភាពដោយសេរី និងឯករាជ្យបានដោយមិនកម្រិតសមត្ថភាពនៃការយល់ដឹង អំពីស្មារតីដឹងខុសដឹងត្រូវផ្អែកច្បាប់របស់ពួកគេទេ អាចបណ្តាលឱ្យសង្គមមានភាពចលាចល ភាពមិនប្រាកដប្រជា ច្បាស់លាស់ ដែលបណ្តាលឱ្យគ្មានអ្នកទទួលខុសត្រូវចំពោះសកម្មភាពដែលធ្វើឡើងដោយជនទាំង ៣ប្រភេទនោះ និងមិនអាចកំណត់អំពីអត្តសញ្ញាណច្បាស់លាស់ឡើយអំពីភាពមានវិការៈនៃការធ្វើសកម្មភាពរបស់ពួកគេ។

ដូច្នេះហើយទើបច្បាប់ បានធ្វើការកំណត់យ៉ាងច្បាស់លាស់អំពី ប្រភេទ នៃជនដែលត្រូវបានកម្រិតសកម្មភាព ដែលរួមមាន អនីតិជន ជននៅក្រោមអាណាព្យាបាលទូទៅ និងជននៅក្រោមហិតូបត្ថម្ភ។ ជនទាំងបីគឺជាជនដែលមិនមានសមត្ថភាពគ្រប់គ្រាន់តាមផ្លូវច្បាប់ ហើយដើម្បីធ្វើកិច្ចសន្យាណាមួយដោយខ្លួនឯងនោះលុះត្រាតែទទួលបានការអនុញ្ញាតពីអ្នកដែលមានសិទ្ធិស្របច្បាប់ក្នុងការគ្រប់គ្រង និងថែរក្សាជនទាំងនោះជាមុនសិនប៉ុណ្ណោះ។ ក្នុងចំណោមប្រភេទជនទាំងនេះ បើទោះបីជាជននោះជា ជនដែលគ្មានសមត្ថភាពយល់ដឹងនិងវិនិច្ឆ័យឱ្យបានត្រឹមត្រូវ ដោយសារស្ថិតក្នុងស្ថានភាពជានិរន្តរ៍វិបត្តិផ្នែកបញ្ញាស្មារតី ដែលជាប្រភេទមួយដែលសមត្ថភាពខាងស្មារតីអន់ខ្សោយបំផុតក៏ដោយ ក៏មានការទទួលស្គាល់នូវការធ្វើសកម្មភាពដោយឯករាជ្យផងដែរ ចំពោះករណីលើកលែង ដែលទាក់ទងទៅនឹងសកម្មភាពរស់នៅប្រចាំថ្ងៃ ពោលគឺមិនមែនដូចជនដែលត្រូវបានកម្រិតសមត្ថភាព ដែលជាជនមិនមានសមត្ថភាពទាំងស្រុងនោះទេ។

ចំពោះជនដែលមានការពិបាកក្នុងការសម្រេចសេចក្ដីពេលធ្វើកិច្ចសន្យា ដោយសារខ្វះសមត្ថភាពវិនិច្ឆ័យគ្រប់គ្រាន់បានដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី ដែលកំណត់នៅក្នុងក្រមរដ្ឋប្បវេណី មានពីរប្រភេទ គឺជនដែលនៅក្រោមអាណាព្យាបាលទូទៅ និង ជនដែលនៅក្រោមហិតូបត្ថម្ភ ។ ប៉ុន្តែ មិនបង្កើតប្រភេទផ្សេងទៀត និងមិនរៀបចំរបបដែលមានលក្ខណៈធូរជាងនេះឡើយគឺដោយសារតែកម្ពុជាមិនមែនជាសង្គមមួយ ដែលមានមនុស្សចាស់ច្រើនទេ ដូច្នេះហើយយើងអាចសន្និដ្ឋានបានថា របបបែបនេះមិនមានភាពចាំបាច់ខ្លាំងក្លានោះទេ សម្រាប់សង្គម និងសម្រាប់សេដ្ឋកិច្ច ហើយទន្ទឹមនឹងនេះ ដើម្បីទ្រទ្រង់របបអាណាព្យាបាលទូទៅដែលមានភាពធូរបែបនេះ ចាំបាច់ត្រូវមានរបប និងធនធានមនុស្សគ្រប់គ្រាន់ និងសមស្របមួយដែរ។

សរុបជារួមមក សកម្មភាពរបស់បុគ្គលទាំងនេះបានធ្វើមួយចំនួនត្រូវបានច្បាប់ហាមឃាត់ និងត្រូវបានលុបចោលដោយអ្នកមានសិទ្ធិលុបចោល ឬអ្នកតំណាង ប៉ុន្តែក៏មានសកម្មភាពមួយចំនួន ដែលច្បាប់អនុញ្ញាតផងដែរ ដូចជាសកម្មភាពដែលទាក់ទងនឹងការរស់នៅប្រចាំថ្ងៃ និងសកម្មភាពមួយចំនួនទៀត ដែលច្បាប់កំណត់ថាត្រូវមានការអនុញ្ញាតពីបុគ្គលដែលគ្រប់គ្រងរបបនោះ។

# អនុសាសន៍

# អនុសាសន៍

ផ្អែកតាមរយៈការសិក្សាស្រាវជ្រាវទៅលើប្រធានបទ « ជនដែលត្រូវបានកម្រិតសមត្ថភាពនៅក្នុងការធ្វើសកម្មភាព » រួចមក យើងមើលឃើញថាផ្នែកនេះមានសារៈសំខាន់ជាងគេនៅក្នុងសៀវភៅស្តីអំពីបទបញ្ញត្តិទូទៅនៃច្បាប់រដ្ឋប្បវេណី ពីព្រោះក្នុងផ្នែកនេះមានបញ្ញត្តិចែងអំពីវិធីដោះស្រាយចំពោះរាល់បញ្ហាដែលអាចកើតមានឡើងក្នុងករណីផ្សេងៗជាច្រើន គឺមានតាំងពីបញ្ញត្តិចែងអំពីសកម្មភាពគតិយុត្តដែលអាច នាំឱ្យកើតមានឡើងនូវលទ្ធផលតាមផ្លូវច្បាប់ ឬបង្ហាញនូវឆន្ទៈដែលខុសពីចិត្តគំនិតដើមរបស់ខ្លួន។ ម៉្យាងវិញទៀតយើងមើលឃើញថាជនដែលមិនមានសមត្ថភាពគ្រប់គ្រាន់នៅក្នុងការធ្វើសកម្មភាពនៅកម្ពុជាបច្ចុប្បន្ន មិនសូវមានការប្រកាសរបបប្រភេទ នៃជនដែលត្រូវបានកម្រិតសមត្ថភាពឱ្យពួកគេឡើយ។ មូលហេតុធំចម្បងដែលច្បាប់មិនធ្វើការប្រកាសជនទាំងនោះ ព្រោះពួកគេមិនមានទ្រព្យសម្បត្តិសម្រាប់ថែរក្សា ឬការពារឱ្យពួកគេ។ នេះជាមូលហេតុមួយដែលធ្វើឱ្យកម្ពុជា មានប្រភេទនៃជនដែលត្រូវបានកម្រិតសមត្ថភាពនេះមិនមានអ្នកមើលថៃ និងត្រូវបានគេធ្វើបាបគ្មានកន្លែងស្នាក់គ្រប់គ្រាន់សម្រាប់ពួកគេ ម៉្យាងវិញទៀតសកម្មភាពដែលពួកគេធ្វើឡើង គឺពិបាកក្នុងការពិចារណាណាស់ថា តើសកម្មភាពនោះចេញពីឆន្ទៈពិតប្រាកដរបស់ពួកគេដែរឬទេ?

ដោយផ្អែកតាមអង្គច្បាប់ សកម្មភាពរបស់ជនដែលត្រូវបានកម្រិតសមត្ថភាពធ្វើទាក់ទងនឹងសកម្មភាពរស់នៅប្រចាំថ្ងៃ មិនអាចលុបចោលបានឡើយ។ មកដល់ចំណុចនេះ មានសំនួរជាច្រើនដែលបានលេចឡើងដែលយើងមិនអាចធ្វើការបកស្រាយជាក់ច្បាស់បានទាក់ទងនឹងសកម្មភាពរស់នៅប្រចាំថ្ងៃ។ យើងមិនអាចដឹងទេថា តើសកម្មភាពបែបណាខ្លះដែលច្បាប់ចាត់ទុកថាជាសកម្មភាពដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ ម៉្យាងវិញទៀតយើងមិនដឹងឡើយថាទំហំប្រាក់ដែលត្រូវចំណាយប៉ុណ្ណា ទើបអាចចាត់ទុកជាសកម្មភាពប្រចាំថ្ងៃ។ នេះគឺជាអញ្ញត្តិកម្មមួយ ដែលមានការពិបាកបកស្រាយ ហើយនៅមិនទាន់មានការបកស្រាយឱ្យមានភាពច្បាស់លាស់នៅឡើយ ។

យើងខ្ញុំសូមផ្តល់អនុសាសន៍ក្នុងន័យកែលម្អថា កម្ពុជាគួរតែមានការប្រកាសរបបចំពោះជនដែលមិនអាចដឹងអំពីសកម្មភាពតាមផ្លូវច្បាប់របស់ខ្លួនចំពោះគ្រប់បុគ្គលដែលមិនមានសមត្ថភាពយល់ដឹង និងមិនអាចវិនិច្ឆ័យតាមផ្លូវច្បាប់បាន ព្រោះកាលណាមានការប្រកាសរបបនេះចំពោះពួកគេ នោះនឹងមិនមានទៀតឡើយភាពមិនច្បាស់លាស់ ឬមិនអាចពិចារណា និងវិនិច្ឆ័យបាននៅពេលដែលពួកគេបានធ្វើ ឬបង្កើតសកម្មភាពណាមួយ ដូចជាកិច្ចសន្យា ឬសកម្មភាពផ្សេងៗជាដើម។ ទន្ទឹមនឹងនេះ ទាក់ទងនឹងសកម្មភាពរស់នៅប្រចាំថ្ងៃ ច្បាប់កម្ពុជាគួរតែមានចែងឱ្យបានច្បាស់លាស់ពីទំហំនៃការចំណាយបែបណាដែលជាសកម្មភាពរស់នៅប្រចាំថ្ងៃ។ ចំណែកឯមនុស្សគថ្លង់វិញ ពួកគេមិនអាចធ្វើសកម្មភាពគតិយុត្តទាក់ទងទៅនឹងខ្លួនឯងបានឡើយ ប៉ុន្តែពួកគេមិនត្រូវបាន

ច្បាប់ចាត់ទុកជាបុគ្គលណាមួយក្នុងចំណោមជនដែលត្រូវបានកម្រិតសមត្ថភាពតាមផ្លូវច្បាប់ឡើយ។ នេះក៏ជាបញ្ហាផងដែរ ពីព្រោះសកម្មភាពដែលអ្នកទាំងអស់នេះធ្វើឡើង ឬប្រព្រឹត្តទៅ បើមានវិការៈណាមួយពិតជាពិបាកនៅក្នុងការវិនិច្ឆ័យ ឬវែកញែកឱ្យដឹងថាពួកគេធ្វើទៅ ពួកគេបានដឹង ឬលឺរឿងនោះដែរឬទេ តួយ៉ាងដូចជាមនុស្សគថ្លង់ ធ្វើកិច្ចសន្យា ឬសន្តតិកម្មជាដើម។

ទន្ទឹមនឹងនេះដើម្បីយល់ឱ្យកាន់តែច្បាស់អំពី ប្រភេទសកម្មភាពដែលច្បាប់បានកម្រិតចំពោះជនដែលត្រូវបានកម្រិតសមត្ថភាពឱ្យបានច្បាស់លាស់បន្ថែមទៀត សិក្ខានុសិស្ស សិស្សនិស្សិត អ្នកសិក្សាស្រាវជ្រាវ ដែលមានផ្នត់គំនិតចង់ដឹងចង់ស្វែងយល់ គួរតែធ្វើការសិក្សាស្រាវជ្រាវបន្ថែមពាក់ព័ន្ធទៅនឹងច្បាប់នៃបណ្តាប្រទេសផ្សេងៗ ដើម្បីងាយស្រួលក្នុងការយកមកវិនិច្ឆ័យថា ធ្វើបែបណាទើបមានភាពច្បាស់លាស់ និងលម្អិតជាងអំពីបញ្ហាដែលពាក់ព័ន្ធនឹង ប្រភេទ និងសកម្មភាពនៃជនដែលត្រូវបានកម្រិតសមត្ថភាពនេះ។

# ឯកសារយោង

# ឯកសារយោង

I. **បទដ្ឋានគតិយុត្ត** ( **នៅជាធរមាន** )

- ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧
- ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា
- ក្រមរដ្ឋប្បវេណីជប៉ុន
- ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ឆ្នាំ២០១១
- ច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីមិនមែនជាបណ្តឹង
- ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល
- ច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម
- ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង ឆ្នាំ២០១៧

II. **បទដ្ឋានគតិយុត្ត** ( **និរាករណ៍** )

- ក្រមរដ្ឋប្បវេណីចាស់ ១៩៦៧
- ក្រឹត្យច្បាប់លេខ៣៨

III. **សៀវភៅ និងឯកសារជំនួយផ្សេងៗ**

- សេចក្តីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមរដ្ឋប្បវេណី, ភាគ១ គន្ថី១-គន្ថី៣, ក្រសួងយុត្តិធម៌, ២០១០
- សេចក្តីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមរដ្ឋប្បវេណី, ភាគ៦ គន្ថី៨-គន្ថី៩, ក្រសួងយុត្តិធម៌, ២០១០
- សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ដែលរៀបចំដោយក្រុមការងារនៃអនាគតគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ( បោះពុម្ពលើកទី១ )
- សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណី
- សទ្ទានុក្រមរដ្ឋប្បវេណី
- សៀវភៅជំនួយស្មារតី នីតិបេតិកភណ្ឌ និងគ្រួសារ, ព្រំ រិទ្ធី ( បោះពុម្ពលើកទី១ )
- សៀវភៅ ច្បាប់ និងអំពើហិង្សាក្នុងគ្រួសារ រៀបរៀងដោយ មេធាវី សុក សំអឿន
- សៀវភៅណែនាំសិក្សាក្រមរដ្ឋប្បវេណី ដែលនិពន្ធដោយ អ៊ីកិដា ម៉ាសាអូ ( បោះពុម្ពលើកទី៦ )
- សៀវភៅ សេចក្តីផ្តើមនីតិវិធីរដ្ឋប្បវេណី ដែលនិពន្ធដោយ សាស្ត្រាចារ្យ ណូមូរ៉ា តូយ៉ូហ៊ីរ៉ូ

- សៀវភៅ នីតិកិច្ចសន្យាពិសេសភាគ១ របស់លោកស្រី ប៉ូលី បញ្ញា និងលោក ព្រំ រិទ្ធី ឆ្នាំ២០២១ ( បោះពុម្ពលើកទី១ )
- វចនានុក្រមសម្ដេចសង្ឃ ជួន ណាត
- កម្រងករណីសិក្សា និងសំនួរចម្លើយអំពីការអនុវត្តជាក់ស្ដែងទាក់ទងនឹងក្រមរដ្ឋប្បវេណីរបស់គម្រោងអភិវឌ្ឍន៍ច្បាប់ និងតុលាការក្រុមការងាររាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ
- ឯកសារមេរៀន នៅក្នុងវគ្គបណ្ដុះបណ្ដាលជំនាន់ទី៧ នៃវិភាគទានច្បាប់
- Fresh News: បណ្ដាញព័ត៌មានគ្មានដែនកំណត់

# ឧបសម្ព័ន្ធ

00847574



ព្រះរាជាណាចក្រកម្ពុជា E138/1/10/1/2/3.1
ជាតិ សាសនា ព្រះមហាក្សត្រ
********

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 01-Oct-2012, 11:48
CMS/CFO: Krystal THOMPSON

មន្ទីរឃុំឃាំង អ.វ.ត.ក
ចូល
លេខ 173 ...
ថ្ងៃទី 16 ខែ... ឆ្នាំ 2012
ម៉ោង 10 ...

សាលាដំបូងរាជធានីភ្នំពេញ

លេខ: ២៨៨ (ខ)

## ដីកាសម្រេច

យើង គូ ពៅស៊ីន ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញមាត្រា ៣ និងមាត្រាពាក់ព័ន្ធ នៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីមិនមែនបណ្តឹង ។

-បានឃើញមាត្រា ២៥ និងមាត្រា ១១០៥ និងមាត្រាពាក់ព័ន្ធនៃក្រមរដ្ឋប្បវេណី ។

-បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខៈ ១៦៣៨ ចុះថ្ងៃទី ១៣-០៩-២០១២ ។

-បានឃើញពាក្យសុំប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅចុះថ្ងៃទី ១៣-០៩-២០១២ របស់អ្នកប្តឹងសុំលោកព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ អាស័យដ្ឋានអាគារលេខ ២៥-២៧ ផ្លូវលេខ ២១៧-២១៣ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ។

ដែលមានកម្មវត្ថុៈ សុំឲ្យតុលាការចេញដីកាសម្រេចៈ

១-ជ្រើសតាំងឈ្មោះ អៀង វិជីដា ជាអ្នកអាណាព្យាបាលទូទៅលើឈ្មោះ អៀង ធីរិទ្ធ ។

២-ឲ្យអ្នកអាណាព្យាបាលទូទៅឈ្មោះ អៀង វិជីដា ថែរក្សាឈ្មោះ អៀង ធីរិទ្ធ ដោយឲ្យស្ថិតនៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា និងជូនដំណឹងដល់ការិយាល័យរដ្ឋបាលនៃ អ.វ.ត.ក មុននឹងផ្លាស់ប្តូរអាស័យដ្ឋានរស់នៅទីណាមួយរបស់ឈ្មោះ អៀង ធីរិទ្ធ ។

-បានឃើញពាក្យសុំយកម្តាយទៅថែរក្សារបស់លោកស្រី អៀង វិជីដា ចុះថ្ងៃទី ១៣-០៩-២០១២ ។

-បានឃើញសំណុំរឿងលេខ ០០២/១៩ កញ្ញា ឆ្នាំ២០០៧/អវតក/អជសដ របស់អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

-បានឃើញរបាយការណ៍សង្ខេបរបស់អ្នកជំនាញពាក់ព័ន្ធនឹង អៀង ធីរិទ្ធ ចុះថ្ងៃទី ២៩-០៨-២០១២ ។

-យោងសេចក្តីសម្រេច លើការវាយតម្លៃឡើងវិញអំពីសម្បទាខាងបញ្ញាស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមការជំនុំជម្រះ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ១៣-១២-២០១១ របស់អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី ១៣-០៩-២០១២ ។

## សាលាដំបូងរាជធានីភ្នំពេញ

## សំអាងហេតុ

១-ពាក្យសុំប្រកាសចាប់ផ្តើមអ្នកអាណាព្យាបាលទូទៅលើឈ្មោះ អៀង ធីរិទ្ធ ចុះថ្ងៃទី ១៣-០៩-២០១២ របស់អ្នកប្តឹងសុំលោកព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងរាជធានី

ភ្នំពេញ និងរបស់ឈ្មោះ អៀង វិជីដា មានលក្ខណៈត្រឹមត្រូវតាមមាត្រា ២៦ នៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីមិនមែនបណ្តឹង ។

២-តាមការអះអាងរបស់អ្នកប្តឹងសុំ លោកព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញថាៈ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានសម្រេចដោះលែងឈ្មោះ អៀង ធីរិទ្ធ ដោយមូលហេតុគាត់មានជម្ងឺវើវវាយ បាត់បង់ការចងចាំ ដើម្បីងាយស្រួលគ្រប់គ្រង ជនដែលស្ថិតនៅក្នុងស្ថានភាពជានិរន្តដែលខ្វះសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធភាពតាមផ្លូវច្បាប់នៃសកម្មភាពរបស់ឈ្មោះ អៀង ធីរិទ្ធ ដោយមានវិបត្តិផ្នែកស្មារតី តាមការបញ្ជាក់នៅក្នុងរបាយការណ៍សង្ខេបរបស់អ្នកជំនាញ ទើបលោកព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញប្តឹងសុំឲ្យប្រកាសការចាប់ផ្តើមអ្នកអាណាព្យាបាលទូទៅលើឈ្មោះ អៀង ធីរិទ្ធិ តាមច្បាប់ ។ តាមការអះអាងនេះស្របនឹងពាក្យសុំរបស់ឈ្មោះ អៀង វិជីដា ហើយស្របនឹងរបាយការណ៍សង្ខេបរបស់អ្នកជំនាញពាក់ព័ន្ធនឹង អៀង ធីរិទ្ធ ចុះថ្ងៃទី ២៩-០៨-២០១២ របស់វេជ្ជបណ្ឌិត Seena Fazel អ្នកស្រាវជ្រាវជាន់ខ្ពស់ផ្នែកវិទ្យាសាស្ត្រព្យាបាលជម្ងឺ និងជាវេជ្ជបណ្ឌិតពិគ្រោះយោបល់កិត្តិយសផ្នែកវិកលវិទ្យានីតិវេជ្ជសាស្ត្រសាកលវិទ្យាល័យ OXFord ចក្រភពអង់គ្លេស , សាស្ត្រាចារ្យ John CAMPBELL សាស្ត្រាចារ្យជំនាញព្យាបាលរោគមនុស្សចាស់នៃសាកលវិទ្យាល័យអូតាហ្គូសប្រទេសណូវែលហ្សេឡង់ និងវេជ្ជបណ្ឌិត ហួត លីនណា ជាសាស្ត្រាចារ្យរងផ្នែកវិកលវិទ្យា នៃសាកលវិទ្យាល័យអន្តរជាតិ , ប្រធានផ្នែកពិគ្រោះជម្ងឺផ្លូវចិត្ត នៃមន្ទីរពេទ្យមិត្តភាពខ្មែរសូវៀត នៅរាជធានីភ្នំពេញ ប្រទេសកម្ពុជា សន្និដ្ឋានថាៈ លោកស្រី អៀង ធីរិទ្ធ ពិតជាមានជម្ងឺវង្វេងស្មារតីក្នុងកម្រិត មធ្យមទៅធ្ងន់ធ្ងរ ។

៣-ឈ្មោះ អៀង វិជីដា ភេទស្រី អាយុ ៥១ឆ្នាំ មុខរបរ គ្រូពេទ្យ [redacted] ជាកូនបង្កើតរបស់ឈ្មោះ អៀង ធីរិទ្ធ ។

៤-ឈ្មោះ អៀង ធីរិទ្ធ មានជម្ងឺវើវវាយស្មារតី បាត់បង់ការចងចាំដែលតំរូវឲ្យអ្នកអាណាព្យាបាលទូទៅមានកាតព្វកិច្ចដើម្បីយកចិត្តទុកដាក់ប្រុងប្រយ័ត្នខ្ពស់ដោយមិនឲ្យជននេះទៅទីណាដោយមិនដឹង ។

៥-ដោយផ្អែងតាមសំអាងហេតុខាងលើគប្បីតុលាការសម្រេចតាមពាក្យសុំរបស់អ្នកប្តឹងសុំ ។

**<u>ហេតុដូច្នេះសំរេច</u>**

១-ជ្រើសតាំងឈ្មោះ អៀង វិជីដា ជាអ្នកអាណាព្យាបាលទូទៅលើឈ្មោះ អៀង ធីរិទ្ធ ។

២-ឲ្យអ្នកអាណាព្យាបាលទូទៅឈ្មោះ អៀង វិជីដា ថែរក្សាឈ្មោះ អៀង ធីរិទ្ធ ដោយឲ្យស្ថិតនៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា និងជូនដំណឹងដល់ការិយាល័យរដ្ឋបាលនៃអ.វ.ត.ក មុននឹងផ្លាស់ប្តូរអាស័យដ្ឋានរស់នៅទីណាមួយរបស់ឈ្មោះ អៀង ធីរិទ្ធ ។

-រក្សាសិទ្ធិប្តឹងជំទាស់ក្នុងកំណត់ច្បាប់ ។

រាជធានីភ្នំពេញ ថ្ងៃទី...ខែ កញ្ញា ឆ្នាំ២០១២

ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

ឡិ_ពៅស៊ីន